


# សៀវភៅណែនាំសម្រាប់គ្រូបង្គោល ស្តីពីការបណ្តុះបណ្តាលអំពី ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បង្កលក្ខណៈងាយស្រួល



រក្សាសិទ្ធិគ្រប់យ៉ាង៖ ឆ្នាំ២០២០

រៀបចំដោយ៖

DISABILITY ACTION COUNCIL

humanity &inclusion

គាំទ្រដោយ៖

Australian Aid

ACCESS
Sustainable quality services for all

# មាតិកា


**ព័ត៌មានទូទៅ** ....................................................... ៤

**បញ្ជីនៃអក្សរកាត់៖** ....................................................... ៦

**ផ្នែកទី ១៖ បុព្វកថា** ....................................................... ៧

១.១ ហេតុអ្វីចាំបាច់ត្រូវមានសៀវភៅណែនាំសម្រាប់គ្រូបង្គោលនេះ? ....................................................... ៧

១.២ ទំនាក់ទំនងជាមួយនឹងបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព ....................................................... ៧

១.៣ របៀបប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្គោលនេះ ....................................................... ៧

១.៤ តើនរណាខ្លះគួរប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្គោលនេះ? ....................................................... ៩

១.៥ វិធីសាស្ត្រ ....................................................... ៩

**ផ្នែកទី២៖ ម៉ូឌុលបណ្តុះបណ្តាល កំណត់សម្គាល់សម្រាប់គ្រូបង្គោល និងការណែនាំអំពីលំហាត់** ....................................................... ១០

របៀបវារៈវគ្គបណ្តុះបណ្តាលពេញលេញ៖ ....................................................... ១១

**ម៉ូឌុលទីមួយ៖** វគ្គសេចក្តីផ្តើម និងទស្សនទានគន្លឹះនៃពិការភាព (២៧០ នាទី) ....................................................... ១៣

មេរៀន ១.១៖ វគ្គសេចក្តីផ្តើម ....................................................... ១៣

មេរៀន ១.២៖ ទស្សនទានគន្លឹះនៃពិការភាព ....................................................... ១៦

មេរៀន ១.២.១៖ ការកំណត់និយមន័យនៃកម្សោយនិងពិការភាព (៦០នាទី) ....................................................... ១៧

មេរៀន ១.២.២៖ កត្តាហានិភ័យនាំឱ្យមានកម្សោយផ្សេងៗ (៣០នាទី) ....................................................... ១៧

មេរៀន ១.២.៣៖ ការប្រាស្រ័យទាក់ទងនិងភាសាសមស្រប (៣០នាទី) ....................................................... ១៩

មេរៀន ១.២.៤៖ គំរូពិការភាព (៦០នាទី) ....................................................... ២០

**ម៉ូឌុលទីពីរ៖** សេចក្តីផ្តើមអំពីការបង្កលក្ខណៈងាយស្រួល ការកំណត់និយមន័យ និងក្របខណ្ឌច្បាប់ (១២០នាទី) ....................................................... ២៣

មេរៀន ២.១៖ កំណត់អត្ថន័យនៃការបង្កលក្ខណៈងាយស្រួល (៣០នាទី) ....................................................... ២៤

មេរៀន ២.២៖ ហេតុអ្វីបានជាការបង្កលក្ខណៈងាយស្រួលមានសារៈសំខាន់? ....................................................... ២៥

មេរៀន ២.៣៖ ក្របខណ្ឌច្បាប់អំពីការបង្កលក្ខណៈងាយស្រួល (៤៥នាទី) ....................................................... ២៥

មេរៀន ២.៤៖ តើត្រូវលើកកម្ពស់ការបង្កលក្ខណៈងាយស្រួលយ៉ាងដូចម្តេចខ្លះ?
(៤៥នាទី) ...................................................................................................................២៥
**ម៉ូឌុលទីបី** ៖ គោលការណ៍នៃការបង្កលក្ខណៈងាយស្រួល (១៥០នាទី)...............................................២៦
មេរៀន ៣.១៖ គោលការណ៍ RECU (៦០នាទី)...........................................................................២៧
មេរៀន ៣.២៖ ការរចនាជាសកលនិងការសម្របសម្រួលសមស្រប (៩០នាទី) .....................................២៨
**ម៉ូឌុលទីបួន**៖ ការវាយតម្លៃការបង្កលក្ខណៈងាយស្រួល (២១០នាទី) ..............................................២៩
មេរៀនទី ៤.១៖ ឧបសគ្គចំពោះការបង្កលក្ខណៈងាយស្រួល (៤៥នាទី) ...........................................៣០
មេរៀនទី ៤.២៖ ការឆ្លើយតបដើម្បីកាត់បន្ថយឧបសគ្គចំពោះការបង្កលក្ខណៈងាយស្រួល
(៤៥នាទី) ...................................................................................................................៣០
មេរៀនទី ៤.៣៖ ឧបករណ៍វាយតម្លៃការបង្កលក្ខណៈងាយស្រួលដែលគ្មានលក្ខណៈបច្ចេកទេស .........៣១
**ម៉ូឌុលទីប្រាំ**៖ ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងបរិស្ថានដែលបានបង្កើតឡើង
(១៤០ នាទី) ..............................................................................................................៣២
មេរៀនទី ៥.១៖ ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងតំបន់ទីក្រុង (៤០នាទី) ....................៣៣
មេរៀនទី ៥.២៖ ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងអគារ (៤០នាទី) ...........................៣៣
មេរៀនទី ៥.៣៖ ការរៀបចំបន្ទប់ទឹកដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព
និងជម្រាល (៦០នាទី) ...................................................................................................៣៣
លំហាត់បញ្ចប់មេរៀន ....................................................................................................៣៧
ទម្រង់វាយតម្លៃវគ្គ ..........................................................................................................៣៨
**ផ្នែកទី ៣៖ ឯកសារបណ្តុះបណ្តាល** ..............................................................................៤០
ឯកសារចែកជូន ១.២.១៖ និយមន័យអំពីកម្សោយ និងពិការភាព ................................................៤៧
ឯកសារចែកជូន ១.២.២៖ ផលប៉ះពាល់នៃកម្សោយនិងវាក្យសព្ទត្រឹមត្រូវ .......................................៤៨
ឯកសារចែកជូន ១.២.៣៖ វិធានមូលដ្ឋានស្តីពីរបៀបក្នុងការទំនាក់ទំនងជាមួយជន
មានពិការភាព ...............................................................................................................៤៩
ឯកសារចែកជូន ១.២.៤៖ គំរូនៃពិការភាព .........................................................................៥០
ឯកសារចែកជូន ២.១៖ និយមន័យនៃការបង្កលក្ខណៈងាយស្រួល ..............................................៥៤

ឯកសារចែកជូន ២.២៖ ការបង្កលក្ខណៈងាយស្រួលនៅក្នុងក្របខណ្ឌច្បាប់ ....................................៥៥
ឯកសារចែកជូន ៤.១៖ ឧបសគ្គចំពោះការបង្កលក្ខណៈងាយស្រួល ....................................៥៧
**ផ្នែកទី ៤៖ ជំនាញសិក្សាបែបមនុស្សធំ ....................................៥៨**
**១.១ គោលការណ៍សិក្សាបែបមនុស្សធំ ....................................៥៨**
១.១.១ ការដឹកនាំខ្លួនឯង ....................................៥៨
១.១.២ ការរៀនតាមរយៈការអនុវត្ត ....................................៥៨
១.១.៣ ភាពជាប់ពាក់ព័ន្ធ ....................................៥៩
១.១.៤ បទពិសោធន៍ ....................................៥៩
១.១.៥ វិញ្ញាណទាំងអស់ ....................................៥៩
១.១.៦ ការអនុវត្ត ....................................៥៩
១.១.៧ ការអភិវឌ្ឍផ្ទាល់ខ្លួន ....................................៥៩
១.១.៨ ការចូលរួម ....................................៥៩
**១.២ ជំនាញសម្របសម្រួលនិងជំនាញធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធិ ....................................៥៩**
១.២.១ ការបង្កើតបរិយាកាសសិក្សាវិជ្ជមាន....................................៦០
១.២.២ ពង្រឹងវត្តមានខ្លួនឯងនៅក្នុងថ្នាក់រៀន....................................៦០
១.២.៣ ដំណើរការនិងបច្ចេកទេសសម្របសម្រួល ....................................៦០
១.២.៤ ឥទ្ធិពលនៃហ្គេមនិងការបង្រៀនដៃគូ ....................................៦១
១.២.៥ ការអនុវត្តសកម្មភាព ....................................៦២
**១.៣ ការសម្របសម្រួលកិច្ចពិភាក្សា ករណីសិក្សា និងការសម្តែងតួ ....................................៦៣**
១.៣.១ ការពិភាក្សា ....................................៦៣
១.៣.២ ករណីសិក្សា....................................៦៣
១.៣.៣ ការសម្តែងតួ....................................៦៤
១.៣.៤ ការសង្ខេបមេរៀន....................................៦៥
១.៣.៥ ការផ្តល់មតិត្រលប់....................................៦៥
ឧបសម្ព័ន្ធ ....................................៦៥

# ព័ត៌មានទូទៅ

## អំពីក្រុមប្រឹក្សាសកម្មភាពជនពិការ Disability Action Council (DAC)

**ក្រុមប្រឹក្សាសកម្មភាពជនពិការ(ក.ស.ជ.)** ត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខនស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការបានកំណត់ថាគឺជាយន្តការសម្របសម្រួលនិងពិគ្រោះយោបល់ថ្នាក់ជាតិលើបញ្ហាពិការភាព និងការស្តារលទ្ធភាពពលកម្ម។ ក្រុមប្រឹក្សាសកម្មភាពជនពិការ គឺជាស្ថាប័នអន្តរវិស័យដែលមានសមាសភាពចម្រុះមកពីក្រសួង ស្ថាប័នរដ្ឋ តំណាងវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងតំណាងជនមានពិការភាព។ ក្រុមប្រឹក្សាសកម្មភាពជនពិការមានរចនាសម្ព័ន្ធដូចខាងក្រោម៖

**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ(អ.ក.ស.ជ.)** គឺជាស្ថាប័នសាធារណៈដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ដើម្បីផ្តល់ការពិគ្រោះយោបល់លើវិស័យពិការភាព រៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ជំរុញការអនុវត្តគោលនយោបាយ ច្បាប់ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធវិស័យពិការភាព តាមដាន វាយតម្លៃការអនុវត្តអនុសញ្ញា ច្បាប់ ផែនការយុទ្ធសាស្ត្រ លើកសំណើរកែសម្រួល បំពេញបន្ថែម ឬវិសោធនកម្ម គោលនយោបាយ ច្បាប់ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធវិស័យពិការភាព ទំនាក់ទំនងសហគមន៍ជាតិ អន្តរជាតិ ផ្លាស់ប្តូរបទពិសោធន៍ កៀរគរប្រភពធនធាន រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញានិងស្ថានភាពជនមានពិការភាព រៀបចំទិវាជនមានពិការភាពជាតិ-អន្តរជាតិ និងទិវាជនមានពិការភាពផ្សេងៗ។ បច្ចុប្បន្ន អ.ក.ស.ជ. មានទីតាំងស្ថិតនៅអគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញនៅក្នុងបរិវេណក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ក្រុមការងារសកម្មភាពជនពិការក្រសួង ស្ថាប័ន (ក.ស.ជ.ក.ស.)** គឺជាក្រុមការងារដែលបង្កើតឡើងដោយក្រសួងស្ថាប័នរដ្ឋតាមវិស័យនីមួយៗមានតួនាទីជាក្រុមជនបង្គោលនិងទទួលបន្ទុកការងារពិការភាពនៅក្នុងក្របខណ្ឌនៃវិស័យនិងដែនសមត្ថកិច្ចក្រសួងស្ថាប័នរបស់ខ្លួន។

**ក្រុមប្រឹក្សាសកម្មភាពជនពិការរាជធានី ខេត្ត (ក.ស.ជ.រ.ខ.)** គឺជាក្រុមប្រឹក្សាសកម្មភាពជនពិការដែលបង្កើតឡើងដោយអាជ្ញាធររាជធានី ខេត្តដែលមានសមាសភាពចម្រុះមកពីគ្រប់វិស័យស៊ីវិល កម្លាំងប្រដាប់អាវុធ តំណាង វិស័យឯកជន អង្គការជនមានពិការភាព និងតំណាងជនមានពិការភាព ដែលមានអភិបាលរងខេត្តជាប្រធានដឹកនាំការងារអន្តរវិស័យដែលពាក់ព័ន្ធនិងការងារពិការភាពនៅក្នុងដែនសមត្ថកិច្ចនៃតំបន់រដ្ឋបាលរាជធានី-ខេត្តរបស់ខ្លួន។

# អំពីអង្គការ Handicap International - Humanity & Inclusion (HI)

អង្គការ HI ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៨២។ អង្គការ HI គឺជាអង្គការឯករាជ្យនិងផ្តល់ជំនួយដោយមិនលំអៀង ដែលកំពុងធ្វើការងារនៅក្នុងស្ថានភាពនៃភាពក្រីក្រនិងការផាត់ចេញ ជម្លោះ និងគ្រោះមហន្តរាយ។ អង្គការ HI ធ្វើការងារជាមួយជនមានពិការភាព និងប្រជាជនងាយរងគ្រោះដោយចាត់វិធានការនិងបង្ហាញអំពីការពិតនានាដើម្បីឆ្លើយតបចំពោះតម្រូវការចាំបាច់ កែលម្អស្ថានភាពរស់នៅ លើកកម្ពស់ការគោរពសេចក្តីថ្លៃថ្នូរ និងសិទ្ធិជាមូលដ្ឋានរបស់ជនមានពិការភាព។ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨ ចលនាជាសកលនៃអង្គការជនពិការអន្តរជាតិ Handicap International បានប្តូរឈ្មោះទៅជាអង្គការ Humanity & Inclusion។ នៅពេលបច្ចុប្បន្នសហព័ន្ធបាននិងកំពុងដំណើរការគម្រោងនានានៅក្នុងប្រទេសប្រមាណហុកសិបក្រោមឈ្មោះប្រតិបត្តិការថា “Humanity & Inclusion”, “Handicap International” ឬ “Atlas Logistique”។ រាល់ឯកសារដែលមានក្បាលលិខិត (Letterhead) “Humanity & Inclusion” អនុវត្តបានចំពោះក្រុម Atlas Logistique និង Handicap International។

## កម្រងឯកសារបណ្តុះបណ្តាលស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលមានការចូលរួមរៀបចំពីក្រុមការងារដូចខាងក្រោម៖

| អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ | | អង្គការជនពិការអន្តរជាតិ(HI) | |
|---|---|---|---|
| ១. ឯកឧត្តម **ឯម ច័ន្ទមករា** | រដ្ឋលេខាធិការនៃស.អ.យ. | ១. លោកស្រី **អេឌីធ វ៉ាន វីញ៉ាដិន** | ប្រធានប្រចាំប្រទេស |
| ២. ឯកឧត្តម **អ៊ុំ សម្បត្តិ** | អគ្គលេខាធិការរងនៃអ.ក.ស.ជ. | ២. លោក **ជរ វ៉ាដា** | ប្រធានគាំទ្របច្ចេកទេស |
| ៣. លោក **ឈន អក្ខរា** | ប្រធានផ្នែកអភិវឌ្ឍន៍សេវាពិការភាព | ៣. លោកស្រី **អេរីកា ត្រាប៊ូកូ** | អ្នកឯកទេសផ្នែកការបង្កលក្ខណៈងាយស្រួល |

# បញ្ជីអក្សរកាត់

| | |
|---|---|
| CDRP | តំណាងជនមានពិការភាពនៅថ្នាក់ឃុំ |
| CIP | កម្មវិធីវិនិយោគឃុំ-សង្កាត់ |
| CRPD | អនុសញ្ញាស្តីពីសិទ្ធិជនពិការ |
| DAC | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| DPOs | អង្គការតំណាងជនពិការ |
| DVN | បណ្តាញភូមិជនមានពិការភាព |
| ICT | បច្ចេកវិទ្យាព័ត៌មានវិទ្យានិងសារគមនាគមន៍ |
| LAs | អាជ្ញាធរមូលដ្ឋាន |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NTAA | ការវិភាគការបង្កលក្ខណៈងាយស្រួលដែលគ្មានលក្ខណៈបច្ចេកទេស |
| PPT | កម្មវិធី PowerPoint |
| PWDs | ជនមានពិការភាព |
| RECU | ការទៅដល់ ការចូលក្នុង ការផ្លាស់ទី ការប្រើប្រាស់ |
| SDGs | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| STD | ជំងឺកាមរោគ |
| ToT | ការបណ្តុះបណ្តាលគ្រូបង្គោល |
| UN | អង្គការសហប្រជាជាតិ |
| UNCRPD | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការ |
| WHO | អង្គការសុខភាពពិភពលោក |

# ផ្នែកទី ១៖ បុព្វកថា

## ១.១ ហេតុអ្វីចាំបាច់ត្រូវមានសៀវភៅណែនាំសម្រាប់គ្រូបង្គោលនេះ ?

សៀវភៅណែនាំសម្រាប់គ្រូបង្គោលផ្នែកបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពត្រូវបានរៀបចំបង្កើតឡើង ដើម្បីផ្តល់ការណែនាំសម្រាប់គ្រូបង្គោលផ្នែកបង្កលក្ខណៈងាយស្រួល នៅក្នុងអំឡុងពេលបណ្តុះបណ្តាលរបស់ខ្លួនដល់អ្នកភាគីពាក់ព័ន្ធផ្សេងទៀតស្តីពីការប្រើប្រាស់ និងគោលការណ៍នៃ **"ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព"**។ សៀវភៅណែនាំនេះលើកកម្ពស់ការប្រើប្រាស់វិធីសាស្ត្របែបចូលរួមនិងបច្ចេកទេសសិក្សាសកម្ម។ ទោះជាយ៉ាងណាក៏ដោយ កិច្ចខិតខំប្រឹងប្រែងពង្រឹងសមត្ថភាពគួរតែដាក់បញ្ចូលនូវការបណ្តុះបណ្តាលច្រើនជាងការគ្រាន់តែជាការបណ្តុះបណ្តាល។អាស្រ័យហេតុនេះខ្លឹមសារនៃសៀវភៅណែនាំនេះអាចបម្រើមិនត្រឹមតែជាមូលដ្ឋានសម្រាប់ការបណ្តុះបណ្តាលនោះទេប៉ុន្តែក៏សម្រាប់ជាសកម្មភាពតាមដានជាច្រើនផ្សេងទៀតដូចជាការបង្ហាត់បង្រៀនក្នុងពេលកំពុងបំពេញការងារ សិក្ខាសាលា រៀបចំតាមតម្រូវការប្រធានបទ ឬ សកម្មភាពស្វែងរកការគាំទ្រមតិជាដើម។

## ១.២ ទំនាក់ទំនងជាមួយនឹងបទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព

"សៀវភៅណែនាំសម្រាប់គ្រូបង្គោលស្តីពីការបណ្តុះបណ្តាលស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល" នេះពន្យល់អំពីទស្សនទាននៃការបង្កលក្ខណៈងាយស្រួលជាទូទៅ និងផ្តល់នូវការយល់ដឹងកាន់តែច្រើនថែមទៀតអំពី "សៀវភៅណែនាំស្តីពីការបណ្តុះបណ្តាលអំពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល និងរបៀបប្រើប្រាស់សៀវភៅណែនាំនេះនៅក្នុងរបាយការណ៍វាយតម្លៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល។ សៀវភៅណែនាំនេះផ្តល់នូវរូបភាពច្បាស់លាស់អំពីរបៀបរៀបចំការបណ្តុះបណ្តាលដល់គ្រូបង្គោលស្តីពីការបង្កលក្ខណៈ ងាយស្រួល និងជួយដល់គ្រូបង្គោល ក្នុងការលើកកម្ពស់ បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។

## ១.៣ របៀបប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្គោលនេះ

សៀវភៅណែនាំសម្រាប់គ្រូបង្គោលនេះមានបួនផ្នែកសំខាន់ដូចខាងក្រោម៖

### ផ្នែកទី១៖ បុព្វកថា

- **ផ្នែកណែនាំ៖** នៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្គោលនេះ គឺមានរៀបរាប់អំពីរចនាសម្ព័ន្ធ និងផ្នែកដែលស្ថិតនៅក្រោមផ្នែកនេះ។ ផ្នែកនេះក៏មានបញ្ជាក់អំពីទំនាក់ទំនងជាមួយនឹង "បទដ្ឋានបច្ចេកទេសនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព" និងរបៀបប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្គោល។

### ផ្នែកទី២៖ ម៉ូឌុលបណ្តុះបណ្តាល កំណត់សម្គាល់សម្រាប់គ្រូបង្គោល និងការណែនាំអំពីលំហាត់

- **វគ្គសេចក្តីផ្តើម៖** វគ្គស្វាគមន៍និងសេចក្តីផ្តើមអំពីការបណ្តុះបណ្តាលឧទាហរណ៍អំពីលំហាត់នៃការនែនាំខ្លួនដើម្បីអនុញ្ញាតឱ្យសិក្ខាកាមស្គាល់គ្នាទៅវិញទៅមក បង្កើតវិន័យក្នុងថ្នាក់រៀន សេចក្តីផ្តើមអំពីការបណ្តុះបណ្តាល និង

របៀបវារៈនៃវគ្គបណ្តុះបណ្តាលដោយកំណត់ការរំពឹងទុករបស់សិក្ខាកាម និងការរៀបចំការផ្លាស់ប្តូរបទពិសោធន៍ជាដើម។

## ម៉ូឌុលបណ្តុះបណ្តាលនិងកំណត់សម្គាល់សម្រាប់គ្រូបង្គោល៖

- **ម៉ូឌុលបណ្តុះបណ្តាលនិងកំណត់សម្គាល់សម្រាប់គ្រូបង្គោល៖** រៀបរាប់អំពីមេរៀនមួយចំនួននៃសៀវភៅណែនាំស្តីពីការបណ្តុះបណ្តាលស្តីពីការបង្កលក្ខណៈងាយស្រួល។ អ្នកត្រូវតែអានម៉ូឌុលនេះមុនពេលចាប់ផ្តើមការបណ្តុះបណ្តាលដើម្បីមានលទ្ធភាពសម្របសម្រួលមេរៀននិងលំហាត់នានា ព្រមទាំងអាចកែសម្រួលម៉ូឌុលទាំងនេះនៅពេលចាំបាច់ជាពិសេសនៅពេលម៉ោងបង្រៀននៅសល់តិច។ អ្នកនឹងរកឃើញព័ត៌មានសារតារនិងការណែនាំអំពីរបៀបសម្របសម្រួលមេរៀនទាំងអស់។គ្រូបង្គោល និងសហគ្រូបង្គោលចាំបាច់ត្រូវតែអានផ្នែកកំណត់សម្គាល់សម្រាប់គ្រូបង្គោល ដើម្បីអាចផ្តល់ការបណ្តុះបណ្តាលបានដោយរលូនដោយសារតែកំណត់សម្គាល់ទាំងនោះនឹងជួយឱ្យគ្រូបង្គោលយល់ដឹងកាន់តែច្បាស់លាស់អំពីខ្លឹមសារ នៃការបណ្តុះបណ្តាលក៏ដូចជាផ្តល់ជូននូវចំណេះដឹងបន្ថែមសម្រាប់ការឆ្លើយសំណួរដែលសិក្ខាកាមអាចមាននៅក្នុងអំឡុងពេលបណ្តុះបណ្តាលផងដែរ។

## ម៉ូឌុលបណ្តុះបណ្តាលរួមមាន៖

- សេចក្តីណែនាំអំពីពិការភាពនិងកម្សោយសរីរាង្គ (ទស្សនទាននៃពិការភាព)
- សេចក្តីណែនាំអំពីក្របខណ្ឌច្បាប់ និយមន័យ និងទស្សនទាននៃការបង្កលក្ខណៈងាយស្រួល
- ការវាយតម្លៃការបង្កលក្ខណៈងាយស្រួល ឧបសគ្គនៃការបង្កលក្ខណៈងាយស្រួលរបៀបលើកកម្ពស់ការបង្កលក្ខណៈងាយស្រួល គោលការណ៍នៃការបង្កលក្ខណៈងាយស្រួល– មេរៀនទ្រឹស្តី។
- ការវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលដែលគ្មានលក្ខណៈបច្ចេកទេស (NTAA) – មេរៀនអនុវត្តន៍។
- ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅតំបន់នៅទីក្រុង។
- **ការណែនាំអំពីលំហាត់៖**លោកអ្នកនឹងរកឃើញការពន្យល់មួយជំហានម្តងៗអំពីរបៀបសម្របសម្រួលការអនុវត្តម៉ូឌុលនៃការបណ្តុះបណ្តាល។

## ផ្នែកទី៣៖ ឯកសារចែកជូនសម្រាប់ការបណ្តុះបណ្តាល

- លោកអ្នកនឹងមើលឃើញឯកសារចែកជូនដែលត្រូវអាននៅមុនពេលការបណ្តុះបណ្តាល។ ឯកសារចែកជូនទាំងនេះអាចផ្សព្វផ្សាយជូនសិក្ខាកាមទាំងអស់។

## ផ្នែកទី៤៖ ជំនាញរៀនសូត្ររបស់មនុស្សពេញវ័យ

- ដើម្បីបណ្តុះបណ្តាលមនុស្សពេញវ័យឱ្យរៀនសូត្រប្រកបដោយប្រសិទ្ធភាពគ្រូបង្គោលចាំបាច់ត្រូវតែពង្រឹងបច្ចេកទេសនិងគោលការណ៍ជាក់លាក់មួយចំនួន។ ផ្នែកនេះផ្តល់នូវក្របខណ្ឌ ឬរចនាសម្ព័ន្ធជាច្រើនដោយធ្វើការពិចារណាទៅលើពេលវេលា ធនធាន លំហាត់ ការសម្តែងតួសាកល្បងដែលរាប់បញ្ចូលទាំងផ្នែកជំនាញរៀនសូត្ររបស់មនុស្សពេញវ័យផងដែរ។

## ១.៤ តើនរណាខ្លះគួរប្រើប្រាស់សៀវភៅណែនាំសម្រាប់គ្រូបង្គោលនេះ ?

យើងសូមណែនាំថាមានតែគ្រូបង្គោលដែលបានទទួលការបណ្តុះបណ្តាលអំពីការបង្កលក្ខណៈងាយស្រួលប៉ុណ្ណោះដែលអាចបង្កើតមេរៀនទាំងនេះបាន។ យើងសូមលើកទឹកចិត្តឱ្យគ្រូបង្គោលអញ្ជើញជនមានពិការភាព ជាពិសេសអ្នកដឹកនាំអង្គការតំណាងជនពិការឱ្យចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាល ដើម្បីឱ្យពួកគេអាចធ្វើជាធនធានដ៏ល្អនៅក្នុងវគ្គបណ្តុះបណ្តាលនិងអំពីការវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលដែលគ្មានលក្ខណៈ បច្ចេកទេស។

## ១.៥ វិធីសាស្រ្ត

ម៉ូឌុលនៃការបណ្តុះបណ្តាលនីមួយៗមានរយៈពេលខុសៗគ្នាដែលបានរៀបចំឡើងយ៉ាងជាក់លាក់ ហើយមេរៀនបណ្តុះបណ្តាលគឺបានដកស្រង់ចេញពី **"សៀវភៅណែនាំស្តីពីការបណ្តុះបណ្តាលអំពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល"**។ ម៉ូឌុលនៃការបណ្តុះបណ្តាលនីមួយៗមានគោលបំណងទូទៅពាក់ព័ន្ធទស្សនទាននៃបង្កលក្ខណៈងាយស្រួល និងពិការភាព។ ម៉ូឌុលនៃការបណ្តុះបណ្តាលរាប់បញ្ចូលនូវព័ត៌មានលម្អិតអំពីមេរៀន ប្រធានបទនៃមេរៀននីមួយៗ និងគោលបំណងជាក់លាក់របស់ប្រធានបទ សម្ភារដែលត្រូវការ និងរយៈពេលប្រហាក់ប្រហែលនៃមេរៀននិមួយៗ។ គ្រូបង្គោលគួរតែមានជំនាញផ្នែកបណ្តុះបណ្តាលនិងការសម្របសម្រួល។ ជាការពិតណាស់ គ្រូបង្គោលតែងតែសម្របសម្រួលវិធីសាស្រ្តបណ្តុះបណ្តាលដើម្បីពន្យល់នូវខ្លឹមសារនៃមេរៀននិមួយៗ។សកម្មភាពដែលបានលើកឡើងនឹងជួយគ្រូបង្គោលនៅក្នុងការសម្របសម្រួលសមត្ថភាពរៀនសូត្រជាច្រើនរបស់សិក្ខាកាម។ គ្រូបង្គោលទទួលបានការលើកទឹកចិត្តឱ្យប្រើប្រាស់សៀវភៅណែនាំនេះដោយមានភាពបត់បែនដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិក្ខាកាមចំណាប់អារម្មណ៍ កម្រិតចំណេះដឹង និងបទពិសោធន៍ដែលមានស្រាប់។ អាស្រ័យហេតុនេះ ទោះបីជាសៀវភៅណែនាំសម្រាប់គ្រូបង្គោលនេះ លើកឡើងពីរយៈពេលបង្រៀនតាមលំដាប់លំដោយ និងប្រហាក់ប្រហែលសម្រាប់មេរៀននិមួយៗក៏ដោយ តែយើងមិនរំពឹងថាគ្រប់គ្រូបង្គោលទាំងអស់នឹង

អនុវត្តគ្រប់មេរៀនទាំងអស់ទៅតាមរបៀបដូចគ្នាបេះបិទដូចដែលបានបង្ហាញនៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្គោលនេះឡើយ។ ស្រដៀងគ្នានេះដែរ ពេលវេលាដែលត្រូវការនៃមេរៀននីមួយៗនឹងអាស្រ័យទៅលើចំនួនសិក្ខាកាមដែលបានចូលរួមសំណួររបស់សិក្ខាកាមការពិភាក្សាក្រុមនិងពេលវេលាដែលត្រូវការសម្រាប់ការលេងហ្គេមឬល្បែងថាមពលរបស់អ្នកសម្របសម្រួល។ ឧទាហរណ៍៖ សកម្មភាពនឹងត្រូវចំណាយពេលច្រើនជាមួយនឹងក្រុមធំ ប្រសិនបើការបណ្តុះបណ្តាលមានអ្នកបកប្រែភាសា ឬអ្នកបកប្រែភាសាកាយវិការ ឬប្រសិនបើអ្នកបណ្តុះបណ្តាលជាមួយនឹងសិក្ខាកាមដែលមិនមានចំណេះដឹងពីមុនមកអំពីទស្សនទានអំពីពិការភាពនិងការបង្កលក្ខណៈងាយស្រួលជាដើម។ គ្រូបង្គោលត្រូវបានលើកទឹកចិត្តឱ្យធ្វើជាអ្នកអនុវត្តដែលមានភាពឆ្លុះបញ្ចាំង ដែលនេះមានន័យថាជាការពិនិត្យត្រលប់ទៅមើលរបៀបដែលខ្លួនអ្នកបានសម្របសម្រួលមេរៀននីមួយៗ ឬពន្យល់អំពីប្រធានបទជាក់លាក់ណាមួយ និងធ្វើការត្រិះរិះពិចារណាទៅលើចំណុចល្អដែលបានអនុវត្តកន្លងមក និងចំណុចផ្សេងទៀតដែលត្រូវកែលម្អនៅពេលសម្របសម្រួលវគ្គលើកក្រោយទៀត។ ពួកគាត់ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់សកម្មភាពវាយតម្លៃវគ្គបណ្តុះបណ្តាលដើម្បីជួយវាស់វែងទស្សនៈរបស់សិក្ខាកាមចំពោះប្រធានបទនិងវិធីសាស្រ្តបណ្តុះបណ្តាល។ សៀវភៅណែនាំសម្រាប់គ្រូបង្គោល គួរតែជាឯកសារសាវ័ន្តដែលត្រូវតែពិនិត្យមើលឡើងវិញនិងកែលម្អដែលជាផ្នែកត្រូវធ្វើការពិភាក្សាជាបន្តបន្ទាប់សម្រាប់ការអនុវត្តដែលមានបរិយាបន្ន។ គ្រូបង្គោលដែលទទួលបានការគាំទ្រពីអង្គការ៣ ត្រូវបានជំរុញទឹកចិត្តឱ្យពិនិត្យមើលម៉ូឌុលនៃការបណ្តុះបណ្តាលនៅមុនពេលចាប់ផ្តើមរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបង្កលក្ខណៈងាយស្រួល។

# ផ្នែកទី២៖ ម៉ូឌុលបណ្តុះបណ្តាល កំណត់សម្គាល់សម្រាប់គ្រូបង្គោលនិងការណែនាំអំពីលំហាត់

គ្រូបង្គោលអាចផ្តល់ការបណ្តុះបណ្តាលស្តីពីការបង្កលក្ខណៈងាយស្រួលសម្រាប់រយៈពេលពីរថ្ងៃ។ សូមណែនាំថា ដំបូងសិក្ខាកាមត្រូវចូលរួមនៅក្នុងការបណ្តុះបណ្តាលស្តីពីមូលដ្ឋាននៃពិការភាពនិងកម្សោយសរីរាង្គនៅថ្ងៃទីមួយនៃវគ្គបណ្តុះបណ្តាលជាមុនសិន។ កំណត់សម្គាល់សម្រាប់គ្រូបង្គោលបានផ្តល់ជូននៅគ្រប់មេរៀនទាំងអស់នៃសៀវភៅណែនាំនេះមួយជំហានម្តងៗរួមទាំងលំហាត់និងល្បែងថាមពលឬហ្គេមសម្រាប់សិក្ខាកាម។ការណែនាំសម្រាប់គ្រូបង្គោលនេះ អាចកែសម្រួលឱ្យត្រូវនឹងបរិបទនិងកម្រិតចំណេះដឹងរបស់សិក្ខាកាម។

**តារាង១៖ ម៉ូឌុលបណ្តុះបណ្តាលនិងមេរៀន**

**តារាងខាងក្រោមនេះឆ្លុះបញ្ចាំងពីមេរៀនផ្សេងៗគ្នានៃម៉ូឌុលបណ្តុះបណ្តាល៖**

| ម៉ូឌុលបណ្តុះបណ្តាល | មេរៀន | រយៈពេល | |
|---|---|---|---|
| | | អប្បបរមា (នាទី) | អតិបរមា (នាទី) |
| ម៉ូឌុលទី១៖ វគ្គសេចក្តីផ្តើម។ ទស្សនទានគន្លឹះនៃពិការភាព | ១. វគ្គសេចក្តីផ្តើម<br>២. កំណត់និយមន័យនៃកម្សោយនិងពិការភាព<br>៣. កត្តាហានិភ័យនាំឱ្យមានកម្សោយសរីរាង្គ<br>៤. ការប្រាស្រ័យទាក់ទងនិងភាសាសមស្រប<br>៥. គំរូពិការភាព | ៩០<br>១១០ | ១០០<br>១២០ |
| ម៉ូឌុលទី២៖ សេចក្តីផ្តើមអំពីការបង្កលក្ខណៈងាយស្រួល និងក្របខណ្ឌច្បាប់ | ១. តើអ្វីទៅគឺជាការបង្កលក្ខណៈងាយស្រួល?<br>២. ហេតុអ្វីបានជាការបង្កលក្ខណៈងាយស្រួលមានសារៈសំខាន់?<br>៣. ការដាក់បញ្ចូលការបង្កលក្ខណៈងាយស្រួលនៅក្នុងក្របខណ្ឌជាតិនិងអន្តរជាតិ<br>៤. តើត្រូវលើកកម្ពស់ការបង្កលក្ខណៈងាយស្រួលយ៉ាងដូចម្តេច? | ២០០ | ២១០ |
| ម៉ូឌុលទី៣៖ គោលការណ៍នៃការបង្កលក្ខណៈងាយស្រួល | ១. គោលការណ៍ RECU ការរចនាជាសកលនិងការសម្របសម្រួលសមស្រប | ១៥០ | ១៦០ |

| | | | |
|---|---|---|---|
| ម៉ូឌុលទី៤៖ ការវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធ រូបវន្តបង្កលក្ខណៈងាយស្រួល | ១. ឧបសគ្គនៃការបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពនិងការឆ្លើយតបដើម្បីកាត់បន្ថយឧបសគ្គនៃការបង្កលក្ខណៈងាយស្រួល<br>២. ឧបករណ៍វាយតម្លៃឧបសគ្គបង្កលក្ខណៈងាយស្រួល និងមេរៀនអនុវត្តន៍ | ២១០ | ២២០ |
| ម៉ូឌុលទី៥៖ ការកែលម្អ ឧបសគ្គបង្កលក្ខណៈងាយស្រួលនៅក្នុងបរិស្ថានដែលបានកសាង(តាមបទដ្ឋាន បច្ចេកទេសថ្នាក់ជាតិ) | ១. ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងតំបន់នៅទីក្រុង<br>២. ការកែលម្អឧបសគ្គបង្កលក្ខណៈងាយស្រួលនៅក្នុងអគារ ការវាយតម្លៃជម្រាល បន្ទប់ទឹក និងការរចនា | | |

| មេរៀនបន្ថែម៖ | |
|---|---|
| ការសង្ខេបឡើងវិញប្រចាំថ្ងៃ | ១០ នាទី |
| ការរំឭកមេរៀនពេលព្រឹក | ៣០ នាទី |
| ល្បែងបង្កើនថាមពល | ១០ នាទី |
| ការវាយតម្លៃនិងការបញ្ចប់មេរៀន | ៣០ នាទី |


រូបភាពទី១៖ គ្រូបង្គោលកំពុងតែពន្យល់អំពីម៉ូឌុលបណ្ដុះបណ្ដាលដល់សិក្ខាកាម

## របៀបវារៈវគ្គបណ្ដុះបណ្ដាលពេញលេញ៖

| ថ្ងៃទី១ | មេរៀន | ថ្ងៃទី២ | មេរៀន |
|---|---|---|---|
| វគ្គពេលព្រឹក | | វគ្គពេលព្រឹក | |
| ៧:៣០-៨:០០ | ការចុះឈ្មោះសិក្ខាកាម | ៨:០០-៨:១៥ | សង្ខេបឡើងវិញថ្ងៃទី១ |
| ៨:០០-៨:១៥ | សុន្ទរកថាស្វាគមន៍ | ៨:១៥-៩:១៥ | មេរៀន ៣.១៖ គោលការណ៍ RECU |
| ៨:១៥-៩:៤៥ | មេរៀន១.១៖ វគ្គសេចក្តីផ្តើមការរំពឹងទុក និងការធ្វើតេស្តមុនពេលវគ្គបណ្តុះបណ្តាល | ៩:១៥-១០:០០ | មេរៀន ៣.២៖ ការរចនាជាសកល និងការសម្របសម្រួលសមស្រប |
| ៩:៤៥-១០:០០ | សម្រាកពិសារអាហារសម្រន់ | ១០:០០-១០:១៥ | សម្រាកពិសារអាហារសម្រន់ |

| | | | |
|---|---|---|---|
| ១០:០០-១២:០០ | មេរៀន ១.២៖ ទស្សនទានគន្លឹះនៃពិការភាព<br>មេរៀន ១.២.១៖ ការកំណត់និយមន័យនៃកម្សោយសរីរាង្គនិងពិការភាព<br>មេរៀន ១.២.២៖ កត្តាហានិភ័យនាំឱ្យមានកម្សោយសរីរាង្គផ្សេងៗ<br>មេរៀន ១.២.៣៖ ការប្រាស្រ័យទាក់ទងនិងភាសាសមស្រប | ១០:១៥-១១:០០ | មេរៀន ៣.២៖ ការសម្របសម្រួលសមស្រប (បន្ត) |
| | | ១១:០០-១២:០០ | មេរៀន ៤.១៖ ឧបសគ្គនៃការបង្កលក្ខណៈងាយស្រួល<br>មេរៀន ៤.២៖ការឆ្លើយតបដើម្បីកាត់បន្ថយឧបសគ្គបង្កលក្ខណៈងាយស្រួល |
| **១២:០០-១៣:០០** | **សម្រាកអាហារថ្ងៃត្រង់** | **១២:០០-១៣:០០** | **សម្រាកអាហារថ្ងៃត្រង់** |
| ១៣:០០-១៣:១៥ | ល្បែងបង្កើនថាមពល | ១៣:០០-១៣:១៥ | ល្បែងបង្កើនថាមពល |
| ១៣:១៥-១៤:១៥ | មេរៀន ១.២.៤៖ គំរូពិការភាព | ១៣:១៥-១៤:១៥ | មេរៀន ៤.៣៖ ឧបករណ៍វាយតម្លៃការបង្កលក្ខណៈងាយស្រួលដែលគ្មានលក្ខណៈបច្ចេកទេស |
| ១៤:១៥-១៥:១៥ | មេរៀន ២.១៖កំណត់និយមន័យអំពីការបង្កលក្ខណៈងាយស្រួល<br>មេរៀន ២.២៖ ហេតុអ្វីបានជាការបង្កលក្ខណៈងាយស្រួលមានសារៈសំខាន់? | ១៤:១៥-១៥:០០ | មេរៀន ៤.៣៖ ឧបករណ៍វាយតម្លៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលដែលគ្មាន លក្ខណៈបច្ចេកទេស (ត) |
| **១៥:១៥-១៥:៣០** | **សម្រាកពិសារអាហារសម្រន់** | **១៥:០០-១៥:១៥** | **សម្រាកពិសារអាហារសម្រន់** |
| ១៥:៣០-១៦:០០ | មេរៀន ២.៣៖ ក្របខណ្ឌច្បាប់អំពីការបង្កលក្ខណៈងាយស្រួល | ១៥:១៥-១៦:៣០ | មេរៀន ៥.១៖ ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅទីក្រុង<br>មេរៀន ៥.២៖ ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងអគារ |
| ១៦:០០-១៧:០០ | មេរៀន ២.៤៖ តើត្រូវលើកកម្ពស់ការបង្កលក្ខណៈងាយស្រួលយ៉ាងដូចម្តេច? | ១៦:៣០-១៧:០០ | **ការបញ្ចប់វគ្គ**<br>• ការធ្វើតេស្តក្រោយពេលបញ្ចប់វគ្គបណ្តុះបណ្តាល និងការវាយតម្លៃវគ្គ<br>• សុន្ទរកថាបិទ |
| **ចប់ថ្ងៃទី១** | | **ចប់ថ្ងៃទី២** | |

## ម៉ូឌុលទីមួយ៖ វគ្គសេចក្តីផ្តើម និងទស្សនទានគន្លឹះនៃពិការភាព (២៧០ នាទី)

### មេរៀន ១.១៖ វគ្គសេចក្តីផ្តើម (៩០នាទី)

| សកម្មភាព ១៖ ការស្វាគមន៍ | ការស្វាគមន៍ |
|---|---|
| គោលបំណង | ✓ ការស្វាគមន៍អ្នកគ្រប់គ្នាដែលបានចូលរួមនៅក្នុងការបណ្តុះបណ្តាល |
| រយៈពេល | ១៥នាទី |
| សម្ភារ | គ្មាន |
| **សកម្មភាព ២៖ ការណែនាំខ្លួនទៅវិញទៅមក** | **ការណែនាំខ្លួន** |
| គោលបំណង | ✓ ដើម្បីអនុញ្ញាតឱ្យអ្នកគ្រប់គ្នាស្គាល់ឈ្មោះរបស់គ្នាទៅវិញទៅមក និងចំណាប់អារម្មណ៍ចម្បងចំពោះការងាររបស់ពួកគេ<br>✓ អភិវឌ្ឍបរិយាកាសថ្មៃប្រឌិតនិងបើកចំហ |
| រយៈពេល | ១៥នាទី |
| វិធីសាស្ត្រ | ហ្គេមបំបែបធាតុត្រជាក់៖ ការស្វាគមន៍ |
| សម្ភារ | សន្លឹកកាត ក្រដាស ប៊ិក ឬហ្វឺត |
| **សកម្មភាព ៣៖ ការបង្កើតវិន័យក្នុងថ្នាក់រៀន** | **ការឯកភាពទៅលើវិន័យក្នុងថ្នាក់រៀននៃការបណ្តុះបណ្តាល** |
| គោលបំណង | ✓ ធានាថាក្រុមមានការយល់ដឹងអំពីរបៀបធ្វើការងាររួមគ្នា |
| រយៈពេល | ១០នាទី |
| វិធីសាស្ត្រ | ការពិភាក្សាជាក្រុមនិងធ្វើសេចក្តីសម្រេចចិត្តចុងក្រោយ |
| សម្ភារ | ក្រដាសផ្ទាំងធំ |
| **សកម្មភាព ៤៖ សេចក្តីណែនាំការបណ្តុះបណ្តាល និងកាលវិភាគ** | **ការតម្រង់ទិសអំពីការបណ្តុះបណ្តាលនិងកាលវិភាគប្រចាំថ្ងៃ** |
| **គោលបំណង** | ✓ អនុញ្ញាតឱ្យសិក្ខាកាមយល់ដឹងគោលបំណងនៃការបណ្តុះបណ្តាល និងបន្សាំឱ្យពួកគេយល់ដឹងពីកាលវិភាគនៅថ្ងៃបន្ទាប់ |
| រយៈពេល | ១០នាទី |

| | |
|---|---|
| វិធីសាស្ត្រ | ស្លាយ PowerPoint ទី១ |
| សម្ភារ | កុំព្យូទ័រយួរដៃ LCD និងឯកសារចែកជូនអំពីកាលវិភាគបណ្តុះបណ្តាល |
| **សកម្មភាព ៥៖ ការរំពឹងទុក** | **កំណត់ការរំពឹងទុករបស់សិក្ខាកាម** |
| **គោលបំណង** | ✓ ធានាថាអ្នកគ្រប់គ្នាយល់ដឹងអំពីការរំពឹងទុករបស់ពួកគេ<br>✓ កំណត់ការរំពឹងទុកដែលមិនបានលើកឡើងនិងពន្យល់ទៅកាន់សិក្ខាកាម |
| **រយៈពេល** | ១០នាទី |
| **វិធីសាស្ត្រ** | ផ្តល់អ្នកគ្រប់គ្នានូវសន្លឹកកាតនិងសុំឱ្យពួកគេសរសេរនូវការរំពឹងទុកសំខាន់ចំនួនបីដែលចង់ដឹងអំពីវគ្គបណ្តុះបណ្តាល ហើយបិទនៅលើក្តារខៀន |
| **សម្ភារ** | សន្លឹកកាត ស្កុតក្រដាស |
| **សកម្មភាព ៦៖ ការធ្វើតេស្តមុនពេលបណ្តុះបណ្តាល** | **តេស្តសរសេរ ការពិនិត្យមើលចំណេះដឹងជាមុនរបស់សិក្ខាកាម** |
| **គោលបំណង** | ✓ ពិនិត្យមើលការយល់ដឹងរបស់សិក្ខាកាមអំពីនិយមន័យពិការភាពកម្សោយសរីរាង្គ គោលការណ៍និងទស្សនទាននៃការបង្កលក្ខណៈងាយស្រួល |
| **រយៈពេល** | ៣០នាទី |
| **វិធីសាស្ត្រ** | ការសង្ខេបម្នាក់ៗនិងក្រុមធំ |
| **សម្ភារ** | ឯកសារដែលបានព្រីន និងសំនួរតេស្តសាកល្បងមុនវគ្គនៃមេរៀនការបង្ក |
| | លក្ខណៈងាយស្រួល |

## សកម្មភាព ១៖ ការស្វាគមន៍ (១៥នាទី)

**ដំណើរការ៖**

**ជំហានទី១៖** ការស្វាគមន៍សិក្ខាកាម។

**ជំហានទី២៖** សួរសិក្ខាកាមចំនួនពីរ ឬបីនាក់ឱ្យចែករំលែកបទពិសោធន៍របស់ខ្លួននៅក្នុងការធ្វើដំណើរការមកកាន់កន្លែងបណ្តុះបណ្តាល។

## សកម្មភាព ២៖ ការណែនាំខ្លួនទៅវិញទៅមក (១៥នាទី)

**ដំណើរការ៖**

**ជំហានទី១៖** សិក្ខាកាមត្រូវបានស្នើសុំឱ្យយកក្រដាស និងប៊ិកដើម្បីគូររូបភាពដើម្បីពណ៌នាពីខ្លួនឯង (ឈ្មោះ ការងារ ចំណង់ចំណូលចិត្ត ទីកន្លែងដែលពួកគេមក ...)។

ជំហានទី២៖ ប្រាប់ឱ្យពួកគេបត់ក្រដាស ហើយមិនបង្ហាញដល់នរណាម្នាក់ឡើយ។

ជំហានទី៣៖ ប្រមូលក្រដាស ហើយដាក់គរលើគ្នានៅកណ្តាលបន្ទប់ ឬនៅលើតុ។

ជំហានទី៤៖ ប្រាប់ឱ្យសិក្ខាកាមម្នាក់ៗជ្រើសរើសក្រដាសមួយសន្លឹកនិងស្វែងរកម្ចាស់របស់ក្រដាសនោះ (ផ្លាស់ប្តូរប្រសិនបើអ្នកជ្រើសរើសចំក្រដាសខ្លួនឯង)។

ជំហានទី៥៖ ប្រាប់ឱ្យពួកគេធ្វើការពិភាក្សាគ្នាជាមួយនឹងម្ចាស់គំនូរ ហើយព្យាយាមស្វែងយល់ពីអត្ថន័យរបស់រូប គំនូរនោះនិងស្វែងយល់ពីដៃគូរបស់ពួកគេ (រួមទាំងឈ្មោះ ការងារ ទីកន្លែងដែលពួកគេមក ចំណង់ចំណូលចិត្ត)។ល។

ជំហានទី៦៖ ជាចុងក្រោយ ប្រាប់ឱ្យសិក្ខាកាមម្នាក់ៗណែនាំដៃគូរបស់ខ្លួនទៅកាន់ក្រុមធំ។

### សកម្មភាព ៣៖ ការង្កើតវិន័យក្នុងថ្នាក់រៀន (១០នាទី)

ដំណើរការ៖

ជំហានទី១៖ បែងចែកក្រុមធំទៅជាក្រុមតូចៗចំនួនពីរក្រុម។

ជំហានទី២៖ ស្នើឱ្យក្រុមទាំងនោះផ្លាស់ប្តូរអ្វីដែលជាការរំខានសំខាន់ៗ ដែលរំខានដល់ការសិក្សារបស់ពួកគេនៅក្នុងក្រុម (ក្រុមនីមួយៗចែករំលែកនូវ "រឿងល្អបំផុតដែលជាបទពិសោធន៍អាក្រក់បំផុតនៅក្នុងក្រុម")។

ជំហានទី៣៖ យល់ព្រមដើម្បីកត់ត្រាវិន័យក្នុងថ្នាក់រៀនសំខាន់ៗ វិធីសាស្ត្រតាមដានដែលបានណែនាំ និងការផាកពិន័យ (ដែលមានប្រសិទ្ធភាពនៅក្នុងអតីតកាលដើម្បីធានានូវបរិយាកាសសិក្សាដ៏ល្អប្រសើរបំផុត និងបរិយាកាសជាក្រុម)។

ជំហានទី៤៖ សង្ខេបប្រាប់ក្រុមពីវិន័យក្នុងថ្នាក់រៀន ដែលបានព្រមព្រៀងគ្នា។

### សកម្មភាព ៤៖ សេចក្តីផ្តើមអំពីការបណ្តុះបណ្តាលនិងកាលវិភាគ (១០នាទី)

ដំណើរការ៖

ជំហានទី១៖ សេចក្តីណែនាំអំពីសារៈតារនៃការបណ្តុះបណ្តាល ។

ជំហានទី២៖ លើកឡើងដោយសង្ខេបពីប្រធានបទដែលនឹងត្រូវលើកឡើង។

### សកម្មភាព ៥៖ ការរំពឹងទុក (១០ នាទី)

ដំណើរការ៖

ជំហានទី១៖ ចែករំលែកសន្លឹកកាតដល់សិក្ខាកាមទាំងអស់ និងប្រាប់ឱ្យពួកគេកត់ត្រានូវការរំពឹងទុកចំនួនបីនៅក្នុងការបណ្តុះបណ្តាលរយៈពេលពីរថ្ងៃ។

ជំហានទី២៖ បន្ទាប់ពីក្រុមបានបិទការរំពឹងទុកទាំងនោះនៅលើជញ្ជាំង ចូរផ្តល់មតិយោបល់ទៅលើការរំពឹងទុកដែលមិនអាចរំពឹងថាអាចធ្វើបាន។

## សកម្មភាព ៦៖ ការធ្វើតេស្តមុនពេលបណ្តុះបណ្តាល (៣០នាទី)

**ដំណើរការ៖**

**ជំហានទី១៖** នៅពេលផ្តល់ជូនឯកសារធ្វើតេស្តសាកល្បងមុនវគ្គបណ្តុះបណ្តាលចូរពន្យល់ថាពួកគេមានពេល៣០នាទីដើម្បីបំពេញតេស្តសាកល្បងនេះ។

**ជំហានទី២៖** ពេលវេលានៅសល់ចំនួន ១០នាទីអ្នកអាចប្រើប្រាស់ដើម្បីធ្វើការពិភាក្សាពីចម្លើយជាមួយគ្នានឹងសិក្ខាកាមនិងបញ្ជាក់ចម្លើយ ប្រសិនបើចាំបាច់។

## មេរៀន ១.២៖ ទស្សនទានគន្លឹះនៃពិការភាព (១៨០នាទី)

| | |
|---|---|
| **មេរៀន ១.២.១៖ កំណត់និយមន័យនៃកម្សោយនិងពិការភាព**<br>**មេរៀន ១.២.២៖ កត្តាហានិភ័យនាំឱ្យមានកម្សោយផ្សេងៗ**<br>**មេរៀន ១.២.៣៖ ការប្រាស្រ័យទាក់ទងនិងភាសាសមស្រប** | |
| គោលបំណង | ✓ កំណត់និយមន័យនៃកម្សោយនិងពិការភាព<br>✓ ពិភាក្សាពីកម្សោយផ្សេងៗគ្នា មូលហេតុ និងផលប៉ះពាល់នៃកម្សោយទាំងនោះ<br>✓ ស្វែងយល់ពីរបៀបប្រាស្រ័យទាក់ទងជាមួយនឹងជនមានពិការភាពនិងប្រើប្រាស់ ភាសាសមស្រប |
| រយៈពេល | ១២០នាទី |
| វិធីសាស្ត្រ | លំហាត់ ១.២.១៖ រូបភាព ស្លាកសញ្ញា និងកម្មវិធី PowerPointទី២<br>- ឆ្លុះបញ្ចាំងពីរូបភាព<br>- ការពិភាក្សាជាក្រុម<br>- ការបំផុសគំនិត ស្លាយដ៍ PowerPoint និងសំណួរចម្លើយ |
| សម្ភារ | រូបភាពមនុស្សដែលមានកម្សោយប្រភេទផ្សេងៗគ្នា រូបភាពដែលពន្យល់ពីភាពខុសៗគ្នារវាង កម្សោយ និងពិការភាព (រូបភាពទី២ខាងក្រោម)ក្រដាសផ្ទាំងធំ ហ្វឺត សន្លឹកកាតតូច ស្លាយដ៍ PowerPointទី២ ដែលមាននិយមន័យនៃពិការភាពនិងកម្សោយ ឯកសារចែកជូន១.២.១ឯកសារចែកជូន១.២.២ និងឯកសារចែកជូន១.២.៣ |
| **មេរៀន ១.២.៤៖ គំរូពិការភាព** | |
| គោលបំណង | ✓ កំណត់គំរូនៃពិការភាព |
| រយៈពេល | ៦០នាទី |

| | |
|---|---|
| វិធីសាស្ត្រ | បទបង្ហាញដោយប្រើប្រាស់កម្មវិធី PowerPoint ទី៣ លំហាត់ការពិភាក្សាជាក្រុម |
| សម្ភារ | ស្លាយដត៍ PowerPointទី៣ ឯកសារចែកជូន១.២.៤ សន្លឹកកាត ក្រដាសផ្ទាំងធំ ហ្វឹត សៀវភៅណែនាំស្តីពីការបណ្ដុះបណ្ដាល និងកំណត់សម្គាល់សម្រាប់គ្រូបង្គោល |

## មេរៀន ១.២.១៖ ការកំណត់និយមន័យនៃកម្សោយនិងពិការភាព (៦០នាទី)
## មេរៀន ១.២.២៖ កត្តាហានិភ័យនាំឱ្យមានកម្សោយផ្សេងៗ (៣០នាទី)

### លំហាត់ ១.២.១៖ រូបភាពនិងស្លាកសញ្ញា

**ដំណើរការ៖**

**ជំហានទី១៖** បែងចែកសិក្ខាកាមជាក្រុម ដែលមានសមាជិកក្រុមយ៉ាងច្រើនបំផុតត្រឹម ៥-៦នាក់

**ជំហានទី២៖** ដាក់រូបភាពដែលមានមនុស្សដែលមានកម្សោយប្រភេទផ្សេងៗគ្នា និងមនុស្សដែលគ្មានកម្សោយដែលអាចកំណត់នៅលើតារាងធំ។ ប្រាប់ឱ្យក្រុមនីមួយៗជ្រើសរើសរូបភាពមួយសន្លឹក ហើយប្រាប់ឱ្យពួកគេធ្វើការពិភាក្សាពីចំណុចដូចខាងក្រោម៖

- ✓ តើពួកគេយល់ថានៅក្នុងរូបភាពនោះគឺជាកម្សោយប្រភេទអ្វី?
- ✓ តើសមត្ថភាពប្រភេទណាដែលរងផលប៉ះពាល់ដោយសារតែកម្សោយនេះនិងនៅក្នុងស្ថានភាពណាខ្លះ?
- ✓ តើអ្វីខ្លះអាចជាមូលហេតុធ្វើឱ្យមានកម្សោយនេះ?

**ចំណុចគន្លឹះ៖** ត្រូវធ្វើយ៉ាងណាប្រាកដថាអ្នកបានជ្រើសរើសរូបភាពដែលអាចនាំឱ្យមានការការភាន់ច្រឡំដើម្បីឱ្យពួកគេចូលរួមនៅក្នុងការពិភាក្សា។

**ឧទាហរណ៍៖** កម្សោយរូបរាងកាយ/ការលំបាកក្នុងការដើរ/ជនដែលមិនអាចឈរបានយូរនៅវាលស្រែ/ជនដែលមិនអាចទៅមណ្ឌលសុខភាពដោយសារតែជណ្ដើរឡើងខ្ពស់ៗ

**ជំហានទី៣៖** ប្រាប់ឱ្យក្រុមមូលមតិគ្នាទៅលើសំណួរទាំងអស់។ ស្នើសុំឱ្យតំណាងរបស់ក្រុមនីមួយៗធ្វើបទបង្ហាញពីកម្សោយ និងមូលហេតុចម្បងនៃគំហើញដែលពួកគេបានកំណត់ និងចែករំលែកទៅកាន់ក្រុមធំ។ កត់ត្រានូវពាក្យដែលបានព្រមព្រៀងគ្នានៅលើក្រដាសផ្ទាំងធំ។

**ជំហានទី៤៖** ប្រើប្រាស់រូបភាពដើម្បីសង្ខេបមូលហេតុចម្បងនៃកម្សោយ និងការលំបាកដែលអ្នកទាំងអស់នោះប្រឈម។

**ជំហានទី៥៖** ចែករំលែកនិយមន័យនៃកម្សោយ និងប្រភេទកម្សោយតាមរយៈការបង្ហាញកម្មវិធី PowerPoint ទី២ និង PowerPoint ទី៣ព្រមទាំងផ្តល់ឧទាហរណ៍ជាក់លាក់មួយចំនួននិងភាសាសមស្របសម្រាប់កម្សោយនីមួយៗ។ សូមចែករំលែកឯកសារចែកជូន ១.២.១ និងឯកសារចែកជូន ១.២.២។

**ចំណុចគន្លឹះ៖** សូមរំឭកផងដែរថាមិនមែនគ្រប់កម្សោយទាំងអស់គឺសុទ្ធតែអាចមើលដឹងនោះទេ!

**ជំហានទី៦៖** បញ្ចប់មេរៀនកម្សោយ បន្ទាប់មកស្នើសុំសិក្ខាកាមឱ្យបញ្ចេញគំនិតយោបល់អំពីពិការភាពដោយសួរសំណួរនេះ “តើអ្នកនឹកឃើញដល់អ្វីនៅពេលអ្នកមើលឃើញ ឬស្តាប់ឮពាក្យថា ពិការភាព? ចូរកត់ត្រាពាក្យគន្លឹះនៅលើសន្លឹកកាតតូចៗ (កាតមួយ=ពាក្យគន្លឹះមួយ) បន្ទាប់មកបិទវានៅលើក្រដាសផ្ទាំងធំ (សន្លឹកកាតទាំងនេះនឹងយកមកប្រើប្រាស់ម្តងទៀតនៅមេរៀនបន្ទាប់)។

**ជំហានទី៧៖** បន្ទាប់ពីបានធ្វើបទបង្ហាញរួច សូមទុកពេលឱ្យសិក្ខាកាមសួរសំណួរ។

**ជំហានទី៨៖** ធ្វើការពិភាក្សាអំពីភាពខុសគ្នារវាងពិការភាព និងកម្សោយជាមួយសិក្ខាកាមដោយប្រើប្រាស់ការបង្ហាញខាងក្រោមដោយប្រើស្លាយដ៍PowerPointទី២។ សូមប្រាកដថាអ្នកបានពន្យល់ដោយពាក្យសម្តីអំពីអ្វីដែលមាននៅក្នុងរូបភាព ប្រសិនបើមានសិក្ខាកាមដែលមានកម្សោយគំហើញ។ ចូរពន្យល់ប្រាប់ពួកគេថារូបភាពទីមួយគឺឆ្លុះបញ្ចាំងពីស្ថានភាពអសមត្ថភាពរបស់ស្ត្រីម្នាក់ដោយប្រើរទេះរុញ។ បរិស្ថាននៅជុំវិញខ្លួនរបស់គាត់គឺមិនមានលក្ខណៈបង្កភាពងាយស្រួលដល់ជនពិការភាពឡើយ ហើយក្មេងប្រុសនៅខាងស្តាំរបស់គាត់គឺមិនបានជួយគាត់ទាល់តែសោះហើយរវក់តែនឹងការងាររបស់ខ្លួន។ រូបភាពទីពីរ បង្ហាញពីស្ត្រីម្នាក់ដែលមានកម្សោយក្នុងការបម្លាស់ទី ប៉ុន្តែដូចដែលយើងអាចឃើញហើយថាគាត់គឺជាវេជ្ជបណ្ឌិត ហើយអាចធ្វើការបាននិងចូលរួមបានពេញលេញនៅក្នុងសកម្មភាពនៅក្នុងជីវិត ដូច្នេះប្រឈមមុខនឹងពិការភាពតិចតួចណាស់។ គាត់អង្គុយនៅកន្លែងមួយដែលអាចជួយពិនិត្យសុខភាពដល់ក្មេងប្រុសបាន។ បរិស្ថានជុំវិញក៏ត្រូវបានសម្របទៅតាមតម្រូវការរបស់គាត់ផងដែរ។



រូបភាព ២៖ ភាពខុសគ្នារវាងពិការភាពនិងកម្សោយ

**ចំណុចគន្លឹះ៖** យើងទាំងអស់គ្នាគឺសុទ្ធតែអាចប្រឈមនឹងស្ថានភាពមានពិការភាពនៅពេលណាមួយក្នុងជីវិតរបស់យើង។

**ជំហានទី៩៖** ចូរអានប្រយោគខាងក្រោមម្តងមួយប្រយោគៗ ហើយសួរទៅកាន់ក្រុមធំថាតើប្រយោគទាំងនោះមានពិការភាព ឬស្ថានភាពអំណោយផល៖

- កម្សោយគំហើញ/ការលំបាកក្នុងការមើលឃើញ/កុមារដែលមានបញ្ហាក្នុងការសិក្សានៅក្នុងថ្នាក់រៀន និងមិនអាចអានអក្សរនៅក្នុងមេរៀនដោយគ្មានអក្សរប្រៃយ៍។ = ស្ថានភាពមានពិការភាព
- កម្សោយស្តាប់ / ការលំបាកក្នុងការស្តាប់ / អ្នកដែលមិនអាចទទួលបានព័ត៌មានដែលបានចែករំលែកនៅក្នុងកិច្ចប្រជុំនៅក្នុងសហគមន៍។ = ស្ថានភាពមានពិការភាព
- កម្សោយរូបរាងកាយ/ការលំបាកនៅក្នុងកាន់ទម្ងន់/ស្ត្រីមិនអាចរៀបអាពាហ៍ពិពាហ៍ ដោយសារតែគ្រួសាររបស់គាត់និយាយថា គ្រួសាររបស់គាត់និយាយថាគាត់នឹងមិនអាចថែទាំផ្ទះសម្បែង និងកូនរបស់ខ្លួន។ = ស្ថានភាពមានពិការភាព
- កុមារដែលពិការភ្នែកត្រូវបានដាក់បញ្ចូលឱ្យចូលរួមនៅក្នុងសាលារៀនដែលកុមារបានទទួលការគាំទ្រពីគ្រូបង្រៀននិងប្រើប្រាស់ឧបករណ៍ពិសេសដូចជាក្បាច់គិតលេខ។ = ស្ថានភាពអំណោយផល
- បុរសម្នាក់ដែលខ្សោយសតិបញ្ញាធ្វើការងារនៅសណ្ឋាគារ ហើយគាត់ត្រូវបានតែងតាំងឱ្យធ្វើការងារសាមញ្ញៗ និងគាត់ត្រូវបានជួយគាំទ្រពីមិត្តរួមការងារដែលអាចជួយរំឭកគាត់អំពីរបៀបអនុវត្តការងារ និងអាចគ្រប់គ្រងម៉ោងបំពេញការងាររបស់គាត់ជាដើម។ = ស្ថានភាពអំណោយផល
- បុរសដែលប្រើប្រាស់រទេះរុញបន្ទាប់ពីបានជួបគ្រោះថ្នាក់។គាត់គឺជាអ្នកលក់បន្លែនៅផ្សារនៅមុនពេលដែលគាត់មានគ្រោះថ្នាក់។ផ្សារមានទីតាំងនៅឆ្ងាយពីភូមិនិងស្ថិតនៅជាន់ទីមួយ។=ស្ថានភាពមានពិការភាព
- ស្ត្រីចំណាស់ម្នាក់មានជំងឺដាច់សរសៃឈាមក្នុងខួរក្បាល ហើយបន្ទាប់ពីមានជំងឺនេះរួចមក គាត់មានការលំបាកក្នុងការបម្លាស់ទី។ ពីមុនគាត់ធ្លាប់តែទៅលេងនៅសួនច្បារក្នុងសហគមន៍ជាប្រចាំ។ កូនប្រុសរបស់គាត់មានម៉ូតូមួយគ្រឿង ហើយឥឡូវនេះកូនប្រុសរបស់គាត់ឌុបគាត់ទៅលេងសួនច្បារជារៀងរាល់ថ្ងៃ។សួនច្បារក្នុងតំបន់ គឺងាយស្រួលក្នុងការចេញចូល ដោយសារតែគ្មានកាំជណ្តើរនោះទេ។ អាជ្ញាធរមូលដ្ឋានបានផ្តល់កន្លែងអង្គុយសម្រាកជាច្រើនដែលមានកៅអីអង្គុយនៅតាមបណ្តោយផ្លូវសួនច្បារនោះ ហើយគាត់អាចសម្រាកនិងអង្គុយមើលទេសភាពនិងសកម្មភាពកីឡាផ្សេងៗនៅក្នុងសួនច្បារបាន។ = ស្ថានភាពអំណោយផល

## មេរៀន ១.២.៣៖ ការប្រាស្រ័យទាក់ទងនិងភាសាសមស្រប (៣០នាទី)

**ដំណើរការ៖**

**ហ្គេម "GOSSIP"**

ជំហានទី ១៖ ប្រាប់ឱ្យសិក្ខាកាមក្រោកឈរឡើង ឬអង្គុយជាជួរ ឬជារង្វង់។

ជំហានទី ២៖ បន្ទាប់មកនិទានរឿងខ្លីមួយដែលមានប្រហែល ៣-៤ ប្រយោគទៅកាន់អ្នកនៅក្នុងជួរ។

ជំហានទី ៣៖ រួចប្រាប់ឱ្យពួកគេខ្សឹបដោយប្រាប់សាច់រឿងនោះទៅកាន់អ្នកអង្គុយជិតបន្ទាប់ទៀត ហើយឱ្យអ្នកបន្ទាប់និយាយប្រាប់តៗគ្នានៅក្នុងជួរជាមួយគ្នា។

ជំហានទី ៤៖ អ្នកចុងក្រោយនឹងប្រាប់សាច់រឿងដែលគាត់បានស្តាប់ឮ ហើយវាយតម្លៃជាមួយក្រុមថាតើសាច់រឿងនោះមានការផ្លាស់ប្តូរច្រើនដែរឬទេ? សង្ខេបដោយប្រាប់មតិត្រឡប់ពីហ្គេមនេះ។

ជំហានទី ៥៖ ដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងជនមានពិការភាព ជាការសំខាន់ដែលត្រូវប្រើប្រាស់ភាសាសមស្រប។សូមមើលឯកសារចែកជូន១.២.១និងធ្វើបទបង្ហាញកម្មវិធីPowerPointទី៤។

ជំហានទី៦៖ បន្ទាប់ពីធ្វើបទបង្ហាញរួច ធ្វើការបែងចែកកាតលឿងដែលមានអក្សរថា "មនុស្សដំបូង ..."ប្រាប់ឱ្យសិក្ខាកាមចេញកាតលឿង (ដូចជានៅក្នុងបាល់ទាត់ដែរ) ប្រសិនបើសមាជិកណាម្នាក់ ឬគ្រូបង្គោលប្រើប្រាស់ភាសាពិការភាពមិនសមស្របក្នុងសិក្ខាសាលា។ល។

ជំហានទី ៧៖ បន្ទាប់ពីរៀនមេរៀនអំពីភាសាសមស្រប និងវិធីប្រាស្រ័យទាក់ទងជាមួយជនមានពិការភាព អ្នកអាចធ្វើការពិភាក្សាអំពីកាតលឿងដែលត្រូវបានចេញជូន។ តើហេតុអ្វីបានជាពួកគេចេញកាតនេះជាតើភាសាមិនសមស្របពិតជាត្រូវបានប្រើប្រាស់ ហើយតើវិធីប្រាស្រ័យទាក់ទងត្រឹមត្រូវដែលបានប្រើប្រាស់គឺជាអ្វី? សូមលើកឡើងផងដែរថា នៅក្នុងការបណ្តុះបណ្តុះនេះយើងទាំងអស់គ្នាសុទ្ធតែរៀនសូត្រជាមួយគ្នានិងចង់ជួយគ្នាទៅវិញទៅមកឱ្យដឹងច្បាស់លាស់អំពីជម្រើសភាសារដែលយើងបានប្រើប្រាស់។

**ចំណុចគន្លឹះ៖** សូមបញ្ជាក់ថាធនធាននេះគឺមិនមែនអំពីការវិនិច្ឆ័យនោះទេ ប៉ុន្តែគឺដើម្បីជួយឱ្យយើងទាំងអស់គ្នារៀនសូត្រជាមួយគ្នា។

## មេរៀន ១.២.៤៖ គំរូពិការភាព (៦០នាទី)

ដើម្បីរៀបចំសកម្មភាពនេះ អ្នកត្រូវការឯកសារចែកជូន១.២.៤ ដែលមានព័ត៌មានអំពីគំរូនៃពិការភាព។

**ដំណើរការ៖**

ជំហានទី ១៖ ប្រើប្រាស់ព័ត៌មាននៅក្នុងឯកសារចែកជូននេះដើម្បីចាប់ផ្តើមមេរៀន ដោយធ្វើការពន្យល់ពីប្រវត្តិនៃចលនាពិការភាព និងរបៀបដែលពិការភាពត្រូវបានគេដឹង ព្រមទាំងពន្យល់ពីរបៀបដែលវាវិវត្តផងដែរ ដោយធ្វើតាមឯកសារចែកជូន។ បង្ហាញស្លាយដ៍ PowerPointទី៣ បន្ទាប់មកពន្យល់អំពីគំរូនៃពិការភាពផ្សេងៗគ្នា។ ឧទាហរណ៍៖ គំរូសប្បុរសធម៌ គំរូវេជ្ជសាស្ត្រ និងគំរូសង្គម និងភាពខុសគ្នារវាងគំរូទាំងនេះនៅក្នុងវិធីសាស្ត្រមួយដែលមានការចូលរួម។

ជំហានទី ២៖ សួរទៅកាន់សិក្ខាកាមថាតើនៅក្នុងសហគមន៍របស់យើងពិការភាពត្រូវបានយល់ឃើញយ៉ាងដូចម្តេច ហេតុអ្វី? បង្ហាញប្រាប់សិក្ខាកាមថាពួកគេនឹងទទួលបានឯកសារចែកជូននៅពេល

ក្រោយដើម្បីឱ្យពួកគេអាចផ្តោតអារម្មណ៍កាន់តែខ្លាំងទៅលើការចូលរួម។

**ជំហានទី ៣៖** ស្នើសុំឱ្យក្រុមនីមួយៗ (ក្រុមដដែលនៅក្នុងលំហាត់ទី១.២.១) ដាក់កាត (កាតព័ត៌មានដែលបានបង្កើតឡើងក្នុងជំហានទី៦នៃលំហាត់១.២.១ (កាតព័ត៌មានអំពីអ្វីពួកគេនឹកឃើញនៅពេលដែលពួកគេបានមើលឃើញ ឬស្តាប់ឮពាក្យពិការភាព) នៅក្រោមចំណងជើងគំរូវេជ្ជសាស្ត្រ គំរូសប្បុរសធម៌ គំរូសង្គម និងគំរូផ្អែកលើ សិទ្ធិនៅលើក្រដាសផ្ទាំងធំទៅតាមអ្វីដែលពួកគេយល់ឃើញថាមានភាពសមស្រប។ ក្រុមនីមួយៗគួរតែពន្យល់ដល់ក្រុមធំអំពីមូលហេតុដែលពួកគេដាក់កាតរបស់ពួកខ្លួននៅក្រោមចំណងជើងជាក់លាក់របស់ខ្លួន។ លើកទឹកចិត្តឱ្យសិក្ខាកាមសួរសំណួរទៅកាន់ក្រុមផ្សេងទៀតអំពីជម្រើសដែលពួកគេបានជ្រើសរើស។

**ជំហានទី ៤៖** សង្កត់ធ្ងន់ទៅលើគំរូពិការភាពសង្គមនិងវិធីសាស្ត្រផ្អែកលើសិទ្ធិ។ ចូរពិភាក្សាឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតទៅលើសំណួរពីក្រុមនីមួយៗ និងកំណត់ឧបសគ្គនានាដែលជនមានពិការភាពបានប្រឈមដោយយោងតាមគំរូពិការភាពសង្គម។ បន្ទាប់មកប្រមូលចម្លើយរបស់សិក្ខាកាមអំពីឧបសគ្គហើយបែងចែកចម្លើយទាំងនោះជាបីក្រុមពោលគឺក្រុមបរិស្ថានរូបវន្ត ឥរិយាបថ និងស្ថាប័ន។

## ការពន្យល់អំពីឧបសគ្គដែលជនមានពិការភាពជួបប្រទះ៖

✓ ឧបសគ្គបរិស្ថានរូបវន្ត៖ អគារ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តផ្សេងៗដែលមិនបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពនិង/ឬប្រព័ន្ធផ្តល់ព័ត៌មានឬការប្រាស្រ័យទាក់ទង។ ឧទាហរណ៍៖ សាលារៀន បង្គន់សាធារណៈ បន្ទប់ទឹក មណ្ឌលសុខភាពដែលមិនបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព កង្វះស្លាកសញ្ញានិងព័ត៌មានដែលអាចទទួលយកបាន។ល។



រូបភាព ៣៖ ស្ត្រីម្នាក់ជិះរទេះរុញមិនអាចចេញចូលសាលាឃុំបានដោយសារតែពុំមានជម្រាលសម្រាប់ឡើង

- ✓ ឧបសគ្គសង្គមនិងវប្បធម៌៖ បុរេវិនិច្ឆ័យ ការរើសអើង និងការមាក់ងាយបង្កឱ្យមានបញ្ហាយ៉ាងធំបំផុតសម្រាប់ជនមានពិការភាពដែលត្រូវបានគេសន្មត់ថាអសមត្ថភាពត្រូវការការព្យាបាល ពឹងផ្អែកលើអ្នកដទៃនិងមានបញ្ញាទាបជាដើម។ ឧទាហរណ៍៖ ឥរិយាបថអវិជ្ជមានពីអ្នកជិតខាងនៅក្នុងសហគមន៍ អាជ្ញាធរមូលដ្ឋាន/អ្នកផ្តល់សេវាកំពុងតែនាំឱ្យមានអបរិយាបន្ននិងការរើសអើង។



រូបភាព ៤៖ ម៉ូតូមួយគ្រឿងបានចតដោយអ្នកផ្សេងទៀតនៅខាងមុខជម្រាលដែលបាំងផ្លូវស្ត្រីជិះរទេះរុញក្នុងការចូលទៅកាន់ភោជនីយដ្ឋាន

- ✓ ឧបសគ្គបែបស្ថាប័ន៖ ការអនុត្តច្បាប់គោលនយោបាយ ដំណើរការ វប្បធម៌ និងស្ថាប័នសង្គម និងប្រព័ន្ធឬការអនុវត្តគោលនយោបាយមិនបានធានានូវសិទ្ធិស្មើភាពរបស់ជនមានពិការភាពឡើយ។



រូបភាព ៥៖ រូបភាពបង្ហាញពីក្របខណ្ឌច្បាប់

**ជំហានទី ៥៖** ពន្យល់ពីភាពខុសគ្នារវាងគំរូពិការភាពដល់សិក្ខាកាមដោយសារតែទម្រង់ទាំងនេះនឹងជះឥទ្ធិពលដល់របៀបយល់នៃការយល់ដឹងអំពីពិការភាពនិងរបៀបការស្វែងរកមតិគាំទ្រដើម្បីដាក់បញ្ចូលពីការភាពនៅក្នុងដំណើរការនៃការអភិវឌ្ឍ។ ពួកគេគួរតែយល់ដឹងថាគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ (CRPD) គឺផ្អែកទៅលើគំរូពិការភាពសង្គម។

**ចំណុចត្រូវចងចាំ៖** ចំណុចដ៏សំខាន់មួយដែលត្រូវចែករំលែកឱ្យសិក្ខាកាមបានដឹងថា ពេលខ្លះអាចមានការលំបាកក្នុងការបែងចែកឱ្យបានច្បាស់លាស់ពីភាពខុសគ្នារវាងគំរូពិការភាព និងវិធីសាស្ត្រខុសៗគ្នា។ ឧទាហរណ៍ តម្រូវការ "រទេះរុញ" អាចត្រូវបានគេចាត់ទុកថាជាវិធីសាស្ត្រខាងវេជ្ជសាស្ត្រ ពីព្រោះតែវាផ្តោតលើមនុស្សដែលមានពិការភាព និង "ភាពអសមត្ថភាព" របស់ពួកគេនៅក្នុងការដើរ។ ទោះជាយ៉ាងណាក៏ដោយ តម្រូវការនេះក៏អាចសំដៅដល់វិធីសាស្ត្រគំរូសង្គមដែរ ប្រសិនបើវិធីសាស្ត្រនេះមានទាក់ទងនឹងលុបបំបាត់ឧបសគ្គបរិស្ថាន តាមរយៈការផ្តល់ភាពអង់អាចដល់បុគ្គលណាម្នាក់ឱ្យធ្វើការបម្លាស់ទីពីចំណុចក ទៅ ចំណុចខ ដូច្នេះអាចនឹងបង្កើនការចូលរួមរបស់ពួកគេ។ អាស្រ័យហេតុនេះ ចូរលើកទឹកចិត្តឱ្យសិក្ខាកាមគិតពីអត្ថន័យនៅពីក្រោយពាក្យទាំងនោះ ហើយខណៈពេលនោះ មិនត្រូវចូលរួមនៅក្នុងទឡ្ហីករណ៍គ្មានផលិតភាពឡើយ។

ក្នុងដំណើរការអភិវឌ្ឍន៍នេះ គំរូសង្គមគឺមានន័យថាត្រូវយកបញ្ហានិងបំណងប្រាថ្នារបស់ជនមានពិការភាពមកធ្វើការពិចារណានៅគ្រប់ដំណាក់កាលទាំងអស់នៃវដ្តគម្រោង។នេះគឺជាបញ្ហាអន្តរវិស័យដែលមានជាប់ពាក់ព័ន្ធជាមួយភាគីពាក់ព័ន្ធដែលជាដៃគូអភិវឌ្ឍន៍ឯកជននិងសាធារណៈទាំងអស់។ ការបញ្ជ្រាបការលើកកម្ពស់ការយល់ដឹងនិងការបញ្ចុះបញ្ចូលគឺជាយុទ្ធសាស្ត្រគន្លឹះនៅក្នុងការលើកកម្ពស់ឋានៈតួនាទីរបស់ជនមានពិការភាពនៅក្នុងសង្គម។

**ចប់ម៉ូឌុលទីមួយ!**

| ម៉ូឌុលទីពីរ៖ សេចក្តីផ្តើមអំពីការបង្កលក្ខណៈងាយស្រួល ការកំណត់និយមន័យនិងក្របខណ្ឌច្បាប់ (១២០នាទី) | |
|---|---|
| **មេរៀន ២.១៖ កំណត់អត្ថន័យនៃការបង្កលក្ខណៈងាយស្រួល** | |
| គោលបំណង | នៅពេលបញ្ចប់មេរៀនបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាច៖<br>✓ យល់ដឹងអំពីអត្ថន័យនៃការបង្កលក្ខណៈងាយស្រួល |
| រយៈពេល | ៣០នាទី |
| វិធីសាស្ត្រ | លំហាត់២.១ ពេញអង្គ៖ បាល់និយមន័យ និងបទបង្ហាញ |
| សម្ភារ | ✓ សៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាលស្តីពីការបង្កលក្ខណៈងាយស្រួល–កំណត់សម្គាល់សម្រាប់គ្រូបង្គោល ឯកសារចែកជូន ២.១<br>✓ បាល់<br>✓ ស្លាយដ៍ PowerPoints ទី៤ ដែលមាននិយមន័យនិងព័ត៌មានសំខាន់ៗ |
| **មេរៀន ២.២៖ ហេតុអ្វីបានជាការបង្កលក្ខណៈងាយស្រួលមានសារៈសំខាន់?** | |
| គោលបំណង | នៅពេលបញ្ចប់មេរៀនបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាច៖<br>✓ យល់ដឹងពីសារៈសំខាន់នៃការបង្កលក្ខណៈងាយស្រួលនិងមូលហេតុដែលវាមានសារៈសំខាន់នៅក្នុងការផ្តល់ជូនក្រុមងាយរងគ្រោះជាពិសេសជនមានពិការភាពនូវបរិស្ថានដែលបានកសាងឡើងដោយបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាពពេញលេញ |
| រយៈពេល | ៣០នាទី |
| វិធីសាស្ត្រ | ការងារជាក្រុម ការពិភាក្សាពេញអង្គ សំណួរនិងចម្លើយ |
| សម្ភារ | ស្លាយដ៍ PowerPoint ទី៤ ឯកសារចែកជូន២.៣ សៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាល |
| **មេរៀន ២.៣៖ ក្របខណ្ឌច្បាប់បង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព** | |
| គោលបំណង | នៅពេលបញ្ចប់មេរៀនបណ្តុះបណ្តាលនេះសិក្ខាកាមនឹង៖<br>✓ យល់ដឹងពីក្របខ័ណ្ឌថ្នាក់ជាតិនិងអន្តរជាតិដែលពាក់ព័ន្ធការបង្កលក្ខណៈងាយស្រួលនិងភាពចាំបាច់នៅក្នុងលើកកម្ពស់និងពង្រឹងក្របខណ្ឌទាំងនេះ |
| រយៈពេល | ៤៥នាទី |
| វិធីសាស្ត្រ | កិច្ចពិភាក្សាពេញអង្គ និងបទបង្ហាញ ការពិភាក្សាជាក្រុមទៅសំណួរមួយចំនួន |
| សម្ភារ | ✓ សៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាលស្តីពីការបង្កលក្ខណៈងាយស្រួល<br>✓ សេចក្តីសង្ខេបអំពីខ្លឹមសារជំពូកអំពីការបង្កលក្ខណៈងាយស្រួលនៅក្នុងច្បាប់ស្តីពីពិការភាពកម្ពុជា (ច្បាប់ឆ្នាំ២០០៩)<br>✓ សេចក្តីសង្ខេបអំពីខ្លឹមសារជំពូកអំពីការបង្កលក្ខណៈងាយស្រួលនៅក្នុង*អនុសញ្ញាស្តីពីសិទ្ធិជនពិការ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព យុទ្ធសាស្ត្រអ៊ីនឈាន់* (ឆ្នាំ២០១២)<br>✓ ប្រអប់ ស្លាយដ៍ PowerPoint ទី៥ បទបង្ហាញ ឯកសារចែកជូន២.៣<br>✓ កាត់សំណួរដែលបានរៀបចំក្រដាសផ្ទាំងធំនិងហ្វឺត |

| មេរៀន ២.៤៖ របៀបលើកកម្ពស់ការបង្កលក្ខណៈងាយស្រួល ? | |
|---|---|
| គោលបំណង | នៅពេលបញ្ចប់មេរៀនបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាច៖<br>✓ លើកកម្ពស់ការបង្កលក្ខណៈងាយស្រួលតាមរយៈវិធានការផ្សេងៗគ្នា |
| រយៈពេល | ៤៥នាទី |
| វិធីសាស្រ្ត | ការពិភាក្សាពេញអង្គ និងបទបង្ហាញ ការពិភាក្សាជាក្រុមអំពីសំណួរមួយចំនួន |
| សម្ភារ | ✓ សៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាលស្តីពីការបង្កលក្ខណៈងាយស្រួល<br>✓ ប្រអប់ លំហាត់២.៣ និងឯកសារចែកជូន២.៣ ស្លាយដ៍ PowerPoint ទី៥<br>✓ កាត់សំណួរដែលបានរៀបចំ ក្រដាសផ្ទាំងធំ និងហ្វឺត |

## មេរៀន ២.១៖ កំណត់អត្ថន័យនៃការបង្កលក្ខណៈងាយស្រួល (៣០នាទី)

ប្រើប្រាស់លំហាត់២.១ និងឯកសារចែកជូន២.១ ដើម្បីសម្របសម្រួលមេរៀននេះនិងពន្យល់អំពីអត្ថន័យនៃការបង្កលក្ខណៈងាយស្រួល។

### លំហាត់ ២.១៖ បាល់និយមន័យ

**ដំណើរការ៖**

**ជំហានទី ១៖** នៅមុនពេលចូលដល់ចំណុចលម្អិត សូមពន្យល់ពីសារៈសំខាន់នៅក្នុងការយល់ដឹងអំពីអត្ថន័យនៃការបង្កលក្ខណៈងាយស្រួល។

**ជំហានទី ២៖** ប្រាប់សិក្ខាកាមឱ្យឈរជារង្វង់និងយកបាល់។ ចោលបាល់ទៅកាន់ម្នាក់នៅក្នុងចំណោមពួកគេ ហើយប្រាប់អ្នកដែលទទួលបាល់បាននូវសំណួរមួយក្នុងចំណោមខាងក្រោម៖ តើអ្វីទៅគឺជាការបង្កលក្ខណៈងាយស្រួល? តើអ្នកនឹងកំណត់និយមន័យនៃការបង្កលក្ខណៈងាយស្រួលយ៉ាងដូចម្តេច? តើនិយមន័យនេះអនុវត្តនៅពេលណា? តើនរណាអាចទទួលអត្ថប្រយោជន៍ពីការបង្កលក្ខណៈងាយស្រួល?ជាការពិតណាស់ អ្នកអាចបន្ថែមសំណួរច្រើនតាមដែលអ្នកចង់។

**ជំហានទី ៣៖** បន្ទាប់ពីបុគ្គលនោះឆ្លើយនឹងសំណួរ គាត់នឹងបោះបាល់ទៅកាន់សិក្ខាកាមផ្សេងទៀត ដែលត្រូវផ្តល់ឧទាហរណ៍រឹងមាំដែលបង្ហាញចម្លើយ។ បន្ទាប់មកយកបាល់ត្រលប់មកវិញ រួចគប់បាល់ទៅកាន់អ្នកផ្សេងទៀតសម្រាប់សំណួរបន្ទាប់។

**ជំហានទី ៤៖** ប្រាប់សិក្ខាកាមឱ្យសរសេរពាក្យគន្លឹះដែលបានលើកឡើងនៅក្នុងជំហានទី២ នៅលើក្រដាសផ្ទាំងធំ / ក្តារខៀន។

**ជំហានទី ៥៖** សង្ខេបលទ្ធផលឡើងវិញជាមួយក្រុម។

**ជំហានទី ៦៖** កំណត់និយមន័យនៃការបង្កលក្ខណៈងាយស្រួល (តើនិយមន័យនេះដើម្បីអ្វី? តើនៅក្នុងនោះមានបញ្ចូលអ្វីខ្លះ? តើនិយមន័យនេះអនុវត្តនៅកន្លែងណាខ្លះ? និងអនុវត្តចំពោះនរណាខ្លះ?) បន្ទាប់មកបង្ហាញនិយមន័យនៃការបង្កលក្ខណៈងាយស្រួលតាមរយៈស្លាយដ៍ PowerPointទី៤ និងផ្តល់ឯកសារចែកជូន២.១។

## មេរៀន ២.២៖ ហេតុអ្វីបានជាការបង្កលក្ខណៈងាយស្រួលមានសារៈសំខាន់? (៣០នាទី)

ដំណើរការ៖

**ជំហានទី ១៖** បំផុសគំនិតជាមួយនឹងសិក្ខាកាមនូវសំណួរដូចខាងក្រោម៖

- ហេតុអ្វីបានជាការផ្តល់បរិស្ថានសាងសង់ ដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពឱ្យបានពេញលេញជូនក្រុមងាយរងគ្រោះ ជាពិសេស ជនមានពិការភាព គឺជាការសំខាន់?
- តើមានចំណុចអ្វីខ្លះដែលអាចធ្វើដើម្បីកែលម្អការបង្កលក្ខណៈងាយស្រួលនៃបរិស្ថានដែលបានសាងសង់?

**ជំហានទី ២៖** កត់ត្រាពាក្យគន្លឹះនៅលើក្រដាសផ្ទាំងធំ បន្ទាប់មក បង្ហាញស្លាយដ៍ PowerPoint ទី ៤

## មេរៀន ២.៣៖ ក្របខណ្ឌច្បាប់អំពីការបង្កលក្ខណៈងាយស្រួល (៤៥នាទី)
## មេរៀន ២.៤៖ តើត្រូវលើកកម្ពស់ការបង្កលក្ខណៈងាយស្រួលយ៉ាងដូចម្ដេចខ្លះ? (៤៥នាទី)

ប្រើប្រាស់ឯកសារចែកជូន ២.៣ និងលំហាត់ ២.៣ ដើម្បីសម្របសម្រួលមេរៀននេះ។

### លំហាត់ ២.២៖ ប្រអប់សំណួរ

**ចំណុចគន្លឹះ៖** សង្ខេបខ្លីនិងលើកចំចំណុចសំខាន់! ចំណាយពេលយ៉ាងច្រើនត្រឹម៥នាទីក្នុងមួយសំណួរ ត្រូវមានភាពយ៉ាងរហ័សនិងសប្បាយរីករាយ!

**ជំហានទី ១៖** រៀបចំសំណួរមួយចំនួន និងដាក់សំណួរទាំងនោះនៅក្នុងប្រអប់។

គំរូសំណួរ៖

១. តើអ្នកមានស្គាល់ច្បាប់/បទប្បញ្ញត្តិអន្តរជាតិណាមួយដែលលើកឡើងអំពីការបង្កលក្ខណៈងាយស្រួលដែរឬទេ? តើច្បាប់ឬបទប្បញ្ញត្តិទាំងនោះលើកឡើងអ្វីខ្លះអំពីការបង្កលក្ខណៈងាយស្រួល?
២. តើមានឯកសារអ្វីខ្លះដែលត្រូវបានអនុម័តនៅក្នុងប្រទេសកម្ពុជាដើម្បីលើកកម្ពស់ និងអនុវត្តការបង្កលក្ខណៈងាយស្រួល?
៣. ហេតុអ្វីបានជាការបង្កលក្ខណៈងាយស្រួលមានសារៈសំខាន់?
៤. ហេតុអ្វីបានជាការផ្តល់បរិស្ថានសាងសង់ដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពឱ្យបានពេញលេញជូនក្រុមងាយរងគ្រោះជាពិសេសជនមានពិការភាពគឺជាការសំខាន់?
៥. តើត្រូវលើកកម្ពស់ការបង្កលក្ខណៈងាយស្រួលឱ្យកាន់តែមានប្រសិទ្ធភាពយ៉ាងដូចម្ដេច?

**ជំហានទី ២៖** យកប្រអប់ហើយដើរជុំវិញនៅក្នុងថ្នាក់រៀនរួចប្រាប់ឱ្យសិក្ខាកាមជ្រើសយកសំណួរមួយ។

**ជំហានទី ៣៖** ប្រាប់សិក្ខាកាមនោះឱ្យអានសំណួរនោះឱ្យឮ (ប្រសិនបើគាត់មិនចេះអាន សូមស្នើសុំឱ្យអ្នកអង្គុយជិតជួយអាន) រួចផ្តល់ចម្លើយ។

**ជំហានទី ៤៖** ប្រសិនបើសិក្ខាកាមមិនដឹងចម្លើយ គាត់អាចផ្តល់កាតសំណួរនោះជូនសិក្ខាកាមផ្សេងទៀត។

**ជំហានទី ៥៖** អញ្ជើញសិក្ខាកាមផ្សេងទៀតឱ្យសរសេរពាក្យគន្លឹះនៃសំណួរនីមួយៗនៅលើក្រដាសផ្ទាំងធំ។

**ជំហានទី ៦៖** សង្ខេបឡើងវិញនូវពាក្យគន្លឹះដែលបានផ្តល់ជូនដោយសិក្ខាកាម

**ជំហានទី ៧៖** លើកឡើងដោយសង្ខេបនូវប្រការស្ដីពីការបង្កលក្ខណៈងាយស្រួលដោយប្រើប្រាស់ឯកសារចែកជូន ២.៣ និងស្លាយដ៍ PowerPoint ទី៥។

- ➢ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) លេខ ១១៖ កសាងទីក្រុងនិងលំនៅដ្ឋានរបស់មនុស្សប្រកបដោយបរិយាបន្ន សុវត្ថិភាព ធន់ និងចីរភាព
- ➢ ច្បាប់ជាតិកម្ពុជា៖ ជំពូក៥
- ➢ អនុសញ្ញាស្តីពីសិទ្ធិជនពិការ៖ មាត្រា៩ ស្តីពីការបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព
- ➢ យុទ្ធសាស្រ្តអ៊ីឈាន់ (គោលដៅ៣៖ កែលម្អការបង្កលក្ខណៈងាយស្រួលទៅកាន់ បរិស្ថានរូបវន្ត ការដឹកជញ្ជូនសាធារណៈ ចំណេះដឹង ព័ត៌មាននិងការប្រាស្រ័យទាក់ទង)
- ➢ "ស្តង់ដារបច្ចេកទេសនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។" និងអនុក្រឹត្យពាក់ព័ន្ធផ្សេងទៀត។

**ជំហានទី ៨៖** បង្ហាញជំហានទាំង៦អំពីរបៀបលើកកម្ពស់ការបង្កលក្ខណៈងាយស្រួលដោយប្រើប្រាស់ស្លាយដ៍ PowerPointទី៥ (១/ការចូលរួមសកម្មរបស់ជនមានពិការភាព ២/ព័ត៌មាននិងការលើកកម្ពស់ការយល់ដឹង ៣/ ការរៀបចំផែនការ ៤/ ការបណ្តុះបណ្តាល ៥/ ការប្រាស្រ័យទាក់ទង ៦/ ការតាមដាន។

ចូរប្រាប់សិក្ខាកាមឱ្យផ្តល់ឧទាហរណ៍រឹងមាំអំពីរបៀបដែលពួកគេអនុវត្តជំហាននីមួយៗនៃជំហានទាំង៦។

**ចប់ម៉ូឌុលទីពីរ!**

| ម៉ូឌុលទីបី ៖ ការបង្កលក្ខណៈងាយស្រួល-គោលការណ៍ (១៥០នាទី) | |
|---|---|
| **មេរៀន ៣.១៖ គោលការណ៍ RECU** | |
| គោលបំណង | នៅពេលបញ្ចប់មេរៀនបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាច៖<br>✓ យល់ដឹងអំពីខ្សែច្រវាក់នៃគោលការណ៍បម្លាស់ទី<br>✓ យល់ដឹងអំពីអត្ថន័យរឹងមាំនៃគោលការណ៍ RECU<br>✓ កំណត់ទីតាំងដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព និងដែលមិនបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព |
| រយៈពេល | ៦០នាទី |
| វិធីសាស្រ្ត | ការពិភាក្សាពេញអង្គ លំហាត់៣.១៖ គោលការណ៍ RECU និងបទបង្ហាញ និងឯកសារចែកជូន៣.១ |
| សម្ភារ | ✓ រូបភាពអំពីស្ថានភាពផ្សេងៗគ្នា មនុស្ស ភូមិ/ទីក្រុង ដែលផ្សារភ្ជាប់ទៅរកការបង្កលក្ខណៈងាយស្រួល និងលើកឡើងអំពីជំហានមួយចំនួននៃគោលការណ៍ RECU (ចូលដល់ ចូល ចរាចរ ប្រើប្រាស់) ក្រដាសផ្ទាំងធំ ហ្វឺត និងស្កុត<br>✓ ស្លាយដ៍ PowerPoint ទី៦ និងLCD<br>✓ វីដេអូគំនូរជីវចលដែលបង្ហាញបញ្ហានៃការបង្កលក្ខណៈងាយស្រួល ដែលពាក់ព័ន្ធនឹងចូលដល់ ចូល ចរាចរ ប្រើប្រាស់ និងបង្ហាញពីរបៀបដែលស្តង់ដារការងារបច្ចេកទេសនៃការបង្កលក្ខណៈងាយស្រួលដើម្បីធ្វើឱ្យការរចនាកាន់តែមានភាពបរិយាបន្នកាន់តែច្រើនឡើង។ |
| **មេរៀន ៣.២៖ ការរចនាជាសកលនិងការសម្របសម្រួលសមស្រប** | |
| គោលបំណង | នៅពេលបញ្ចប់មេរៀនបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាច៖<br>✓ ពន្យល់ពីគោលការណ៍គន្លឹះនៃការរចនាប្លង់ជាសកល។<br>✓ ស្វែងយល់អំពីអត្ថន័យនៃការសម្របសម្រួលសមស្របនិងរបៀបអនុវត្តវានៅក្នុងបរិស្ថានការងារ។ |

| | |
|---|---|
| រយៈពេល | ៩០នាទី |
| វិធីសាស្ត្រ | បទបង្ហាញ និងការពិភាក្សាពេញអង្គ ការងារជាក្រុម លំហាត់៣.២ ការរចនាជាសកលនិងការសម្របសម្រួលសមស្រប |
| សម្ភារ | សៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាលស្តីពីការបង្កលក្ខណៈងាយស្រួលស្លាយដ៍ PowerPoint ទី៦ ឯកសារចែកជូនអំពីលំហាត់៣.២ សៀវភៅណែនាំស្តីពីការបណ្តុះបណ្តាល ឯកសារសារាចរណ៍០០៥[១]៖ ការសម្របសម្រួលសមស្របនៅកន្លែងធ្វើការ។ក្រដាសផ្ទាំងធំ ហ្វឺត ឧបករណ៍សំឡេង ប្រអប់ រូបភាព ការរចនាប្លង់ជាសកល និង LCD។ |

## មេរៀន ៣.១៖ គោលការណ៍ RECU (៦០នាទី)

### លំហាត់ ៣.១៖ គោលការណ៍ RECU

**ដំណើរការ៖**

**ជំហានទី ១៖** បង្ហាញស្លាយដ៍ PowerPoint ទី៦ អំពីគោលការណ៍ RECU និងពន្យល់ពីខ្សែច្រវាក់ជាប់នៃគោលការណ៍បម្លាស់ទី។

**ជំហានទី ២៖** ចែករូបភាពអំពីជំហានផ្សេងៗគ្នានៃគោលការណ៍ RECU ដោយបង្ហាញពីស្ថានភាពនៃការបង្កលក្ខណៈងាយស្រួលពេញលេញ ការបង្កលក្ខណៈងាយស្រួលមានកម្រិតកំណត់ និងការគ្មានការបង្កលក្ខណៈងាយស្រួល នៅលើតារាង ឬនៅលើកម្រាល។

**ជំហានទី ៣៖** បែងចែកជាក្រុមមានគ្នាបីនាក់ (សមាជិក ៣នាក់នៅក្នុងមួយក្រុម)

**ជំហានទី ៤៖** ទុកពេលឱ្យក្រុមនីមួយៗចំនួន១០នាទីដើម្បីជ្រើសរើសរូបភាពចំនួន២សន្លឹក ដោយបង្ហាញពីបរិស្ថានដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពនិងរូបភាពពីរសន្លឹកផ្សេងទៀត ដែលបង្ហាញពីបរិស្ថានមិនបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព បន្ទាប់មកអនុញ្ញាតឱ្យក្រុមទាំងអស់ពន្យល់ពីជំហាននៃគោលការណ៍ RECU ដែលរូបភាពបង្ហាញជូន។

**ជំហានទី ៥៖** ប្រាប់ឱ្យតំណាងរបស់ក្រុមនីមួយៗពន្យល់រយៈពេលពីរបីនាទីដល់ក្រុមធំពីមូលហេតុដែលពួកគេជ្រើសរើសរូបភាពទាំងនោះ។

**ជំហានទី ៦៖** កត់ត្រានៅលើក្រដាសផ្ទាំងធំនូវចំណុចសំខាន់ៗ សរសេរចូលនូវពាក្យគន្លឹះ។

**ជំហានទី ៧៖** ចាក់វីដេអូគំនូរជីវចល ដែលបង្ហាញពីបញ្ហាទូទៅនៃការបង្កលក្ខណៈងាយស្រួលពាក់ព័ន្ធនឹងជំហានទាំង៤នៃគោលការណ៍RECU។

**វីដេអូនេះមានប្រភពពីច្រកចេញចូលសហរដ្ឋអាមេរិក៖**

វីដេអូទី ១៖ របៀបបិទបើកទ្វារ

វីដេអូទី ២៖ ឈើច្រត់

វីដេអូទី ៣៖ ផ្នែកលក់និងសេវាកម្ម

វីដេអូទី ៤៖ បន្ទប់ទឹកដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព

---

[១] សារាចរណ៍ណែនាំអន្តរក្រសួងស្តីពីការសម្របសម្រួលសមស្របសម្រាប់ការងាររបស់ជនមានពិការភាព

**ជំហានទី ៨៖** រៀបចំសេចក្តីសង្ខេបដោយឆ្លុះបញ្ចាំងនៅក្នុងក្រុមធំ ដែលផ្សារភ្ជាប់ជាមួយនឹងស្តង់ដារបច្ចេកទេសថ្នាក់ជាតិអំពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។

**កំណត់ចំណាំ៖ ១អ៊ីញ = ២.៥៤សម**

## មេរៀន ៣.២៖ ការរចនាប្លង់ជាសកលនិងការសម្របសម្រួលសមស្រប ( ៩០នាទី )

**ដំណើរការ៖**

**ជំហានទី ១៖** បំផុសគំនិតជាមួយនឹងក្រុមធំអំពីការរចនាប្លង់ជាសកល៖ តើអ្នកបានដឹងអ្វីខ្លះអំពីដំណើរការនេះ? តើដំណើរការនេះមានន័យដូចម្តេច?សូមសរសេរពាក្យគន្លឹះនៅលើក្រដាសផ្ទាំងធំ។

**ជំហានទី ២៖** ចូរប្រើប្រាស់រូបភាពទាំងបីខាងក្រោមនេះ ទីមួយបង្ហាញអំពីគំរូអាក្រក់ទីពីរបង្ហាញអំពីការសម្របសម្រួលសមស្របនិងទីបីបង្ហាញអំពីការរចនាប្លង់ជាសកល។ បន្ទាប់មកសាកសួរសិក្ខាកាមអំពីអ្វីដែលពួកគេគិត រួចកំណត់ថាតើរូបភាពមួយណាបង្ហាញអំពីគោលការណ៍មួយណា?



គំរូប្លង់មិនល្អ



ការសម្របសម្រួលសមស្រប



ការរចនាជាសកល

**ជំហានទី ៣៖** សូមផ្តល់ពេលវេលាបន្ថែមដល់ក្រុមដើម្បីធ្វើការពិភាក្សាដេញដោលអំពីបញ្ហានេះ។

**ជំហានទី ៤៖** សូមប្រើប្រាស់ស្លាយដ៍ PowerPoint ទី៦ដើម្បីបង្ហាញរូបភាពទាំងបីខាងលើ រួចធ្វើការពន្យល់អំពីភាពខុសគ្នារវាងរូបភាពទាំងនេះ។ ជាមួយគ្នានេះដែរ សូមធ្វើការពន្យល់អំពីគោលការណ៍ទាំង៧នៃការរចនាជាសកល។

**ជំហានទី ៥៖** សូមដាក់រូបភាពមួយចំនួនរបស់មនុស្សដែលមានកម្សោយខុសៗគ្នានៅលើតុធំ រួចស្នើឱ្យអ្នកស្ម័គ្រចិត្តចំនួន៧នាក់ធ្វើការជ្រើសរើសរូបភាពមួយ រួចធ្វើការពន្យល់ដល់ក្រុមធំថាតើរូបភាពរបស់ពួកគាត់តំណាងឱ្យគោលការណ៍មួយណានៅក្នុងចំណោមគោលការណ៍ទាំង៧។ សូមធ្វើការពិភាក្សាប្រសិនបើចាំបាច់។

### លំហាត់ទី ៣.២៖ ការរចនាជាសកលនិងការសម្របសម្រួលសមស្រប

**ដំណើរការ៖**

**ជំហានទី ១៖** បទបង្ហាញស្លាយដ៍ PowerPointទី៦។ គ្រូបង្គោលបង្ហាញស្លាយដ៍ដែលពណ៌នាអំពីការសម្របសម្រួល

សមស្របនិងការរចនាជាសកល។ និងការតម្រង់ទិសឆ្ពោះទៅសារាចរណ៍ណែនាំអន្តរក្រសួងលេខ០០៥ ឆ្នាំ២០១២ ស្តីពី៖ "ការសម្របសម្រួលសមស្របនៅកន្លែងធ្វើការសម្រាប់ជនមានពិការភាព២" ប៉ុន្តែសូមកុំបង្ហាញឧទាហរណ៍ច្រើនពេក។

**ជំហានទី ២៖** លើកឡើងអំពីស្ថានភាពទៅកាន់ក្រុមធំ។ កុមារទៅសាលារៀនជាមួយនឹងឪពុករបស់ខ្លួនដែលមានពិការភាពផ្នែករាងកាយ ហើយលោកឪពុករូបនោះតែងតែជូនកូនរបស់គាត់ទៅសាលានៅរៀងរាល់សប្តាហ៍។

**ជំហានទី ៣៖** ឱ្យសិក្ខាកាមធ្វើកិច្ចការជាគូរ។ សួរសំណួរដូចខាងក្រោមនេះទៅកាន់ពួកគេ៖ តើសាលារៀនអាចធ្វើអ្វីបានខ្លះដើម្បីជួយសម្របសម្រួលដល់កុមារ? តើមានការសម្របសម្រួលសមស្របប្រភេទអ្វីខ្លះ?

**ជំហានទី ៤៖** បន្ទាប់ពីបាន១០នាទី គ្រូបង្គោលឱ្យសិក្ខាកាមបង្ហាញចម្លើយរបស់ពួកខ្លួន៖ ឱ្យសិក្ខាកាមគូទីមួយឆ្លើយសំណួរទីមួយតើសិក្ខាកាមផ្សេងទៀតយល់ស្របដែរឬទេ?សូមផ្តល់ចម្លើយដែលត្រឹមត្រូវនិងពន្យល់ពីមូលហេតុ។

**ចំណុចគន្លឹះ៖** សូមលើកទឹកចិត្តឱ្យធ្វើការពិភាក្សាដេញដោល ប្រសិនបើពួកគេមានគំនិតខុសៗ គ្នា។

## ចប់ម៉ូឌុលទីបី!

| ម៉ូឌុលទីបួន៖ ការវាយតម្លៃការបង្កលក្ខណៈងាយស្រួល (២១០នាទី) | |
|---|---|
| មេរៀនទី ៤.១៖ ឧបសគ្គចំពោះការបង្កលក្ខណៈងាយស្រួល<br>មេរៀនទី ៤.២៖ ការឆ្លើយតបដើម្បីកាត់បន្ថយឧបសគ្គចំពោះការបង្កលក្ខណៈងាយស្រួល | |
| គោលបំណង | នៅចុងបញ្ចប់មេរៀនបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាច៖<br>✓ ពិពណ៌នាអំពីឧបសគ្គ/របាំងដែលអាចរារាំងការចូលរួមពេញលេញរបស់ជនដែលមានពិការភាពផ្សេងៗគ្នានៅក្នុងបរិស្ថានដែលបានសាងសង់ឡើង។ |
| រយៈពេល | ៩០នាទី |
| វិធីសាស្ត្រ | ការសម្តែងលំហាត់៤.១ ការផ្លះបញ្ចាំងនិងការធ្វើបទបង្ហាញ |
| សម្ភារ | - រទេះរុញ វ៉ែនតាដែលពាក់ឃើញព្រាលៗ ឈើច្រត់រាវផ្លូវ ក្រណាត់រុំភ្នែក ឈើច្រត់ត្រឹមស្មា ក្រម៉ា (ដើម្បីចងដៃ ឬជើង)<br>- ក្រដាសផ្ទាំងធំ សន្លឹកកាត ស្កុត ហ្វឺត ផ្ទាំងបង្ហាញ PowerPointទី៧ |
| មេរៀនទី ៤.៣៖ ឧបករណ៍វាយតម្លៃការបង្កលក្ខណៈងាយស្រួលដែលគ្មានលក្ខណៈបច្ចេកទេស | |
| គោលបំណង | នៅចុងបញ្ចប់មេរៀនបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាច៖<br>✓ យល់ដឹងអំពីរបៀបវាយតម្លៃលម្អិតទៅលើការបង្កលក្ខណៈងាយស្រួលនៅតាមអគារ<br>✓ កំណត់ឧបសគ្គទូទៅ ឬរបាំងដែលកំពុងតែកើតមាន<br>✓ ដឹងអំពីរបៀបស្ទើអនុសាសន៍នានា<br>✓ ដឹងអំពីរបៀបវាយតម្លៃសមាសភាគអគារជាក់លាក់ |

២ សារាចរណ៍ណែនាំអន្តរក្រសួងស្តីពីការសម្របសម្រួលសមស្របសម្រាប់ការងាររបស់ជនមានពិការភាព

| | |
|---|---|
| រយៈពេល | ១២០នាទី |
| វិធីសាស្ត្រ | សមាជិកទាំងអស់ចូលរួម ការធ្វើសវនកម្មនៅលើទីតាំង ការងារជាក្រុម |
| សម្ភារ | ឯកសារស្តីពីការបង្កលក្ខណៈងាយស្រួលដែលគ្មានលក្ខណៈបច្ចេកទេស (បញ្ជី NTAA)<br>ម៉ែត្រសម្រាប់វាស់វែង ប៊ិក រទេះរុញ កាមេរ៉ា ផ្ទាំងបង្ហាញ PowerPointទី៨ |

**មេរៀនទី ៤.១៖ ឧបសគ្គចំពោះការបង្កលក្ខណៈងាយស្រួល (៤៥នាទី)**
**មេរៀនទី ៤.២៖ ការឆ្លើយតបដើម្បីកាត់បន្ថយឧបសគ្គចំពោះការបង្កលក្ខណៈងាយស្រួល (៤៥នាទី)**

## លំហាត់ ៤.១៖ ការសម្តែងអំពីការធ្វើពិសោធន៍និងកំណត់ឧបសគ្គ

**ដំណើរការ៖**

**ជំហានទី ១៖** បែងចែកសិក្ខាកាមទៅជាក្រុមតូចដែលមានសិក្ខាកាមចំនួន ៥-៦។

**ជំហានទី ២៖** ឱ្យអ្នកស្ម័គ្រចិត្តម្នាក់នៃក្រុមនីមួយៗឆ្លងកាត់លំហាត់បំផុត។

**ជំហានទី ៣៖** ផ្តល់ជូនអ្នកស្ម័គ្រចិត្តនូវក្រណាត់បិទភ្នែក វ៉ែនតាដែលពាក់ឃើញព្រាលៗ រទេះរុញ ឈើច្រត់ទប់ខ្លួន ឬក្រម៉ាដើម្បីចងដៃ ឬជើងជាប់ទៅនឹងដងខ្លួន។

**ជំហានទី ៤៖** ឱ្យអ្នកស្ម័គ្រចិត្តនៃក្រុមនីមួយៗដាក់ខ្លួននៅក្នុងស្ថាន ឬលក្ខខណ្ឌដែលបានកំណត់នៅក្នុងរយៈពេលនៃលំហាត់។ ឱ្យពួកគាត់ទៅកាន់កន្លែងណាមួយនៅក្នុង និង/ឬខាងក្រៅទីកន្លែងសិក្ខាសាលា ដូចជា អគារផ្សេងៗទៀតដែលនៅជិត រួចឱ្យពួកគាត់ប្រើប្រាស់អគារ (ចូលទៅកាន់ជណ្តើរ បន្ទប់ទឹក ទីធ្លា ជណ្តើរយន្ត កន្លែងសម្រាក។ល។)

**ជំហានទី ៥៖** នៅពេលផុតរយៈពេលដែលបានកំណត់ (ឧទាហរណ៍ ៣០នាទី) សូមឱ្យពួកគាត់ជួបជុំនៅកន្លែងបណ្ដុះបណ្តាលវិញ រួចឱ្យពួកគាត់ចែករំលែកបទពិសោធន៍ និងអារម្មណ៍ផ្ទាល់ខ្លួន។ សាកសួរពួកគាត់ថាតើពួកគាត់មានបានព្យាយាមស្វែងរកជម្រើសផ្សេងៗទៀតដើម្បីបង្កើនសក្តានុពលរបស់ខ្លួនដែរឬទេ?

**ជំហានទី ៦៖** សូមពិភាក្សានៅក្នុងក្រុមតូចអំពីជម្រើស ឬដំណោះស្រាយដែលអាចមាននៅក្នុងការជម្នះឧបសគ្គ។

**ជំហានទី ៧៖** ចែកកាតទទេ និងហ្វឺតដល់ក្រុមតូចនីមួយៗ។

**ជំហានទី ៨៖** ឱ្យក្រុមតូចនីមួយៗ សរសេររៀបរាប់អំពីការលំបាកដែលបានកំណត់ រួចសរសេរចូលទៅក្នុងកាត(បញ្ហាមួយសូមសរសេរនៅលើកាតមួយ)។

**ជំហានទី ៩៖** ធ្វើការឆ្លុះបញ្ចាំងលើការសម្តែង ដោយសួរពួកគាត់៖

- ✓ តើអ្នកគិតដូចម្តេចអំពីការសម្តែង?
- ✓ តើមានការលំបាកដែរទេនៅក្នុងការស្វែងរកវិធី កំណត់បន្ទប់ និងមើលរាល់ព័ត៌មាន ស្លាកសញ្ញា...? តើអ្នកមានអារម្មណ៍ដូចម្តេចអំពីជណ្តើរ ជណ្តើរយន្ត បន្ទប់ទឹក កម្ពស់តុ/តុបុគ្គលិកផ្នែកទទួលភ្ញៀវ...?
- ✓ តើអ្វីខ្លះដែលមានការលំបាក និងតើអ្វីខ្លះដែលងាយស្រួលអនុវត្ត?
- ✓ តើអ្នកមានអារម្មណ៍ដូចម្តេចនៅពេលអ្នកជិះលើរទេះរុញឆ្ពោះទៅកាន់អគារ ឬបន្ទប់ទឹក ឬបន្ទប់ប្រជុំ?
- ✓ តើអ្នកមានអារម្មណ៍ដូចម្តេចនៅពេលអ្នកមិនអាចនិយាយទៅកាន់បុគ្គលិកទទួលភ្ញៀវ និងបង្ហាញអំពីអ្វីដែលអ្នកត្រូវការ?

**ជំហានទី ១០៖** សូមធ្វើកំណត់សម្គាល់ពាក្យគន្លឹះទាំងអស់នៅក្រដាសផ្ទាំងធំ។

**ជំហានទី ១១៖** សូមឱ្យអ្នកស្ម័គ្រចិត្តធ្វើការបែងចែកពាក្យគន្លឹះនៃជំហានទី១០ ទៅតាមប្រភេទខុសៗគ្នាទាំងបីនៃឧបសគ្គដែលបានលើកឡើងនៅក្នុងឯកសារ ៤.១ (បរិស្ថានរូបវន្ត ឥរិយាបថសង្គម ការប្រាស្រ័យទាក់ទង)។

**ជំហានទី ១២៖** បង្ហាញស្លាយដ៍ PowerPoint ទី៧ ដើម្បីបង្ហាញប្រភេទខុសៗគ្នានៃឧបសគ្គចំពោះការបង្កលក្ខណៈងាយស្រួល និងការឆ្លើយតបដែលអាចមានដើម្បីកាត់បន្ថយឧបសគ្គទាំងនោះ។

**សម្គាល់៖** ឧបសគ្គនៅពេលធ្វើជាគ្រូបង្គោល គឺនៅពេលឧបសគ្គទាំងនោះត្រូវបានលុបបំបាត់និងអាចជួយជនមានពិការភាពអាចត្រូវបានគេដាក់បញ្ចូល និងអាចចូលរួមនៅក្នុងសង្គម (ឧទាហរណ៍៖ ប្រសិនបើអ្នកសាងសង់ជម្រាលដើម្បីសម្រួលការឡើងចុះ ជំនួសឱ្យកាំជណ្តើរសម្រាប់ការចេញចូលទៅក្នុងអគារ)។

## មេរៀនទី ៤.៣៖ ឧបករណ៍វាយតម្លៃការបង្កលក្ខណៈងាយស្រួលដែលគ្មានលក្ខណៈបច្ចេកទេស

### លំហាត់ ៤.៣៖ ការវាយតម្លៃការបង្កលក្ខណៈងាយស្រួលដែលគ្មានលក្ខណៈបច្ចេកទេស (NTAA)

**ដំណើរការ៖**

**ជំហានទី ១៖** បំផុសគំនិតសិក្ខាកាមអំពីឧបករណ៍ NTAA ដោយការសួរពួកគាត់អំពីសំណួរមួយចំនួនដូចខាងក្រោម៖

- ✓ តើអ្វីទៅជាឧបករណ៍វាយតម្លៃការបង្កលក្ខណៈងាយស្រួលដែលគ្មានលក្ខណៈបច្ចេកទេស (NTAA)?
- ✓ ហេតុអ្វីបានជាយើងធ្វើការវាយតម្លៃនេះ?
- ✓ តើយើងធ្វើការវាយតម្លៃនេះនៅពេលណា?
- ✓ តើយើងធ្វើការវាយតម្លៃនេះយ៉ាងដូចម្តេច?

**ជំហានទី ២៖** សូមផ្តល់ចម្លើយល្អៗចំពោះសំណួរខាងលើ រួចធ្វើការពិភាក្សាអំពីចម្លើយនេះប្រសិនបើចាំបាច់។

**ជំហានទី ៣៖** សូមធ្វើការបង្ហាញអំពីស្លាយដ៍ PowerPointទី៨ អំពីឧបករណ៍NTAA រួចធ្វើការពន្យល់អំពីគ្រប់ជំហានទាំងអស់។ បន្ទាប់មក សូមចែកឯកសារក្រដាសនៃបញ្ជីត្រួតពិនិត្យNTAA។

**ជំហានទី ៤៖** បន្ទាប់ពីធ្វើការបញ្ជាក់អំពីកង្វល់ផ្សេងៗពាក់ព័ន្ធនឹងបញ្ជី បែងចែកសិក្ខាកាមទៅជាក្រុមដែលមានសមាជិកច្រើនបំផុតចំនួន៤។ សូមផ្តល់ជូនក្រុមនីមួយៗនូវរាល់ឯកសារចាំបាច់ដូចជាឯកសារបញ្ជីត្រួតពិនិត្យ (NTAA) ម៉ែត្រសម្រាប់វាស់ ប៊ិកសម្រាប់កត់ត្រា។ ជាមួយគ្នានេះ សូមធ្វើការត្រួតពិនិត្យថាតើក្រុមនីមួយៗមានទូរសព្ទស្មាតហ្វូនដើម្បីថតរូបដែរឬទេ?។បើអត់មានទេ សូមធ្វើការរៀបចំក្រុមសារជាថ្មី។

**ជំហានទី ៥៖** នៅក្នុងក្រុមតូចនីមួយៗអ្នកត្រូវដាក់បញ្ចូលជនមានពិការភាពនិងជនដែលគ្មានពិការភាព ឬស្នើឱ្យសមាជិកក្រុមធ្វើការស្ម័គ្រចិត្តដាក់ខ្លួនឯងទៅក្នុងស្ថានភាពពិការដូចមាននៅក្នុងលំហាត់៤.១។

**ជំហានទី ៦៖** ឱ្យក្រុមនីមួយទៅកាន់កន្លែងណាមួយនៅក្នុងនិង/ឬ ខាងក្រៅទីកន្លែងសិក្ខាសាលាដូចជាអគារផ្សេងទៀតដែលនៅជិត បន្ទាប់មកឱ្យពួកគាត់ប្រើប្រាស់អគារ (ចូលទៅកាន់ជណ្តើរ បន្ទប់ទឹក ទីធ្លា ជណ្តើរយន្ត កន្លែងសម្រាកជាដើម)។ សូមឱ្យពួកគាត់បំពេញបញ្ជីវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលដោយគ្មានលក្ខណៈបច្ចេកទេស (បញ្ជី NTAA) សម្រាប់ទីកន្លែងដែលជនមានពិការភាពប្រើប្រាស់។

**ជំហានទី ៧៖** ឱ្យក្រុមទាំងអស់ត្រឡប់មកកាន់បន្ទប់បណ្តុះបណ្តាលវិញ រួចធ្វើការបូកសរុបដោយប្រើប្រាស់សំណួរមួយចំនួន៖

- ✓ តើអ្នកគិតយ៉ាងដូចម្តេចចំពោះឧបករណ៍នេះ?
- ✓ តើមានផ្នែកណាមួយដែលអ្នកនៅមិនទាន់យល់ច្បាស់លាស់ដែរឬទេ?
- ✓ តើអ្នកមានការលំបាកអ្វីខ្លះនៅក្នុងប្រើប្រាស់ឧបករណ៍នេះ?
- ✓ តើអ្នកធ្លាប់ប្រើប្រាស់ឧបករណ៍ផ្សេងទៀតសម្រាប់ធ្វើការវាយតម្លៃទៅលើការបង្កលក្ខណៈងាយស្រួលដែរឬទេ?

**លំហាត់ ៤.៣៖ ការពិភាក្សាជាក្រុម NTAA អំពីលទ្ធផលរកឃើញនិងអំពីចំណុចដែលត្រូវដាក់បញ្ចូលទៅក្នុងរបាយការណ៍វាយតម្លៃ**

**ជំហានទី ៨៖** រក្សាក្រុមដដែលដូចនៅក្នុងលំហាត់ NTAA រួចឱ្យពួកគាត់ពិភាក្សាអំពីរបៀបបង្កើតរបាយការណ៍វាយតម្លៃនិងអំពីចំណុចដែលពួកគាត់គិតថាគួរតែដាក់បញ្ចូលទៅក្នុងរបាយការណ៍នោះ?

**ជំហានទី ៩៖** សូមធ្វើការកត់ត្រារាល់ពាក្យគន្លឹះនៅលើក្រដាសផ្ទាំងធំ រួចធ្វើការប្រៀបធៀបជាមួយស្លាយដ៍ PowerPoint ទី៨ដែលបានរៀបចំរួចនិងសូមយល់ព្រមទៅលើទម្រង់របាយការណ៍វាយតម្លៃ។

**ចប់ម៉ូឌុលទីបួន!**

| ម៉ូឌុលទីប្រាំ៖ ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងបរិស្ថានដែលបានបង្កើតឡើង (១៤០ នាទី) | |
|---|---|
| **មេរៀនទី ៥.១៖ ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅតំបន់ទីក្រុង**<br>**មេរៀនទី ៥.២៖ ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងអគារ** | |
| គោលបំណង | នៅចុងបញ្ចប់មេរៀនបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាច៖<br>✓ យល់ដឹងអំពីបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួលនៅ<br>✓ ផ្តល់អនុសាសន៍សម្រាប់កែលម្អការបង្កលក្ខណៈងាយស្រួល |
| រយៈពេល | ៨០នាទី |
| វិធីសាស្ត្រ | ការឆ្លុះបញ្ចាំង និងស្លាយដ៍ PowerPoint ទី៩ និងស្លាយដ៍ PowerPoint ទី ៩.១ និងវគ្គសំណួរចម្លើយ |
| សម្ភារ | - ក្រដាសផ្ទាំងធំ កាតទទេ ស្កុត ហ្វឺត ស្លាយដ៍ PowerPoint |
| **មេរៀនទី ៥.៣៖ ការកំណត់បន្ទប់ទឹកនិងជម្រាលដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព** | |
| គោលបំណង | នៅចុងបញ្ចប់មេរៀនបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាច៖<br>✓ កំណត់ភាពខ្វះខាតហេដ្ឋារចនាសម្ព័ន្ធ និងទម្លាប់ល្អប្រសើរ<br>✓ កំណត់ដំណោះស្រាយដែលអាចមានដើម្បីរៀបចំបន្ទប់ទឹកបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពនិងជម្រាល |
| រយៈពេល | ៦០នាទី |
| វិធីសាស្ត្រ | សមាជិកទាំងអស់ចូលរួម ការងារជាក្រុម លំហាត់ បទបង្ហាញអំពីដំណោះស្រាយ និងការពិភាក្សាគ្នា |

| | |
|---|---|
| សម្ភារ | លំហាត់ ៥.៣៖ លំហាត់អំពីជម្រាលនិងបន្ទប់ទឹក ស្លាយដ៍ PowerPoint ទី១០ក្រដាសចែកជូន៥.៣ ប៊ិកដែលមានពណ៌ខុសៗគ្នា និងស្កុរគ្រាប់សម្រាប់លើកទឹកចិត្តអ្នកចូលរួម |

## មេរៀនទី ៥.១៖ ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងតំបន់ទីក្រុង (៤០នាទី)
## មេរៀនទី ៥.២៖ ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងអគារ (៤០នាទី)

**ដំណើរការ៖** មេរៀននេះមានគោលបំណងផ្ដល់នូវសំណួមពរជាច្រើនដែលពាក់ព័ន្ធនឹងទិដ្ឋភាពខុសៗគ្នាអំពីបរិស្ថានដែលបានបង្កើតឡើងដោយមានការសម្របសម្រួលបន្តិចបន្តួច។

**ជំហានទី ១៖** ធ្វើការបំផុសគំនិតអំពីច្រវាក់ផ្លាស់ទីមិនមានដាច់ ហើយសាកសួរសិក្ខាកាមតើគាត់នៅចងចាំអំពីជំហានទាំង៤ដែរឬទេ?

**ជំហានទី ២៖** សូមធ្វើការពន្យល់ពួកគាត់ថា ការធានាការបង្កលក្ខណៈងាយស្រួលចំពោះបរិស្ថានរូបវន្តសម្រាប់ជនមានពិការភាពប្រភេទផ្សេងៗគ្នា គឺត្រូវធ្វើការសម្របសម្រួលការផ្លាស់ទីរបស់ពួកគាត់តាមរយៈជំហានទាំង៤នៃគោលការណ៍RECU។

**ជំហានទី ៣៖** មុនពេលចាប់ផ្ដើមធ្វើបទបង្ហាញ សូមធ្វើការពន្យល់អំពីគោលបំណងនៃមេរៀននេះ។

**ជំហានទី ៤៖** បទបង្ហាញស្លាយដ៍ PowerPointទី៩ អំពីការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងតំបន់ទីក្រុងនិងស្លាយដ៍ PowerPointទី៩.១ អំពីការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងអគារ។ សូមបញ្ចប់មេរៀននេះជាមួយនឹងវគ្គសំណួរចម្លើយ។

## មេរៀនទី ៥.៣៖ ការរៀបចំបន្ទប់ទឹកដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពនិងជម្រាល (៦០នាទី)

### លំហាត់ ៥.៣.១៖ ការរៀបចំបន្ទប់ទឹកដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព

**ដំណើរការ៖**

**ជំហានទី ១៖** ចូរបែងចែកសិក្ខាកាមជា៥ក្រុម រួចចែកគំនូរប្លង់កម្រាលបន្ទប់ទឹកដល់ក្រុមនីមួយៗ។




រូបភាពទី ៦៖ ប្លង់បន្ទប់ទឹក

**ជំហានទី ២៖** សូមទុកពេលចំនួន១៥នាទី ដើម្បីឱ្យក្រុមធ្វើការកែសម្រួលគំនូរប្លង់និងរៀបចំព្រាងប្លង់បន្ទប់ទឹក ដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពរួមទាំងហេដ្ឋារចនាសម្ព័ន្ធបន្ទប់ទឹកនេះផងដែរ។ ទាំងបន្ទប់ទឹកនិងហេដ្ឋារចនាសម្ព័ន្ធដែលបានតភ្ជាប់គួរតែមានភាពងាយស្រួលប្រើប្រាស់សម្រាប់ជនដែលមានពិការភាពប្រភេទផ្សេងៗគ្នា។ ការកែសម្រួលគួរកំណត់ដើម្បីកាត់បន្ថយការចំណាយ។

**ជំហានទី ៣៖** ឱ្យតំណាងមកពីក្រុមនីមួយៗធ្វើបទបង្ហាញមកកាន់ក្រុមធំអំពីគំនិតរបស់ខ្លួននៅក្នុងការកែសម្រួលគំនូរប្លង់នេះ។ សូមធ្វើការពិភាក្សា និងកំណត់ដំណោះស្រាយប្រសើរបំផុត។

**ជំហានទី ៤៖** សូមបង្ហាញជម្រើស/ដំណោះស្រាយ ដែលអាចមានដោយប្រើស្លាយដ៍ PowerPoint ទី១០។

## លំហាត់៥.៣.២៖ការរៀបចំនិងជម្រាលដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព

**ដំណើរការ៖**

**ជំហានទី ១៖** សូមបង្ហាញរូបភាពទី៧ អំពីជម្រាលដោយប្រើប្រាស់ស្លាយដ៍ PowerPoint ទី១០ រួចសាកសួរឱ្យសិក្ខាកាមអំពីការយល់ឃើញរបស់ពួកគាត់ចំពោះជម្រាល។



រូបភាពទី ៧៖ ស្ថានភាពជម្រាលបេតុងចេញចូលទៅមកបន្ទប់ទឹក

**ជំហានទី ២៖** បង្ហាញរូបមន្តដើម្បីគណនាប្រវែងអប្បបរមានៃជម្រាលដោយប្រើស្លាយដ៍ PowerPoint ទី១០ (សូមមើលរូបភាពខាងក្រោម)

ឧទាហរណ៍ទី ១




រូបភាពទី ៨៖ ឧទាហរណ៍ទី១ អំពីរូបមន្តគណនាជម្រាល

**ជំហានទី ៣៖** សូមបង្ហាញលំហាត់នៃឧទាហរណ៍ទី២៖ នៅក្នុងស្លាយដ៍ PowerPoint ទី១០ រួចសូមឱ្យសិក្ខាកាមធ្វើការគណនាភាគរយនៃចំណោត(%S) នីមួយៗ។ អ្នកដែលផ្តល់ចម្លើយត្រឹមត្រូវនឹងទទួលស្ករគ្រាប់។

ឧទាហរណ៍ទី ២




រូបភាពទី ៩៖ លំហាត់ទី ២ និងចម្លើយអំពីភាគរយនៃជម្រាល

**ជំហានទី ៤៖** សូមបង្ហាញលំហាត់នៃឧទាហរណ៍ទី៣៖ នៅក្នុងស្លាយដ៍ PowerPoint ទី១០ រួចសូមស្នើឱ្យសិក្ខាកាមគណនាប្រវែងនៃជម្រាលនេះដូចខាងក្រោម៖

ឧទាហរណ៍ទី ៣




រូបភាពទី ១០៖ ឧទាហរណ៍ទី៣និងចម្លើយត្រឹមត្រូវនៃប្រវែងជម្រាល

**កំណត់ចំណាំ៖** កម្ពស់កម្រិតខុសគ្នាគឺប៉ះពាល់ទៅដល់ប្រវែងត្រឹមត្រូវនៃជម្រាលដោយសារតែភាគរយធំបំផុតនៃជម្រាលមិនអាចលើសពី៥%ឡើយ ដើម្បីផ្តល់លក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។ រូបភាពខាងក្រោមនេះបង្ហាញពីភាគរយស្តង់ដារនៃជម្រាលដែលអាចបង្កការលំបាកចំពោះអ្នកជិះរទេះរុញ។




រូបភាពទី ១១៖ ភាគរយចំណោតនៃជម្រាល

**ជំហានទី ៥៖** ចូរបែងចែកសិក្ខាកាមជា៥ក្រុមម្តងទៀត រួចធ្វើការចែករំលែកគំនូរប្លង់នៃអគារ (ខាងក្រោម)៖

ឧទាហរណ៍ទី ៤




រូបភាពទី ១២៖ ឧទាហរណ៍ទី៤នៃប្លង់អគារ

**ជំហានទី ៦៖** ចូរធ្វើកិច្ចការជាក្រុមដើម្បីដាក់បញ្ចូលជម្រាលបង្កលក្ខណៈងាយស្រួលទៅក្នុងគំនូរប្លង់នេះ នៅកន្លែងសមស្របដែលអាចឱ្យបុគ្គលពិបាកផ្លាស់ទីអាចចូលទៅក្នុងអគារនេះដោយគ្មានឧបសគ្គ។

**ជំហានទី ៨៖** សូមឱ្យតំណាងម្នាក់មកពីក្រុមនីមួយៗធ្វើការបង្ហាញអំពីគំនិតរបស់ខ្លួននៅក្នុងការកែសម្រួលគំនូរប្លង់នេះដល់ក្រុមធំ។ ចូរពិភាក្សា និងកំណត់ដំណោះស្រាយប្រសើរបំផុត។

**ជំហានទី ៩៖** សូមបង្ហាញជម្រើស/ដំណោះស្រាយដែលអាចមានដោយប្រើប្រាស់ស្លាយដ៍ PowerPoint ទី១០ ដើម្បីធ្វើការពន្យល់អំពីមូលហេតុ។

**ចប់ម៉ូឌុលទីប្រាំ!**

## លំហាត់បញ្ចប់មេរៀន

នៅថ្ងៃចុងក្រោយនៃការបណ្តុះបណ្តាលជាការសំខាន់ដែលត្រូវធ្វើការវាយតម្លៃការបណ្តុះបណ្តាលនេះ។ ការវាយតម្លៃនេះអាចជួយអ្នកក្នុងការកំណត់ថាតើវិធីសាស្រ្តរបស់អ្នកមានភាពច្បាស់លាស់ ហើយតើសិក្ខាកាមពេញចិត្តចំពោះការរៀបចំមេរៀនទូទៅដែរឬទេ។ ការវាយតម្លៃនេះ មិនមានគោលដៅដើម្បីធ្វើការវាស់វែងការយល់ដឹងរបស់សិក្ខាកាមពាក់ព័ន្ធនឹងខ្លឹមសារនៃការបណ្តុះបណ្តាលឡើយ។ សមាសភាគនេះត្រូវបានវាស់វែងតាមរយៈការធ្វើតេស្តនៅមុនពេលនិងក្រោយពេលវគ្គបណ្តុះបណ្តាល។ខាងក្រោមនេះគឺជាវិធីសាស្រ្តល្អប្រសើរមួយចំនួនដែលអ្នកអាចប្រើប្រាស់ដើម្បីធ្វើការវាយតម្លៃមេរៀនទីនេះ។

**គោលដៅ៖**

**ដំណើរការ៖**



**ជំហានទី ១៖** សូមគូសគោលដៅ (ការជម្រើសដែលអ្នកចង់ធ្វើការវាយតម្លៃ) នៅលើក្រដាសផ្ទាំងធំដូចជារូបភាពនៅខាងក្រោមនេះ៖

**ជំហានទី ២៖** សូមធ្វើការបែងចែកទៅជាផ្នែកមួយចំនួន៖ គុណភាពនៃការសម្របសម្រួល គុណភាពនៃការរៀបចំរយៈពេល និងការបំពេញតាមការរំពឹងទុក ។ល។

**ជំហានទី ៣៖** ចូរប្រាប់ឱ្យសិក្ខាកាមម្នាក់ៗបង្ហាញអំពីកម្រិតពេញចិត្តរបស់ខ្លួននៅក្នុងផ្នែកនីមួយៗដោយគូសបន្ទាត់កាត់។សិក្ខាកាមដែលដាក់បន្ទាត់កាត់នៅជិតនឹងចំណុចកណ្តាលនៃគោលដៅមានន័យថាគាត់មានការពេញចិត្តខ្លាំងប្រសិនបើគាត់ដាក់បន្ទាត់កាត់នៅជិតចំណុចខាងក្រៅនោះគាត់មានការពេញចិត្តតិចតួច។

**<u>បាល់៖</u>**

**ដំណើរការ៖**

**ជំហានទី ១៖** សូមឱ្យសិក្ខាកាមគូសជារង្វង់។

**ជំហានទី ២៖** បោះបាល់ទៅសិក្ខាកាមណាម្នាក់ រួចឱ្យគាត់និយាយអំពីមេរៀនដែលគាត់ចូលចិត្តជាងគេនៅក្នុងពេលបណ្តុះបណ្តាល។ បន្ទាប់មកទៀត ឱ្យគាត់បញ្ជូនបាល់ទៅសិក្ខាកាមម្នាក់ទៀតដែលនិយាយអំពីចំណុចដែលគាត់ចូលចិត្តតិចជាងគេនៅក្នុងពេលរៀនមេរៀន។

**ជំហានទី ៣៖** សូមបន្តរហូតទាល់តែសិក្ខាកាមម្នាក់ៗមានឱកាសនិយាយអំពីចំណុចដែលគាត់ចូលចិត្តច្រើនជាងឬតិចជាងគេ។

**<u>នៅកាច់ជ្រុង៖</u>**

វិធីសាស្រ្តនេះកាន់តែងាយស្រួលប្រើប្រាស់ប្រសិនបើអនុវត្តនៅក្នុងបន្ទប់បិទជិត។ ប្រសិនបើអ្នកអនុវត្តវិធីសាស្រ្តនេះនៅខាងក្រៅ សូមបង្កើតជ្រុងចំនួន៤ដោយដាក់កៅអីចំនួន៤ ឬវត្ថុផ្សេងៗទៀតនៅកន្លែងដែលអ្នកនឹងដាក់ឈ្មោះនៅកាច់ជ្រុង។

**ដំណើរការ៖**

**ជំហានទី ១៖** ពន្យល់ចំពោះសិក្ខាកាមអំពីខ្លឹមសារដែលនៅជ្រុងនីមួយៗតំណាងឱ្យ៖ ពេញចិត្តខ្លាំង ពេញចិត្ត មិនពេញចិត្ត មិនពេញចិត្តទាល់តែសោះ។

**ជំហានទី ២៖** ឱ្យសិក្ខាកាមឈរនៅចំកណ្តាលបរិវេណដែលបានជ្រើសរើសសម្រាប់លំហាត់។

**ជំហានទី ៣៖** ប្រកាសអំពីកន្លែងដែលអ្នកចង់វាស់ (ការបង្កលក្ខណៈងាយស្រួលនៅទីកន្លែងបណ្តុះបណ្តាលរយៈពេលនៃការបណ្តុះបណ្តាល ការសម្របសម្រួល៖ ល្បែង លំហាត់ ខ្លឹមសារនៃការបណ្តុះបណ្តាល ភ័ស្តុភារនៃការបណ្តុះបណ្តាល (អាហារ កន្លែងបណ្តុះបណ្តាល។ល។)។

**ជំហានទី ៤៖** ឱ្យសិក្ខាកាមផ្លាស់ទីទៅកន្លែងកាច់ជ្រុងដែលឆ្លុះបង្ហាញបានត្រឹមត្រូវជាងគេអំពីកម្រិតពេញចិត្តរបស់គាត់ពាក់ព័ន្ធនឹងទីកន្លែងកន្លែងនេះ។

**ជំហានទី ៥៖** សូមធ្វើការរាប់ រួចកត់ចំណាំលេខសិក្ខាកាមនៅក្នុងជ្រុងនីមួយៗ និងប្រកាសអំពីកន្លែងមួយទៀត។

**ជំហានទី ៦៖** ឱ្យសិក្ខាកាមផ្លាស់ទីទៅតាមកម្រិតនៃការពេញចិត្តរបស់គាត់ពាក់ព័ន្ធនឹងកន្លែងទីពីរនេះ។ ប្រសិនបើពួកគាត់គិតដូចគ្នា ដូច្នេះពួកគាត់មិនត្រូវផ្លាស់ទីឡើយ។

**ចំណុចគន្លឹះ៖** ប្រសិនបើសិក្ខាកាមមានការលំបាកក្នុងការផ្លាស់ទី អ្នកត្រូវប្រាកដថាអ្នកទុកពេលឱ្យពួកគាត់បានគ្រប់គ្រាន់ដើម្បីផ្លាស់ទីពីជ្រុងមួយទៅជ្រុងមួយទៀត ឬពួកគាត់ទទួលបានជំនួយមួយចំនួន។

## យល់ស្របឬមិនយល់ស្រប៖

គ្រូបង្គោលប្រើប្រាស់វិធានតែមួយសម្រាប់ជ្រុងទាំងឡាយ ប៉ុន្តែជ្រុងនីមួយៗមានអត្ថន័យខុសគ្នា៖ យល់ស្របទាំងស្រុង ឬយល់ស្រប ឬមិនយល់ស្រប ឬមិនយល់ស្របទាំងស្រុង។នៅក្នុងករណីនេះ សូមអានប្រយោគជំនួសឱ្យទីកន្លែង។

**ដំណើរការ៖**

**ចំណុចគន្លឹះ៖** ត្រូវប្រាកដថាកន្លែងដែលរៀបចំការបណ្តុះបណ្តាលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពនិងមានទីធ្លាគ្រប់គ្រាន់។ក្នុងករណីដែលសិក្ខាកាមមួយចំនួនមានបញ្ហាក្នុងការផ្លាស់ទី អ្នកអាចកែសម្រួលវិធីសាស្ត្រ ហើយគ្រាន់តែពិចារណាយល់ស្របនិងមិនយល់ស្រប។

**ជំហានទី ១៖** ផ្តល់ជូនសិក្ខាកាមនូវកាតពណ៌ខៀវ = យល់ស្រប និងកាតពណ៌ក្រហម = មិនយល់ស្រប។

**ជំហានទី ២៖** ធ្វើការប្រកាសសេចក្តីថ្លែង រួចសូមឱ្យសិក្ខាកាមលើកកាតពណ៌ខៀវ ឬពណ៌ក្រហមដើម្បីបញ្ជាក់យល់ស្រប/មិនយល់ស្រប។

## ការប្រើប្រាស់ទម្រង់វាយតម្លៃវគ្គ៖

គ្រូបង្គោលអាចប្រើប្រាស់ទម្រង់វាយតម្លៃខាងក្រោមនេះដើម្បីធ្វើការវាយតម្លៃការបណ្តុះបណ្តាលទាំងមូល។ សូមទុកពេលឱ្យសិក្ខាកាមបំពេញទម្រង់នេះរួចប្រមូលយកទម្រង់វាយតម្លៃនោះមកវិញ។

### ទម្រង់វាយតម្លៃ វគ្គ

ទម្រង់វាយតម្លៃការបណ្តុះបណ្តាលអំពីពិការភាព និងការបង្កលក្ខណៈងាយស្រួល យើងសូមស្នើឱ្យអ្នកបំពេញទម្រង់វាយតម្លៃដើម្បីឱ្យយើងអាចទទួលបានមតិត្រឡប់អំពីការបណ្តុះបណ្តាលដែលសិក្ខាកាមនៅក្នុងសប្តាហ៍នេះ។

| ទិដ្ឋភាពវាយតម្លៃ | ល្អប្រសើរ | ល្អ | ធម្មតា | អាក្រក់ |
|---|---|---|---|---|
| គោលបំណងនៃការបណ្ដុះបណ្ដាល | | | | |
| ភាពជាប់ពាក់ព័ន្ធនឹងមេរៀន | | | | |
| គុណតម្លៃដែលបានមកពីការចំណាយពេលវេលា | | | | |
| ភាសា/ពាក្យពេចន៍ដែលបានប្រើប្រាស់ | | | | |
| សកម្មភាពជាក្រុម | | | | |
| វិធីសាស្ត្របណ្ដុះបណ្ដាល | | | | |
| ទីកន្លែងបណ្ដុះបណ្ដាល | | | | |
| កម្មវិធីស្គាល់គ្នាដំបូង | | | | |
| សូមសរសេរចំណុចសំខាន់ចំនួន៤ដែលអ្នកបានសិក្សាពីការបណ្ដុះបណ្ដាលនេះ | | | | |
| តើមេរៀនអ្វីដែលមានសារប្រយោជន៍ជាងគេ? សូមផ្ដល់ហេតុផលសម្រាប់ចម្លើយរបស់អ្នក។ | | | | |
| តើអ្នកមានយោបល់អ្វីខ្លះអំពីគ្រូបង្គោលរបស់អ្នក? | | | | |
| នៅក្នុងការបណ្ដុះបណ្ដាលនេះ តើអ្នកពេញចិត្តអ្វីជាងគេ? | | | | |
| តើអ្នកមិនពេញចិត្តអ្វីខ្លះនៅក្នុងការបណ្ដុះបណ្ដាលនេះ? | | | | |
| សូមសរសេរមតិយោបល់ផ្សេងៗទៀតដែលអ្នកអាចមានពាក់ព័ន្ធនឹងការបណ្ដុះបណ្ដាលនេះ។ | | | | |

# ផ្នែកទី ៣៖ ឯកសារបណ្តុះបណ្តាល

### គំរូតេស្តអំពីពិការភាពនិងការបង្កលក្ខណៈងាយស្រួល

| ការធ្វើតេស្តផ្នែកពិការភាព | | |
|---|---|---|
| ១) តើអ្វីជាពិការភាព? | | |
| គឺជាលទ្ធផលនៃស្ថានភាពដែលកត្តាផ្ទាល់ខ្លួនមានអន្តរកម្មអវិជ្ជមានជាមួយនឹងបរិស្ថានជុំវិញ។ | បាទ/ចាស | ទេ |
| គឺជាកម្រិតនៃកំហិតផ្នែករាងកាយ បញ្ញា ផ្លូវចិត្ត ឬវិញ្ញាណរបស់បុគ្គលម្នាក់ដែលមានផលប៉ះពាល់រយៈពេលវែង។ | បាទ/ចាស | ទេ |
| អាចប៉ះពាល់ទៅលើពលរដ្ឋគ្រប់វ័យ ហើយអាចមានលក្ខណៈអចិន្ត្រៃយ៍ ឬបណ្តោះអាសន្ន។ | បាទ/ចាស | ទេ |
| គឺជាស្ថានភាពដែលអាចប្រែប្រួលតាមរយៈការធ្វើឱ្យប្រសើរឡើងនូវកត្តាផ្ទាល់ខ្លួន និង/ឬកត្តាបរិស្ថានជុំវិញ។ | បាទ/ចាស | ទេ |
| ២) តើអ្វីជាកម្សោយសរីរាង្គ? | | |
| គឺជាបញ្ហានៃមុខងាររាងកាយ ឬរចនាសម្ព័ន្ធរាងកាយ ដូចជា ការប្រែប្រួលខ្លាំង ឬការបាត់បង់ទាំងស្រុងតែម្តង។ | បាទ/ចាស | ទេ |
| កម្សោយអាចមានលក្ខណៈបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ថយចុះ នៅថេរ ម្តងម្កាល ឬជាប់ជាប្រចាំ។ | បាទ/ចាស | ទេ |
| ជនដែលមានភាពចុះខ្សោយមុខងារសរីរាង្គណាមួយជាញឹកញាប់ តែងតែជួបប្រទះឧបសគ្គនានាក្នុងការទទួលបានការអប់រំ សេវាសុខភាព ការងារនិងចូលរួមក្នុងជីវិតសាធារណៈ។ | បាទ/ចាស | ទេ |
| រាល់ភាពចុះខ្សោយសរីរាង្គទាំងអស់សុទ្ធតែអាចមើលឃើញដោយភ្នែកបាន | បាទ/ចាស | ទេ |
| ៣) នៅពេលអ្នកជួបអ្នកមានពិការភាព តើជាការសមស្របដែរ ឬទេនៅក្នុងការចាប់រលាក់ដៃជាមួយគាត់? | | |
| ៤) តើអ្នកអាចទាក់ទាញការចាប់អារម្មណ៍របស់មនុស្សគរ-ថ្លង់យ៉ាងដូចម្តេច? | | |
| និយាយខ្លាំងៗទៅកាន់ពួកគាត់ | បាទ/ចាស | ទេ |
| ទះស្មាពួកគាត់ | បាទ/ចាស | ទេ |
| គ្រវីដៃរបស់អ្នកជាសញ្ញា | បាទ/ចាស | ទេ |
| ៥) នៅពេលដែលអ្នកចង់និយាយទៅកាន់បុគ្គលដែលកម្សោយការស្តាប់ | | |
| តើអ្នកធ្វើដូចម្តេច? | | |

| | | |
|---|---|---|
| អ្នកនិយាយទៅអ្នកបកប្រែភាសាសញ្ញារបស់គាត់ | បាទ/ចាស | ទេ |
| អ្នកនិយាយជាមួយគាត់ដោយផ្ទាល់ | បាទ/ចាស | ទេ |
| អ្នកនិយាយទៅកាន់អ្នកថែទាំរបស់គាត់ | បាទ/ចាស | ទេ |
| **៦) តើអ្នកធ្វើដូចម្តេចប្រសិនបើអ្នកកំពុងនិយាយជាមួយបុគ្គលមានពិការភាព ហើយអ្នកមិនយល់អំពីអ្វីដែលគាត់និយាយមកកាន់អ្នក?** | | |
| អ្នកងក់ក្បាល រួចធ្វើដូចជាយល់ ដូច្នេះអ្នកមិនធ្វើឱ្យពួកគាត់អាក់អន់ចិត្ត | បាទ/ចាស | ទេ |
| អ្នកសួរសំណួរខ្លីហើយច្បាស់ ដែលនឹងទទួលបានមកវិញនូវចម្លើយដែលខ្លីហើយច្បាស់ | បាទ/ចាស | ទេ |
| អ្នកញញឹម | បាទ/ចាស | ទេ |
| **ការធ្វើតេស្តផ្នែកការបង្កលក្ខណៈងាយស្រួល** | | |
| **១) ការបង្កលក្ខណៈងាយស្រួល មានន័យថាជាការធានាថាហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់៖** | | |
| ជនមានពិការភាពតែប៉ុណ្ណោះ | បាទ/ចាស | ទេ |
| ជនមានពិការភាពនិងកុមារតែប៉ុណ្ណោះ | បាទ/ចាស | ទេ |
| ជនមានពិការភាពនិងស្ត្រីមានផ្ទៃពោះតែប៉ុណ្ណោះ | បាទ/ចាស | ទេ |
| ជនមានពិការភាពនិងអ្នកមានរបួសតែប៉ុណ្ណោះ | បាទ/ចាស | ទេ |
| សម្រាប់មនុស្សទាំងអស់ដោយមិនគិតពីអាយុ ឬស្ថានភាពណាមួយឡើយ | បាទ/ចាស | ទេ |
| **២) ឧបសគ្គដែលជនមានពិការភាពអាចជួបមាន** | | |
| ផ្នែកសង្គម និងនយោបាយ/ស្ថាប័ន | បាទ/ចាស | ទេ |
| ពាក់ព័ន្ធនឹងឥរិយាបថ/អាកប្បកិរិយាបុគ្គល | បាទ/ចាស | ទេ |
| ពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងលក្ខណៈផ្តេក លក្ខណៈបញ្ឈរ | បាទ/ចាស | ទេ |
| បរិស្ថានរូបវន្ត | បាទ/ចាស | ទេ |
| **៣) តើវិធីសាស្ត្រ RECU មានន័យដូចម្តេច?** | | |
| អាន អប់រំ ប្រាស្រ័យទាក់ទង ប្រើប្រាស់ (Read, Educate, Communicate, Use) | បាទ/ចាស | ទេ |
| ការទៅដល់ ការចូលក្នុង ការផ្លាស់ទី ការប្រើប្រាស់ (Reach, Enter, Circulate, Use) | បាទ/ចាស | ទេ |
| កម្រ សង្ហារ ប្រុងប្រយ័ត្ន ពិសេស (Rare, Elegant, Cautious, Unique) | បាទ/ចាស | ទេ |

| | | |
|---|---|---|
| ត្រឹមត្រូវ អប់រំ ការប្រាស្រ័យទាក់ទង ឯកសណ្ឋាន (Right, Education, Communication, Uniform) | បាទ/ចាស | ទេ |
| **៤) ការបង្កលក្ខណៈងាយស្រួលផ្នែករូបវ័ន្តនៅក្នុងបរិបទអាស៊ី៖** | | |
| គឺពិបាកណាស់ដើម្បីសំរេចបានដោយសារតែការខ្វះវត្ថុធាតុដើមសម្ភារៈនិងបច្ចេកវិទ្យា | បាទ/ចាស | ទេ |
| អាចធ្វើឱ្យប្រសើរឡើងបានជាមួយនឹងការប្រើប្រាស់ដំណោះស្រាយដែលងាយៗនិងប្រើប្រាស់សម្ភារៈក្នុងស្រុកជំនួស | បាទ/ចាស | ទេ |
| មិនមានសារសំខាន់ទេ ដោយសារមានអាទិភាពផ្សេងទៀត | បាទ/ចាស | ទេ |
| គួរធ្វើការលើកកម្ពស់ដោយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដោយមានការចូលរួមយ៉ាងសកម្មពីជនមានពិការភាព | បាទ/ចាស | ទេ |
| ការបង្កលក្ខណៈងាយស្រួលត្រូវធ្វើការពិចារណាឱ្យបានឆាប់តាមដែលអាចធ្វើបាននៅពេលកសាងហេដ្ឋារចនាសម្ព័ន្ធថ្មី ឬជួសជុលអគារឡើងវិញ | បាទ/ចាស | ទេ |
| **៥) ការបង្កលក្ខណៈងាយស្រួលអាចសម្រេចបានទាំងស្រុងនៅក្នុងការសាងសង់ ប្រសិនបើ៖** | | |
| ជម្រាលត្រូវបានកសាងនៅច្រកចូលអគារ ទោះមានការរៀបចំបែបណាក៏ដោយ | បាទ/ចាស | ទេ |
| ជណ្តើរយន្តដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពត្រូវបានរៀបចំឱ្យមាននៅទីកន្លែងផ្ទាល់ | បាទ/ចាស | ទេ |
| បង្កាន់ដៃត្រូវបានរៀបចំឱ្យមាននៅក្នុងបន្ទប់ទឹក | បាទ/ចាស | ទេ |
| ផ្ទាំងព័ត៌មានត្រូវបានរៀបចំឱ្យមាននៅក្នុងអគារទោះបីមានសញ្ញាសម្គាល់ ឬអត់ក៏ដោយ | បាទ/ចាស | ទេ |
| មានបំពាក់ពេញលេញនូវទីកន្លែងបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព | បាទ/ចាស | ទេ |
| **៦) នៅពេលធ្វើកិច្ចការនៅក្នុងការកែសម្រួល ឬសាងសង់ទីកន្លែងបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព យើងគួរមានការចូលរួមពី៖** | | |
| វិស្វករនិងអ្នកជំនាញផ្នែកបង្កលក្ខណៈងាយស្រួលតែប៉ុណ្ណោះ | បាទ/ចាស | ទេ |
| អ្នកប្រើប្រាស់រទេះរុញតែប៉ុណ្ណោះ | បាទ/ចាស | ទេ |
| វេជ្ជបណ្ឌិត គ្រូពេទ្យព្យាបាល និងអ្នកឯកទេសផ្នែកពិការភាពតែប៉ុណ្ណោះ | បាទ/ចាស | ទេ |
| រាល់ភាគីពាក់ព័ន្ធ អ្នកឯកទេស អ្នកគ្រប់គ្រង និងអ្នកប្រើប្រាស់ទាំងអស់រួមទាំងជនមានពិការភាពផងដែរ។ | បាទ/ចាស | ទេ |
| **៧) ការបង្កលក្ខណៈងាយស្រួលគឺជាបុរេលក្ខខណ្ឌចំពោះ៖** | | |
| ការប្រើប្រាស់សេវាសាធារណៈ ដូចជាសាលារៀន និងមន្ទីរពេទ្យជាដើម | បាទ/ចាស | ទេ |

| | | |
|---|---|---|
| ការសម្រេចបាននូវសិទ្ធិផ្សេងៗ ដូចជា ការបោះឆ្នោត ការទទួលបានឱកាសការងារ និងការមានទឹកប្រើប្រាស់ | បាទ/ចាស | ទេ |
| ការមានលទ្ធភាពអាចធ្វើសកម្មភាពកម្សាន្តសប្បាយផ្សេងៗ (ការប្រើប្រាស់កន្លែងលេងសម្រាប់កុមារ ការចូលរួមក្នុងកម្មវិធីបង្ហាញសាធារណៈ ការទៅលេងនៅតំបន់ឆ្នេរ។ល។) | បាទ/ចាស | ទេ |
| **៨) ដើម្បីកែលម្អការបង្កលក្ខណៈងាយស្រួលជាការសំខាន់ត្រូវ៖** | | |
| កែលម្អការបង្កលក្ខណៈងាយស្រួលនៅច្រកចូលអគារ | បាទ/ចាស | ទេ |
| កែលម្អការបង្កលក្ខណៈងាយស្រួលតាមធ្យោបាយដឹកជញ្ជូនសាធារណៈ និងឯកជន | បាទ/ចាស | ទេ |
| គិតអំពីទីតាំង និងការរចនាបរិក្ខារ និងសង្ហារឹមនៅតាមទីក្រុង | បាទ/ចាស | ទេ |
| ធានាថា ឯកសារងាយស្រួលមើលយល់ នៅពេលព្រីនចេញ | បាទ/ចាស | ទេ |
| ធានាថា ខ្សែច្រវាក់នៃការផ្លាស់ទីពីផ្ទះទៅកន្លែងផ្តល់សេវាមិនមានការខូចខាត | បាទ/ចាស | ទេ |
| ពិចារណាអំពីតម្រូវការរបស់ជនមានពិការភាពនៅពេលរៀបចំកម្មវិធីណាមួយ | បាទ/ចាស | ទេ |
| **៩) ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងបរិស្ថានដែលបានសាងសង់ឡើង៖** | | |
| គួរកាត់បន្ថយឱ្យនៅកម្រិតទាបបំផុតដោយសារវាមានតម្លៃថ្លៃខ្លាំងដូចជា (ជម្រាល បង្កាន់ដៃ បន្ទប់ទឹកដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព។ល។) | បាទ/ចាស | ទេ |
| កាន់តែមានប្រសិទ្ធភាពប្រសិនបើបានដាក់បញ្ចូលទៅក្នុងដំណាក់កាលរចនាអគារតាំងពីដំណាក់កាលដំបូង | បាទ/ចាស | ទេ |
| មិនអាចផ្តល់ជូនឬធ្វើទៅបានទេ សម្រាប់អគារដែលមានស្រាប់ឡើយ | បាទ/ចាស | ទេ |
| គឺមិនចាំបាច់រួមបញ្ចូលព័ត៌មានលាយលក្ខណ៍អក្សរ ទំហំអក្សរ ពណ៌ ការបង្ហាញព័ត៌មានតាមរយៈផ្ទាំងរូបភាព និមិត្តសញ្ញា ឬការប្រើប្រាស់ពន្លឺនោះទេ។ | បាទ/ចាស | ទេ |
| អាចផ្តល់ជូនសម្រាប់អគារមានស្រាប់ ប៉ុន្តែលទ្ធផលចុងក្រោយគឺមានបញ្ហារាំងស្ទះជាច្រើន (ទំហំទីកន្លែង ទ្រង់ទ្រាយអគារ ទីតាំងអគារ។ល។) | បាទ/ចាស | ទេ |
| **១០) ការសម្របសម្រួលសមស្របមានន័យថា៖** | | |
| ភាពបត់បែនដើម្បីអនុវត្តការកែសម្រួលជាក់លាក់ដើម្បីស្របតាមតម្រូវការជនមាន | បាទ/ចាស | ទេ |
| ពិការភាពដើម្បីធានាការចូលរួមនិងបរិយាបន្នពួកគាត់។ | បាទ/ចាស | ទេ |
| សំដៅដល់ការធ្វើទីផ្សារផលិតផលនិងសេវាកម្មសម្រាប់ជនមានពិការភាព។ | បាទ/ចាស | ទេ |
| ការរៀបចំកិច្ចប្រជុំនៅនឹងកន្លែងដែលផ្តល់លក្ខណៈងាយស្រួលសម្រាប់ជនដែលមានការលំបាកក្នុងការផ្លាស់ទី ឬនៅជិតផ្ទះរបស់ពួកគាត់។ | បាទ/ចាស | ទេ |

| ១១) តើអ្វីទៅជាការរចនាជាសកល? | | |
|---|---|---|
| ទំហំ ឬបរិវេណសមស្របត្រូវបានផ្តល់ជូនដើម្បីឱ្យមានភាពងាយស្រួលចូលទៅដល់សម្របសម្រួល និងប្រើប្រាស់បាន បើទោះជាអ្នកប្រើប្រាស់មានទំហំដងខ្លួនប៉ុណ្ណា តំរិយាបថ ឬការផ្លាស់ទីយ៉ាងណាក៏ដោយ វាគឺជាគោលការណ៍នៃការរចនាជាសកល។ | បាទ/ចាស | ទេ |
| សំដៅលើការរចនាផលិតផល បរិស្ថាន កម្មវិធី និងសេវាដើម្បីឱ្យមនុស្សទាំងអស់អាចប្រើប្រាស់បានច្រើនបំផុតតាមដែលអាចធ្វើបានដោយពុំចាំបាច់មានការសម្របសម្រួល ឬការរៀបចំតាមបែបបច្ចេកទេស។ | បាទ/ចាស | ទេ |
| មានគោលដៅជួយសម្រួលដល់ការរស់នៅសម្រាប់មនុស្សទាំងអស់ដោយធ្វើឱ្យ | បាទ/ចាស | ទេ |
| ផលិតផល ការទំនាក់ទំនង និងបរិស្ថានដែលបានបង្កើតឡើងកាន់តែអាចប្រើប្រាស់បានដោយមនុស្សជាច្រើននៅក្នុងតម្លៃតិចតួច ឬគ្មានការចំណាយបន្ថែម។ | បាទ/ចាស | ទេ |
| ត្រូវដាក់បញ្ចូលឧបករណ៍ជំនួយសម្រាប់ក្រុមមានពិការភាពណាមួយដែលមានតម្រូវការឧបករណ៍ទាំងនេះ។ | បាទ/ចាស | ទេ |

## ចម្លើយតេស្តអំពីពិការភាព

ចម្លើយដែលត្រឹមត្រូវចំពោះការធ្វើតេស្តមុននិងក្រោយវគ្គបណ្តុះបណ្តាលមានដូចខាងក្រោម៖

### ១. និយមន័យពិការភាព៖

- គឺជាលទ្ធផលនៃស្ថានភាពដែលកត្តាផ្ទាល់ខ្លួនមានអន្តរកម្មអវិជ្ជមានជាមួយបរិស្ថាន។ ពិការភាពអាចប៉ះពាល់ដល់មនុស្សគ្រប់វ័យ ហើយអាចមានលក្ខណៈជាអចិន្ត្រៃយ៍ ឬជាបណ្តោះអាសន្ន។
- ពិការភាពគឺជាស្ថានភាពដែលអាចមានការប្រែប្រួលតាមរយៈការធ្វើឱ្យប្រសើរឡើងនូវកត្តាផ្ទាល់ខ្លួន ឬកត្តាបរិស្ថាន ហើយជាទូទៅគឺកត្តាទាំងពីរ។

### ២. កម្សោយសរីរាង្គ

- បញ្ហានៅក្នុងមុខងាររាងកាយ ឬរចនាសម្ព័ន្ធរាងកាយដូចជាការប្រែប្រួលខ្លាំង ឬការបាត់បង់ទាំងស្រុងតែម្តង។ បុគ្គលដែលមានកម្សោយសរីរាង្គតែងតែជួបប្រទះឧសគ្គក្នុងការចូលរួមនៅក្នុងជីវិតដូចជាការសិក្សា សុខភាព ការងារ នយោបាយ និងជីវិតសាធារណៈ។

### ៣. នៅពេលអ្នកជួបអ្នកមានពិការភាព តើជាការសមស្របដែរឬទេនៅក្នុងការចាប់រលាក់ដៃជាមួយគាត់?

- បាទ/ចាសទោះបីជាបុគ្គលនោះមិនអាចចាប់រលាក់ដៃរបស់អ្នកដោយសារតែកម្សោយរបស់គាត់ក៏ដោយ ប៉ុន្តែជាការសំខាន់គឺត្រូវស្វាគមន៍ពួកគាត់និងបង្ហាញការគោរពរបស់អ្នកដោយប្រើប្រាស់កាយវិការដែលមានលក្ខណៈវប្បធម៌រួមតែមួយ។

### ៤. តើអ្នកទាក់ទាញ ឬអាចទាក់ទាញការចាប់អារម្មណ៍របស់មនុស្សគរថ្លង់យ៉ាងដូចម្តេច?

- គ្រវីដៃរបស់អ្នកជាសញ្ញាសូមកុំបញ្ឆៀតចូលកន្លែងអ្នកដទៃដោយគិតថាដើម្បីឱ្យខ្លួនអ្នកងាយស្រួល ។ សូមសាកល្បងគិតថា បើមានគេទះស្មារបស់អ្នកគ្រប់ពេលវេលា។ ជាវិធានទូទៅត្រូវពឹងផ្អែកលើវិញ្ញាណដែល "មានប្រសិទ្ធភាព"

ដើម្បីធ្វើការប្រាស្រ័យទាក់ទង (ការនិយាយសម្រាប់អ្នកមានកម្សោយចក្ខុ ការមើលសម្រាប់អ្នកមានកម្សោយផ្នែកការស្តាប់។ល។)។

**៥. នៅពេលដែលអ្នកចង់និយាយទៅកាន់បុគ្គលដែលកម្សោយការស្តាប់ តើអ្នកធ្វើដូចម្តេច?**

- អ្នកនិយាយជាមួយគាត់ដោយផ្ទាល់អ្នកអាចប្រាស្រ័យទាក់ទងជាមួយអ្នកមានកម្សោយការស្តាប់។ ទោះបីពួកគាត់មានអ្នកប្រែភាសាសញ្ញា ឬអ្នកថែទាំឬអ្នកមើលថែក៏ដោយ ប៉ុន្តែអ្នកគួរប្រាស្រ័យទាក់ទងជាមួយគាត់ដោយផ្ទាល់ ហើយជាការសំខាន់ដែលត្រូវរក្សាទំនាក់ទំនងភ្នែកនឹងភ្នែក ដើម្បីឱ្យការប្រាស្រ័យទាក់ទងអាចមានតុល្យភាពនិងមានការឆ្លើយឆ្លងទៅវិញទៅមក។

**៦. តើអ្នកធ្វើដូចម្តេចប្រសិនបើអ្នកកំពុងនិយាយជាមួយបុគ្គលមានពិការភាព ហើយអ្នកមិនយល់អំពីអ្វីដែលគាត់និយាយមកកាន់អ្នក?**

- អ្នកសួរសំណួរខ្លីហើយច្បាស់ដែលនឹងទទួលបានមកវិញនូវចម្លើយដែលខ្លីហើយច្បាស់។សូមកុំធ្វើជាយល់នៅពេលដែលអ្នកមិនយល់។ ប្រសិនបើអ្នកយល់ទេ សូមនិយាយពាក្យរបស់អ្នកឡើងវិញ រួចសួរសំណួរផ្សេងដែលខ្លីជាងមុន។ បុគ្គលដែលមានកម្សោយមិនមែនជា"ជនរងគ្រោះ"ទេ ហើយមិនគួរថាគាត់ថាជាជនរងគ្រោះដោយសារតែកម្សោយរបស់គាត់ឡើយ។ គាត់អាចជា "ជនរងគ្រោះ" នៃគ្រោះថ្នាក់ណាមួយប៉ុណ្ណោះ។ ប៉ុន្តែនៅក្នុងករណីនេះ យើងសំដៅលើមូលហេតុនៃកម្សោយរបស់គាត់ វាមិនមែនសំដៅលើបុគ្គលនោះទេ។

## ចម្លើយចំពោះការធ្វើតេស្តការបង្កលក្ខណៈងាយស្រួល

**១. ការបង្កលក្ខណៈងាយស្រួលមានន័យថា ជាការធានាថាហេដ្ឋារចនាសម្ព័ន្ធដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពដោយៈ**

- ជនមានពិការភាព ហើយរួមទាំងកុមារផងដែរ
- ជនមានពិការភាព ហើយរួមទាំងស្ត្រីមានផ្ទៃពោះផងដែរ
- ជនមានពិការភាព ហើយរួមទាំងអ្នកមានរបួសផងដែរ
- សម្រាប់មនុស្សទាំងអស់ដោយមិនគិតពីអាយុ ឬស្ថានភាពណាមួយឡើយ

**២. ឧបសគ្គដែលជនមានពិការភាពអាចរួមមានៈ**

- ផ្នែកសង្គម និងនយោបាយ ឬស្ថាប័ន
- ពាក់ព័ន្ធនឹងឥរិយាបថ ឬអាកប្បកិរិយាបុគ្គល
- ពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងលក្ខណៈផ្ដេកនិងលក្ខណៈបញ្ឈរ
- បរិស្ថានរូបវន្ត

**៣. តើវិធីសាស្ត្រ RECU មានន័យដូចម្តេច?**

- ការទៅដល់ ការចូលក្នុង ការផ្លាស់ទី ការប្រើប្រាស់ (Reach, Enter, Circulate, Use)

**៤. ការបង្កលក្ខណៈងាយស្រួលផ្នែករូបវន្តនៅក្នុងបរិបទអាស៊ីៈ**

- អាចធ្វើឱ្យប្រសើរឡើង តាមរយៈការប្រើប្រាស់ដោះស្រាយ និងសម្ភារៈនៅក្នុងស្រុកជាជម្រើសផ្សេងទៀត
- គួរធ្វើការលើកកម្ពស់ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ដោយមានការចូលរួមយ៉ាងសកម្មពីជនមានពិការភាព

- ការបង្កលក្ខណៈងាយស្រួលត្រូវធ្វើការពិចារណាឱ្យបានឆាប់តាមដែលអាចធ្វើបាននៅពេលកសាងហេដ្ឋារចនាសម្ព័ន្ធថ្មី ឬការជួសជុលអគារឡើងវិញ

### ៥. ការបង្កលក្ខណៈងាយស្រួលអាចសម្រេចបានទាំងស្រុងនៅក្នុងការសាងសង់ ប្រសិនបើៈ

- សេវាសាធារណៈមានបំពាក់ពេញលេញនូវទីកន្លែងបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព

### ៦. នៅពេលធ្វើការកែសម្រួល ឬសាងសង់ទីកន្លែងដែលបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព យើងគួរមានការចូលរួមពីៈ

- រាល់ភាគីពាក់ព័ន្ធ អ្នកឯកទេស អ្នកគ្រប់គ្រង និងអ្នកប្រើប្រាស់ទាំងអស់រួមទាំងជនមានពិការភាពផងដែរ។

### ៧.ការបង្កលក្ខណៈងាយស្រួលគឺជាបុរេលក្ខខណ្ឌចំពោះៈ

- ការប្រើប្រាស់សេវាសាធារណៈ ដូចជាសាលារៀន និងមន្ទីរពេទ្យជាដើម
- ការសម្រេចបាននូវសិទ្ធិផ្សេងៗដូចជាការបោះឆ្នោត ការទទួលបានឱកាសការងារ និងការមានទឹកស្អាតប្រើប្រាស់
- ការមានលទ្ធភាពអាចធ្វើសកម្មភាពកម្សាន្តសប្បាយផ្សេងៗ (ការប្រើប្រាស់កន្លែងលេងសម្រាប់កុមារ ការចូលរួមក្នុងកម្មវិធីបង្ហាញសាធារណៈ ការទៅលេងនៅតំបន់ឆ្នេរ។ល។)

### ៨. ដើម្បីកែសម្រួលការបង្កលក្ខណៈងាយស្រួលជាការសំខាន់ដែលត្រូវៈ

- ធ្វើកែសម្រួលការបង្កលក្ខណៈងាយស្រួលនៅលើធ្យោបាយដឹកជញ្ជូនសាធារណៈ និងឯកជន
- ធានាថាខ្សែច្រវាក់នៃការផ្លាស់ទីពីផ្ទះទៅកន្លែងផ្តល់សេវាមិនមានការខូចខាត ឬធានាថា ខ្សែច្រវាក់ទាំងមូលមិនមានការលំបាកសម្រាប់ជនមានពិការភាព។
- ពិចារណាអំពីតម្រូវការរបស់ជនមានពិការភាពនៅពេលរៀបចំកម្មវិធីណាមួយ

### ៩. ការកែលម្អការបង្កលក្ខណៈងាយស្រួលនៅក្នុងបរិស្ថានដែលបានសាងសង់ឡើងៈ

- កាន់តែមានប្រសិទ្ធភាព ប្រសិនបើបានដាក់បញ្ចូលទៅក្នុងដំណាក់កាលរចនាអគារតាំងពីដំបូង
- អាចផ្តល់ជូនសម្រាប់អគារមានស្រាប់ ប៉ុន្តែលទ្ធផលចុងក្រោយគឺមានបញ្ហារាំងស្ទះជាច្រើន (ទំហំទីកន្លែង ទ្រង់ទ្រាយអគារ ទីតាំងអគារ។ល។)

### ១០. ការសម្របសម្រួលសមស្របមានន័យថាៈ

- អង្គភាពមានភាពបត់បែនដើម្បីអនុវត្តការកែសម្រួលជាក់លាក់ដើម្បីស្របតាមតម្រូវការជនមានពិការភាពដើម្បីធានាការចូលរួមនិងបរិយាបន្នពួកគាត់។
- ការរៀបចំកិច្ចប្រជុំនៅនឹងកន្លែងដែលផ្តល់លក្ខណៈងាយស្រួលសម្រាប់ជនដែលមានការលំបាកក្នុងការផ្លាស់ទី ឬនៅជិតផ្ទះរបស់ពួកគាត់ គឺជាការសម្របសម្រួលសមស្រប។

### ១១. តើអ្វីទៅជាការរចនាជាសកល?

- ទំហំ ឬទីកន្លែងសមស្របដែលត្រូវបានផ្តល់ជូនដើម្បីឱ្យមានភាពងាយស្រួលចូលដល់ ចូលទៅកាន់ សម្របសម្រួល និងប្រើប្រាស់ ទោះជាអ្នកប្រើប្រាស់នោះមានទំហំដងខ្លួន រូបរាង ឬការផ្លាស់ទីយ៉ាងណាក៏ដោយ វាគឺជាគោលការណ៍មួយនៃការរចនាជាសកល។
- "ការរចនាជាសកល" សំដៅលើការរចនាផលិតផល បរិស្ថាន កម្មវិធី និងសេវាដើម្បីឱ្យបុគ្គលទាំងអស់អាចប្រើប្រាស់បានច្រើនបំផុតតាមដែលអាចធ្វើបានដោយពុំចាំបាច់មានការសម្របសម្រួល ឬការរចនាជាពិសេស។

- “ការរចនាជាសកល” មានគោលដៅជួយសម្រួលដល់ការរស់នៅសម្រាប់បុគ្គលទាំងអស់ដោយធ្វើឱ្យផលិតផល ការទំនាក់ទំនង និងបរិស្ថានដែលបានបង្កើតឡើងកាន់តែអាចប្រើប្រាស់បានដោយមនុស្សជាច្រើននៅក្នុងតម្លៃតិចតួច ឬគ្មានការចំណាយបន្ថែម។
- ត្រូវដាក់បញ្ចូលឧបករណ៍ជំនួយសម្រាប់ក្រុមមានពិការភាពណាមួយដែលមានតម្រូវការឧបករណ៍ទាំងនេះ។

### ឯកសារចែកជូន ១.២.១៖ និយមន័យអំពីកម្សោយនិងពិការភាព

**កម្សោយ៖** បញ្ហាមុខងាររាងកាយ (មុខងារផ្លូវចិត្ត មុខងារវិញ្ញាណ មុខងារសំឡេង និងការនិយាយ) ឬរចនាសម្ព័ន្ធរាងកាយ (សរសៃប្រសាទ ប្រព័ន្ធសាច់ដុំ និងប្រព័ន្ធសរសៃឈាមបេះដូង) ដូចជាការខូចខាតខ្លាំង ឬការបាត់បង់ទាំងស្រុងតែម្តង (ដូចជាការកាត់អវៈយវៈ ជើងខ្វេរ ជើងខ្វិន ពិការចលករខួរក្បាល)។ កម្សោយអាចមានលក្ខណៈបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ថយចុះ នៅថេរ ម្តងម្កាល ឬជាប់ជាប្រចាំ។ បុគ្គលដែលមានកម្សោយតែងតែជួបប្រទះឧសគ្គក្នុងការចូលរួមនៅក្នុងការសិក្សា សុខាភិបាល ការងារ នយោបាយ និងជីវិតសាធារណៈ។

**ពិការភាព៖** ត្រូវបានសង្គមបកស្រាយថាជាសមត្ថភាពមានកម្រិតរបស់បុគ្គលដែលមានកម្សោយដោយសារតែឧបសគ្គផ្នែកឥរិយាបថ ស្ថាប័ន ឬបរិស្ថានរូបវន្តដែលធ្វើឱ្យពួកគាត់មិនអាចចូលរួមនៅក្នុងសកម្មភាពសង្គមបានពេញលេញ។

**ជនមានពិការភាព៖** យោងតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនមានពិការភាព “ជនមានពិការភាពជាបុគ្គលដែលមានកម្សោយរាងកាយ ផ្លូវចិត្ត សតិបញ្ញា ឬវិញ្ញាណរយៈពេលយូរដែលមានអន្តរកម្មជាមួយនឹងឧបសគ្គផ្សេងៗដែលអាចរាំងដល់ការចូលរួមរបស់ពួកគាត់នៅក្នុងសង្គមដោយពេញលេញនិងប្រកបដោយប្រសិទ្ធភាពនិងស្មើភាពគ្នាជាមួយនឹងអ្នកដទៃ”។ និយមន័យនេះមានន័យថា កម្សោយអាចក្លាយជាពិការភាពនៅពេលបុគ្គលនោះត្រូវប្រឈមនឹងស្ថានភាពបរិស្ថានជុំវិញដែលមិនត្រូវបានរចនាដើម្បីជួយបង្កលក្ខណៈងាយស្រួលសម្រាប់ពួកគេ។ នៅក្នុងន័យម៉្យាងទៀត បរិស្ថានជុំវិញមានការបង្កលក្ខណៈងាយស្រួលកាន់តែល្អប្រសើរអាចធ្វើឱ្យបុគ្គលដែលមានកម្សោយប្រើប្រាស់សិទ្ធិរបស់គាត់ស្មើមុខមាត់ជាមួយនឹងអ្នកដទៃ។ ការរើសអើងដោយផ្អែកលើមូលហេតុកម្សោយមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសិទ្ធិលំនៅដ្ឋាន ការដឹកជញ្ជូន វប្បធម៌ និងលទ្ធភាពចេញចូលទីកន្លែងសាធារណៈ និងលទ្ធភាពទទួលបានសេវាផ្សេងៗ។ (ចំណុចត្រូវចងចាំ៖ ចាំបាច់ត្រូវធ្វើការបែងចែក “ពិការភាព” (ផ្តោតលើបញ្ហាសង្គម) ពី “កម្សោយ” (ផ្តោតលើបញ្ហាវេជ្ជសាស្ត្រ)។ ដើម្បីបែងចែកបញ្ហាទាំងពីរនេះ គេត្រូវអនុវត្តវិធានការនិងវិធីសាស្ត្រជាក់លាក់ឆ្ពោះទៅរកដំណោះស្រាយ។

ខាងក្រោមគឺជាដំណើរការបង្កើតឱ្យមានពិការភាព។




រូបភាពទី ១៣៖ ដំណើរការបង្កើតពិការភាព

## ឯកសារចែកជូន ១.២.២៖ ផលប៉ះពាល់នៃកម្សោយ និងវាក្យសព្ទត្រឹមត្រូវ

**១. កម្សោយរូបរាងកាយ** - ប៉ះពាល់ដល់ការធ្វើចលនាខ្លួនប្រាណ និង/ឬ រូបរាងកាយ។

**២. កម្សោយវិញ្ញាណ** - ប៉ះពាល់ដល់ការមើល ការស្តាប់ ការនិយាយ ការហិតក្លិន ការដឹងរសជាតិ ស្មារតី/អារម្មណ៍ និង/ឬតុល្យភាពផ្នែករាងកាយ។

**៣. កម្សោយផ្នែកសតិបញ្ញា** - ប៉ះពាល់ធ្ងន់ធ្ងរដល់បញ្ញារបស់មនុស្ស និងមុខងារខួរក្បាល និងឥរិយាបថសម្របសម្រួល។ កម្សោយនេះតែងតែកើតមានឡើងនៅមុនពេលកុមារឈានដល់អាយុ១៨ឆ្នាំ។ បញ្ហានេះ ក៏អាចហៅថាជាអសមត្ថភាពផ្នែកសិក្សាផងដែរ។ បុគ្គលដែលអសមត្ថភាពផ្នែកសិក្សាប្រឈមនឹងការលំបាកក្នុងការបញ្ជូនសារទៅកាន់ខួរក្បាលដោយសារតែបញ្ហាច្របូកច្របល់ ដូច្នេះទើបធ្វើឱ្យពួកគេមានការលំបាកក្នុងការរៀនសូត្រ និងក្នុងផ្នែកការសិក្សាមួយ ឬច្រើន។ អ្នកដែលមានពិការភាពផ្នែកសិក្សាមិនមែនមានបញ្ហា "លូតលាស់យឺតយ៉ាវផ្នែកសតិបញ្ញា" ឬ "ជាអ្នករៀនមិនទាន់គេ" នោះទេ។ អសមត្ថភាពផ្នែកសិក្សា គឺគ្រាន់តែជាពាក្យទូទៅដែលសំដៅទៅលើក្រុមចម្រុះនៃពិការភាពដែលបានបែងចែកទៅតាមការលំបាកធ្ងន់ធ្ងរនៅក្នុងការសិក្សានិងការប្រើប្រាស់ការស្តាប់ ការនិយាយ ការអាន ការសរសេរ ការគិតពិចារណា ឬសមត្ថភាពគណនាគណិតវិទ្យាដោយសារតែការដំណើរការមិនប្រក្រតីនៃប្រព័ន្ធប្រសាទតែប៉ុណ្ណោះ។

**៤. ជំងឺផ្លូវចិត្ត ឬកម្សោយផ្លូវចិត្ត** - ប៉ះពាល់និងបន្ទុចបង្អាក់ដល់ការគិត អារម្មណ៍ សមត្ថភាពក្នុងការទំនាក់ទំនងជាមួយអ្នកដទៃរបស់បុគ្គលម្នាក់និងសមត្ថភាពក្នុងការដោះស្រាយបញ្ហាត្រូវការប្រចាំថ្ងៃរបស់ខ្លួន។ ជំងឺផ្លូវចិត្តរួមមានជំងឺមួយចំនួនដូចជា ជំងឺវិកលចរិតនិងជំងឺធ្លាក់ទឹកចិត្តធ្ងន់ធ្ងរ។ ជំងឺនេះអាចប៉ះពាល់ទៅដល់មនុស្សគ្រប់វ័យ ពូជសាសន៍ សាសនា ឬប៉ះពាល់ដល់ការប្រាក់ចំណូល និងមិនមែនបណ្តាលមកពីភាពទន់ខ្សោយនៃបុគ្គលម្នាក់ៗ បាត់បង់លក្ខណៈណាមួយ ឬការខ្វះការទំនុកបំរុងចិញ្ចឹមបីបាច់ថែរក្សារបស់បុគ្គលម្នាក់នោះទេ។

**៥.កម្សោយច្រើនប្រភេទ**-អ្នកដែលមានបញ្ហាកម្សោយលើសពីមួយប្រភេទ។ឧទាហរណ៍៖អ្នកដែលមានបញ្ហាដោនស៊ីនដ្រូម (អសមត្ថភាពផ្នែកសិក្សា) ក៏អាចមានបញ្ហាកម្សោយការស្តាប់និង/ឬគំហើញផងដែរ។អ្នកដែលមានជំងឺពិការចលករខួរក្បាលអាចនឹងមានបញ្ហាពិបាកដើរ និយាយ និងរៀនសូត្រ ឬអ្នកអាចមានបញ្ហាថ្លង់និងងងឹតភ្នែកដែរ។

| កម្សោយ | វាក្យសព្ទត្រឹមត្រូវ |
|---|---|
| កម្សោយរូបរាងកាយ | អ្នក ឬជនមានពិការភាពរូបរាងកាយ<br>អ្នក ឬជនមានពិការភាពរូបរាងកាយ<br>អ្នក ឬជនមានពិការភាពផ្នែកចលនា<br>អ្នក ឬជនដែលប្រើប្រាស់ឧបករណ៍ជំនួយក្នុងការធ្វើមល្លាស់ទី (ដូចជាអ្នកដែលប្រើរទេះរុញ) |
| កម្សោយគំហើញ | អ្នក ឬជនដែលពិការភ្នែក<br>អ្នក ឬជនដែលចុះខ្សោយគំហើញ<br>អ្នក ឬជនដែលមានកម្សោយគំហើញ |

| | |
|---|---|
| កម្សោយការស្តាប់ | មនុស្សថ្លង់<br>អ្នក ឬជនដែលមានការលំបាកក្នុងការស្តាប់<br>អ្នក ឬជនដែលមានកម្សោយការស្តាប់ |
| កម្សោយផ្នែកសតិបញ្ញា | អ្នក ឬជនដែលមានពិការភាពផ្នែកសតិបញ្ញា<br>អ្នក ឬជនដែលមានពិការភាពផ្នែកចលករខួរក្បាល<br>អ្នក ឬជនអសមត្ថភាពផ្នែកសិក្សា<br>អ្នកឬជនមានការលំបាកផ្នែកសិក្សា |
| កម្សោយសុខភាពផ្លូវចិត្ត | អ្នក ឬជនមានបញ្ហាសុខភាពស្មារតី<br>អ្នក ឬជនមានតម្រូវការសុខភាពស្មារតី |

## ឯកសារចែកជូន ១.២.៣៖ វិធានមូលដ្ឋានស្តីពីរបៀបក្នុងការទំនាក់ទំនងជាមួយជនមានពិការភាព

ផ្នែកនេះមានផ្តល់ជូននូវវិធានមូលដ្ឋានមួយចំនួនសម្រាប់ឱ្យសិក្ខាកាមអនុវត្តតាមនៅពេលទាក់ទងជាមួយជនមានពិការភាព។

ប្រសិនបើអ្នកមិនបានដឹងច្បាស់អំពីរបៀបនិយាយទៅកាន់ជនមានពិការភាពទេ សូមសាកសួរគាត់ជាមុនសិន។

- **ធ្វើជាខ្លួនឯង** ប្រព្រឹត្តចំពោះជនមានពិការភាពប្រកបដោយការគោរពដូចដែលអ្នកគោរពអ្នកដទៃផ្សេងទៀតអញ្ចឹងដែរ។ ផ្តោតការយកចិត្តទុកដាក់ទៅលើបុគ្គលម្នាក់ៗនិងបញ្ហានៅក្នុងដៃរបស់អ្នក ពោលគឺមិនមែនផ្តោតលើបញ្ហាកម្សោយសរីរាង្គរបស់គាត់នោះទេ។
- **ត្រូវចេះជួយ** ត្រូវសាកសួរជាមុនសិននៅមុនពេលដែលអ្នកចង់ជួយគាត់។ ហាមជួយនៅគ្រប់ពេលវេលាទាំងអស់។ ប្រសិនបើគាត់ទទួលយកជំនួយពីអ្នក នោះអ្នកត្រូវតែស្តាប់ ឬស្នើសុំការណែនាំពីគាត់ជាមុន។ ត្រូវទុកឱ្យគាត់ធ្វើអ្វីដែលគាត់ចង់ធ្វើប្រកបដោយសេចក្តីថ្លៃថ្នូរសម្រាប់ពួកគាត់។
- **ភាសា** ហាមប្រើប្រាស់វាក្យសព្ទបែបបន្ទាបតម្លៃដែលហួសសម័យដូចជាពាក្យ "មិនគ្រប់ទឹក" "អាកំបុតអាកំបាក់" "អាពិការ ឬ "ពិការ"។ ប្រសិនបើអ្នកមិនដឹងច្បាស់ថាត្រូវប្រើពាក្យពេចន៍អ្វីនោះទេ សូមកុំមានការស្ទាក់ស្ទើរនៅក្នុងការសួរជាមុនសិន។
- **ការទំនាក់ទំនង** និយាយដោយផ្ទាល់ទៅកាន់ជនមានពិការភាព មិនមែនគ្រាន់តែនិយាយជាមួយអ្នកដែលមកជាមួយគាត់ ដូចជាអ្នកថែទាំ ឬអ្នកបកប្រែនោះទេ។ មិនត្រូវនិយាយចំអកទៅលើជនមានពិការភាពនោះទេ ពួកគេអាចនឹងដឹងភ្លាមៗ។
- **ការប៉ះពាល់** ត្រូវដឹងឱ្យបានច្បាស់អំពីការប៉ះពាល់រូបរាងកាយ។ ត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អ្នកជាមុនសិន មុនពេលអ្នកធ្វើការប៉ះពាល់រូបរាងកាយអ្នកមានបញ្ហាខ្សោយគំហើញ ឬជនពិការភ្នែក។ ជនមានពិការភាពចាត់ទុកផ្នែកនៃឧបករណ៍ជំនួយរបស់ពួកគេជាសម្ភារផ្ទាល់ខ្លួនរបស់ពួកគេ។ ត្រូវគោរពឧបករណ៍ជំនួយរបស់គេ ដូចជារទេះរុញ ឈើច្រត់រាវផ្លូវ ឬឈើច្រត់ដោយប្រើដៃទាំងសងខាងជាដើម។
- **កុំធ្វើការប៉ាន់ស្មាន** ជនមានពិការភាព គឺដូចជាមនុស្សគ្រប់គ្នាអញ្ចឹងដែរគឺជាអ្នកដែលដឹងច្បាស់អំពីខ្លួនឯង៖ ពួកគេ

ដឹងច្បាស់អំពីអ្វីដែលពួកគេចូលចិត្តនិងមិនចូលចិត្ត និងអ្វីដែលពួកគេអាចធ្វើបាននិងធ្វើមិនបាន។ សូមកុំធ្វើការសម្រេចចិត្តជំនួសពួកគេអោយសោះ។

- **ការបង្កលក្ខណៈងាយស្រួល** លើកកម្ពស់ការបង្កលក្ខណៈងាយស្រួលនៅកន្លែងរបស់អ្នក៖ ដាក់បញ្ចូលទៅក្នុងគោលនយោបាយនិងការដំណើរការជាក់ស្តែង។ ឧទាហរណ៍៖ នៅពេលរៀបចំផែនការប្រជុំ ឬកម្មវិធីត្រូវធ្វើការប្រមើលមើល ឬសួររកតម្រូវការជាក់លាក់ដែលជនមានពិការភាពត្រូវការជាមុនសិន។ ត្រូវប្រើប្រាស់ពុម្ពអក្សរដែលងាយស្រួលអាននៅក្នុងឯកសារផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរ។ ប្រសិនបើបញ្ហាទាំងនោះមិនអាចដោះស្រាយបានទេ សូមប្រាប់ឱ្យពួកគាត់បានដឹងជាមុន។

*សួរ*

*ពួកគាត់*

*ជាមុនសិន!*

**សារគន្លឹះ៖**

- ជនមានពិការភាពគឺជាជនអាទិភាព។
- ជនមានពិការភាពគឺមិនមែនជាក្រុមដូចគ្នានោះទេ មនុស្សគ្រប់រូបមានលក្ខណៈពិសេសរៀងៗខ្លួន។
- ជនមានពិការភាពមានសមត្ថភាព ដូចអ្នកដទៃទៀតដែរ។
- ជនមានពិការភាពមានតម្រូវការជាមូលដ្ឋានដូចគ្នាទៅនឹងមនុស្សគ្រប់គ្នាដែរ។
- ជនមានពិការភាពមួយចំនួនមានតម្រូវការជាក់លាក់ (ឧបករណ៍ជំនួយ អ្នកថែទាំជាដើម) ភាគច្រើនគឺដោយសារតែឧបសគ្គ បរិស្ថានជុំវិញដែលពួកគេជួបប្រទះ ពោលគឺមិនមែនដោយសារតែកម្សោយរបស់ពួកគាត់នោះទេ។
- ពិការភាព គឺមិនមានជាបញ្ហាសុខភាពនោះទេ ប៉ុន្តែភាគច្រើនគឺជាបញ្ហាសង្គម និងសិទ្ធិ។

## ឯកសារចែកជូន ១.២.៤៖ គំរូនៃពិការភាព

### សេចក្តីផ្តើមនិងប្រវត្តិ

កាលដើមឡើយពិការភាពត្រូវបានគេចាត់ទុកថាជាពាក្យពេចន៍ជំនឿ ឬសាសនា។ ឧទាហរណ៍៖ជនមានពិការភាព ត្រូវបានគេចាត់ទុកថាត្រូវបានខ្មោចបីសាច ឬវិញ្ញាណគ្រប់គ្រង។ ពិការភាពត្រូវបានគេយល់ឃើញថាជាការដាក់ទណ្ឌកម្មចំពោះទង្វើខុសឆ្គងដែលបានប្រព្រឹត្តកាលពីពេលកន្លងមក។ ទស្សនៈយល់ឃើញទាំងនេះ ក៏នៅតែកើតមានក្នុងពេលបច្ចុប្បន្ននៅក្នុងសង្គមបែបប្រពៃណីជាច្រើនផងដែរ។ នៅក្នុងសតវត្សរ៍ទី១៩និងទី២០ ការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្រនិងឱសថបានជួយបង្កើតឱ្យមានការយល់ដឹងថាពិការភាព គឺមានមូលដ្ឋានមកពីកត្តាជីវសាស្ត្រ និងវេជ្ជសាស្ត្រ។ គំរូបែបវេជ្ជសាស្ត្របានធ្វើឱ្យបញ្ហាពិការភាពក្លាយជាបញ្ហាបុគ្គលហើយផ្តោតការយកចិត្តទុកដាក់ទៅលើការព្យាបាលនិងការផ្តល់ការថែទាំវេជ្ជសាស្ត្រដោយអ្នកមានវិជ្ជាជីវៈ។ ក្រោយមកទៀត នៅក្នុងទស្សវត្សឆ្នាំ១៩៦០ និងនៅឆ្នាំ១៩៧០ ការយល់ឃើញរបស់បុគ្គលផ្ទាល់ខ្លួន និងផ្នែកវេជ្ជសាស្ត្រចំពោះបញ្ហាពិការភាពមានការលំបាកខ្លាំងដោយសារតែគំរូបែបសង្គមចំពោះពិការភាព។ គំរូបែបសង្គម គឺផ្តោតទៅលើឧបសគ្គសង្គមនិងការរើសអើងទៅលើជនមានពិការភាពដែលកំពុងជួបប្រទះ។ ពិការភាពក៏ត្រូវបានកំណត់និយមន័យឡើងវិញថា វាជាបញ្ហារបស់សង្គមជាជាងបញ្ហារបស់បុគ្គលផងដែរ ហើយដំណោះស្រាយក៏ត្រូវបានផ្តោតការយកចិត្តទុកដាក់ជាងមុនទៅលើការលុបបំបាត់រនាំងឧបសគ្គនិងការផ្លាស់ប្តូរឥរិយាបថ

សង្គម ពោលគឺមិនត្រឹមតែជាការព្យាបាលបែបវេជ្ជសាស្ត្រប៉ុណ្ណោះទេ។ អនុសញ្ញាស្តីពីសិទ្ធិជនពិការបានផ្តោតការយកចិត្តទុកដាក់ទៅលើតម្រូវការក្នុងការ បញ្ជ្រាបយេនឌ័រនិងបញ្ហាពិការភាពនៅក្នុងសកម្មភាពប្រចាំថ្ងៃ។ អភិក្រមមួយចំនួនចំពោះបញ្ហាពិការភាព។ នៅក្នុងឯកសារចែកជូននេះ យើងបានលើកឡើងអំពីគំរូវេជ្ជសាស្ត្រនិងសប្បុរស( គំរូនីមួយៗ) ដែលផ្តោតលើឧបសគ្គចំពោះការចូលរួមរបស់ជនមានពិការភាព។

**គំរូពិការភាព៖** ពិការភាពត្រូវបានគេមើលឃើញក្នុងទិដ្ឋភាពផ្សេងៗគ្នា

**១. គំរូវេជ្ជសាស្ត្រសម្រាប់ពិការភាព (គំរូផ្ទាល់ខ្លួន)៖** គំរូវេជ្ជសាស្ត្រជឿថា៖ ដោយសារតែអ្នកមានកម្សោយ នោះបញ្ហាគឺជារបស់អ្នក ហើយគិតថាយើងអាចដោះស្រាយបញ្ហានេះជូនអ្នក។ គំរូនេះជារឿយៗគឺទទួលបរាជ័យនៅពេលដែលមនុស្សមិនត្រូវការដំណោះស្រាយ ឬមិនអាចដោះស្រាយបាន ហើយបញ្ហាគឺមិនមែនគ្រាន់តែកម្សោយសរីរាង្គរបស់ពួកគេប៉ុណ្ណោះទេ ពោលគឺវាជាការមិនរាប់បញ្ចូលពួកគាត់ទៅក្នុងសកម្មសង្គម។

**“អ្នកមានបញ្ហាហើយ ទុកឱ្យយើងដោះស្រាយឱ្យអ្នក”**




រូបភាព ១៤៖ គំរូវេជ្ជសាស្ត្រនៃពិការភាព

**កំណត់សម្គាល់៖** រូបភាពនេះ គឺរូបភាពតំណាងកាន់តែច្បាស់អំពីអ្វីដែលគំរូវេជ្ជសាស្ត្របានបង្កើតឡើង និងរបៀបក្នុងការកម្រិតផលប៉ះពាល់ ប្រសិនបើផ្តោតទៅលើតែការបង្កើតធនធានមនុស្ស(វិជ្ជាជីវៈ) ឬទីតាំងដែលដោះស្រាយកម្សោយ និងមិនមែនដោះស្រាយផ្នែកដ៏ធំនៃបញ្ហាទាំងមូល។ ចំណុចខាងក្រោមរៀបរាប់អំពីគំរូវេជ្ជសាស្ត្រ៖

- កម្សោយ គឺមិនមែនជាបញ្ហានោះទេ
- ការយល់ដឹងបែបបុរាណអំពីពិការភាព
- ផ្តោតលើកម្សោយរបស់មនុស្សម្នាក់ៗថាជាឧបសគ្គ
- ស្វែងរក “ការព្យាបាល” ឬ “កែលម្អ” ចំពោះបុគ្គលដើម្បី “សម្រប” ទៅតាមសង្គម
- កំណត់ជនមានពិការភាពថាគ្រាន់តែជាអ្នកជំងឺដែលត្រូវការជំនួយវេជ្ជសាស្ត្រ
- បែងចែកជនមានពិការភាពពីអ្នកដទៃ

- ផ្តល់តែជំនួយវេជ្ជសាស្ត្រដែលផ្តល់ជូនដោយអ្នកជំនាញ
- មានទំនោរថាចំណាយប្រាក់ច្រើនដើម្បីផ្តល់អត្ថប្រយោជន៍ជូនជនមានពិការភាពមួយចំនួនតូច

**២. គំរូសប្បុរសធម៌៖** គំរូសប្បុរស គឺបង្កើតឡើងដោយក្រុមជំនឿបែបសាសនា ដែលមានអារម្មណ៍ថាជាសំណាងអាក្រក់ ឬភ័ព្វវាសនាមិនល្អធ្លាក់មកលើជនមានពិការភាព ហើយគិតថាពួកគេមិនត្រូវទទួលរងទុក្ខលំបាកនេះតែម្នាក់ឯងនោះទេ ដូច្នេះត្រូវផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ សម្លៀកបំពាក់ អាហារដើម្បីជួយសម្រួលដល់ទុក្ខលំបាករបស់ពួកគេ។ ពួកគេត្រូវបានគេមើលឃើញថាជាមនុស្សគ្មានកម្លាំងនិងត្រូវការជំនួយសប្បុរសធម៌។

“យើងមានអារម្មណ៍ថាអាណិតអ្នកណាស់ ទុកឱ្យយើងជួយអ្នកបន្តិចបន្តួច”




រូបភាព ១៥៖ គំរូសប្បុរសនៃពិការភាព

**កំណត់សម្គាល់៖** រូបភាពនេះ គឺរូបភាពតំណាងកាន់តែច្បាស់អំពីអ្វីដែលគំរូសប្បុរសបង្កើត ឡើង និងរបៀបក្នុងការកម្រិតផលប៉ះពាល់ ប្រសិនបើផ្តោតលើអ្នកដែលគិតអវិជ្ជមានផ្តោតលើតម្រូវការ និងពិការភាពដែលធ្វើឱ្យពួកគេគ្មានអំណាច។ សកម្មភាពនានាដែលផ្តោតលើ “ការជួយគាំទ្រ” ជនមានពិការភាពដែលគ្មាននរណាជួយពួកគាត់និងទុកគាត់អោយស្ថិតនៅខាងក្រៅសង្គម “ទូទៅ”។ គំរូនេះត្រូវបានកំណត់ចរិតលក្ខណៈដូចខាងក្រោម៖

- ពិការភាពគឺជាបញ្ហារបស់មនុស្ស
- ពួកគេត្រូវបានគេមើលឃើញថា “គ្មានសំណាង” “ពឹងផ្អែកលើអ្នកដទៃ” ឬ “គ្មានអ្នកជួយ”
- ពួកគេត្រូវបានចាត់ទុកថាជាអ្នកត្រូវការការអាណិតអាសូរនិងជំនួយសប្បុរសធម៌
- សន្មត់ថាជនមានកម្សោយ មិនអាចរួមចំណែកក្នុងសង្គម ឬជួយខ្លួនឯងបាននោះទេ
- ភាគច្រើនផ្តល់ជូនពួកគេនូវប្រាក់ ឬកាដូ ដូចជាអាហារនិងសម្លៀកបំពាក់
- ជនមានពិការភាពក្លាយជាអ្នកទទួលសេវាសុខុមាលភាពនិងការគាំទ្ររយៈពេលវែង
- ជំនួយត្រូវបានផ្តល់ជូនស្ថាប័នជំនាញ និងមិនត្រូវបានបញ្ជ្រាបការអភិវឌ្ឍនោះទេ
- ជនមានពិការភាពត្រូវបានគេមើលឃើញនិងចាត់ទុកថាក្រុមដាច់ដោយឡែក

**៣. គំរូសង្គម៖** គំរូសង្គមទទួលស្គាល់អំពីមូលហេតុដែលមនុស្សមានការលំបាកគឺដោយសារតែការមិនរាប់បញ្ចូលក្នុងសង្គមដែលបង្កឱ្យមានភាពក្រីក្រហើយប្រសិនបើសង្គមផ្លាស់ប្តូរនោះជីវិតរបស់ជនមានពិការភាពនឹងកាន់តែល្អប្រសើរ។

“សង្គមមានបញ្ហាអ្វីម៉្យាងហើយ ត្រូវធ្វើឱ្យសង្គមកាន់តែមានបរិយាបន្នភាព”




រូបភា ១៦៖ គំរូសង្គមនៃពិការភាព

**កំណត់សម្គាល់៖** រូបភាពនេះ គឺរូបភាពតំណាងកាន់តែច្បាស់អំពីអ្វីដែលគំរូវេជ្ជសាស្រ្តបានបង្កើតឡើង និងរបៀបក្នុងការកម្រិតផលប៉ះពាល់ ប្រសិនបើផ្តោតទៅលើតែការបង្កើតធនធានមនុស្ស(ជំនាញ) ឬទីតាំងដែលដោះស្រាយបញ្ហាពិការភាព និងមិនដោះស្រាយផ្នែកដ៏ធំនៃបញ្ហា។

សកម្មភាពនានា ផ្តោតទៅលើការអនុវត្តបែបបរិយាបន្ន ហើយអភិក្រមនេះ មើលឃើញជនមានពិការភាពថាជាផ្នែកមួយរបស់សង្គមដ៏ធំ។ គំរូសង្គមនេះ មានដំណើរការដូចខាងក្រោម៖

- ផ្តោតលើសង្គមថាជាបញ្ហាពោលគឺមិនមែនជនមានពិការភាពនោះទេ
- ចាត់ទុកជនមានពិការភាព ជាផ្នែកមួយនៃសង្គម ពោលគឺមិនមែនជាក្រុមដាច់ដោយឡែកនោះទេ
- មនុស្សនឹងមានពិការភាព ដោយសារតែសង្គមបដិសេធសិទ្ធិ និងឱកាសរបស់ពួកគេ
- មើលឃើញបញ្ហាពិការភាពថាជាលទ្ធភាពកម្សោយរបស់សង្គម
- តម្រូវការនិងសិទ្ធិរបស់ជនមានពិការភាពគឺដូចគ្នាទៅនឹងអ្នកមិនមានពិការភាពដែរ ឧទាហរណ៍៖ កម្មសិទ្ធិ សុខភាព ការស្រលាញ់ ការអប់រំ និងការងារ។
- សកម្មភាពនានាផ្តោតលើការកំណត់និងការលុបចោលនូវឧបសគ្គឥរិយាបថ បរិស្ថាន និងស្ថាប័នដែលរារាំងដល់ការធ្វើបរិយាបន្នជនមានពិការភាព។

**៤. គំរូផ្អែកលើសិទ្ធិ៖** គំរូផ្អែកលើសិទ្ធិ គឺជាជំហានមួយទៀតដែលហួសពីគំរូសង្គម ហើយមិនមែនគ្រាន់តែមានអារម្មណ៍ថាសង្គមគឺជាប្រភពនៃបញ្ហានោះទេ ប៉ុន្តែថែមទាំងគិតថាដំណោះស្រាយគឺស្ថិតនៅលើបញ្ហាសិទ្ធិមនុស្ស មិនមែនការមានសេដ្ឋកិច្ចល្អប្រសើរ នៅពេលដែលយើងមានពេល យើងនឹងដោះស្រាយបញ្ហានោះ។

“បញ្ហាគឺនៅត្រង់បញ្ហាសិទ្ធិមនុស្ស យើងត្រូវតែស្វែងរកមធ្យោបាយដើម្បីដោះស្រាយបញ្ហានោះ”




រូបភាព ១៧៖ គំរូផ្អែកលើសិទ្ធិនៃពិការភាព

**រូបកំណត់សម្គាល់៖** រូបភាពនេះ គឺរូបភាពតំណាងកាន់តែច្បាស់អំពីគំរូផ្អែកលើសិទ្ធិដែលពិនិត្យមើលទៅលើផ្នែកច្បាប់ និងនីតិវិធីដែលរើសអើង និងការប្រើប្រាស់ជាក្របខណ្ឌសម្រាប់ការផ្លាស់ប្តូរ។

## ឯកសារចែកជូន ២.១៖ និយមន័យនៃការបង្កលក្ខណៈងាយស្រួល

សម្រាប់បទដ្ឋានបច្ចេកទេសជាតិស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព បរិស្ថានអាចប្រើប្រាស់បាន ត្រូវតែអនុញ្ញាតឱ្យមានមុខងារបម្លាស់ទីដោយសេរី ប្រកបដោយសុវត្ថិភាព និងអាចប្រើប្រាស់បានទាំងអស់គ្នាដោយមិនប្រកាន់អំពីអាយុ ភេទ ឬលក្ខខណ្ឌអ្វីនោះទេ។ វាគឺជាទីតាំងដែលអាចប្រើប្រាស់បានដោយមនុស្សទាំងអស់គ្នា ដោយមិនមានឧបសគ្គ ប្រកបដោយសេចក្តីថ្លៃថ្នូរ និងមានភាពឯករាជ្យតាមដែលអាចធ្វើទៅបាន។ ប្រសិនបើមិនទទួលបាននូវបរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូន ព័ត៌មាននិងការទំនាក់ទំនងដែលបង្ក លក្ខណៈងាយស្រួលរួមទាំងប្រព័ន្ធព័ត៌មានវិទ្យានិងទំនាក់ទំនង និងការទទួលបានសេវាផ្សេងៗដោយបើកចំហរ ឬផ្តល់ជូនជាសាធារណៈនោះទេ ប្រាកដណាស់ជនមានពិការភាពមិនអាចមានឱកាសស្មើភាពគ្នាសម្រាប់ការចូលរួមនៅក្នុងសង្គមបានទេ ។ បរិស្ថានគ្មានឧបសគ្គគឺជាទីតាំង ឬបណ្តុំសេវាដែលអាចត្រូវបានប្រើប្រាស់ដោយអ្នកគ្រប់គ្នាដោយគ្មានឧបសគ្គរាំងជាមួយនឹងសេចក្តីថ្លៃថ្នូរ និងមានភាពឯករាជ្យតាមដែលអាចធ្វើទៅបាន។ វាមិនមែនគ្រាន់តែសំដៅដល់ការកសាងអគារដែលមានបំពាក់បង្កាន់ដៃនោះទេ។ វារួមបញ្ចូលទាំងការធ្វើអោយតំបន់ទាំងមូលរួមមានទាំងអគារ ផ្លូវដើរ មធ្យបាយដឹកជញ្ជូន សេវាកម្មនានា និងប្រព័ន្ធទាំងមូលដែលងាយស្រួលចេញចូលសម្រាប់គ្រប់មនុស្សគ្រប់រូប។ បរិស្ថានគ្មានឧបសគ្គមិនមែនគ្រាន់តែធ្វើឱ្យមានការផ្លាស់ប្តូរទៅលើតែបរិស្ថានរូបវន្តដែលបានសាងសង់នោះទេ ប៉ុន្តែក៏រួមបញ្ចូលទាំងការផ្លាស់ប្តូរឥរិយាបថរបស់សមាជិកសហគមន៍ អ្នកផ្តល់សេវានានា និងអ្នកបង្កើតគោលនយោបាយ ដើម្បីឱ្យពួកគេទទួលស្គាល់ថាមនុស្សទាំងអស់មានសិទ្ធិផ្លាស់ទីបានដោយសេរី។ ចំណុចនេះមានន័យថាជនមានពិការភាពគប្បីមានអារម្មណ៍ថាត្រូវបានទទួលស្វាគមន៍ដោយសមាជិកសហគមន៍ អ្នកផ្តល់សេវា និងស្ថាប័នទាំងអស់។ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈភាគច្រើននៅក្នុងប្រទេសកម្ពុជាគឺមិនអាចប្រើប្រាស់បានដោយងាយស្រួល ហើយជម្រើសនៃការបម្លាស់ទីគឺនៅមានកម្រិតខ្លាំងសម្រាប់ជនមានពិការភាពដែលប៉ះពាល់ធ្ងន់ធ្ងរទៅលើការទទួលសេវានិងឱកាសសេដ្ឋកិច្ចសង្គម។

## ឯកសារចែកជូន ២.២៖ ការបង្កលក្ខណៈងាយស្រួលនៅក្នុងក្របខណ្ឌច្បាប់

### ចម្លើយដែលអាចមានសម្រាប់សំណួរដែលបានរៀបះ

១. តើអ្នកដឹងអំពីច្បាប់ ឬបទប្បញ្ញត្តិជាតិនិងអន្តរជាតិដែលមានចែងអំពីការបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពដែរទេ? តើគេនិយាយអ្វីខ្លះអំពីការបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព?

- គោលដៅប្រកបដោយចីរភាព (SDGs)នៃរបៀបវារៈឆ្នាំ២០៣០–គោលដៅទី១១៖ ធ្វើឱ្យទីក្រុងនិងលំនៅដ្ឋានមនុស្សមានបរិយាបន្ន សុវត្ថិភាព មានភាពធន់ និងនិរន្តរភាព
- អនុសញ្ញាស្តីពីសិទ្ធិជនពិការ (UNCRPD)- មាត្រា៩ ស្តីពីការបង្កលក្ខណៈងាយស្រួល៖ ប្រការនេះទទួលស្គាល់ការបង្កលក្ខណៈងាយស្រួលថាជាកត្តាគន្លឹះដើម្បីធានាបានថាជនមានពិការភាពពិតជាអាចចូលទៅប្រើប្រាស់បរិស្ថានរូបវន្ត ការដឹកជញ្ជូន ព័ត៌មាន និងការទំនាក់ទំនង រួមមានបច្ចេកវិទ្យា និងប្រព័ន្ធព័ត៌មាន និងទំនាក់ទំនង និងសេវាមូលដ្ឋាននិងសេវាបើកចំហរឬត្រូវបានផ្តល់ជូនសាធារណជនទាំងនៅទីក្រុងនិងជនបទប្រកបដោយភាពស្មើគ្នាជាមួយនឹងអ្នកដទៃ។
- យុទ្ធសាស្ត្រអ៊ីនឈាន់ (គោលដៅទី៣៖ ជំរុញការចូលទៅប្រើប្រាស់បរិស្ថានរូបវន្ត ការដឹកជញ្ជូនសាធារណៈ ព័ត៌មាន និងការទំនាក់ទំនង)
- ច្បាប់ស្តីពីកិច្ចការពារនិងកម្ពស់សិទ្ធិជនពិការនៃប្រទេសកម្ពុជាឆ្នាំ២០០៩ (ច្បាប់នេះកំពុងស្ថិតក្នុងដំណាក់កាលកែសម្រួល) ចែងសង្ខេបអំពីការបង្កលក្ខណៈងាយស្រួលនៅក្នុងជំពូកទី៥។
- ពាក់ព័ន្ធនឹងការប្រើប្រាស់ច្បាប់ជាតិត្រូវអនុវត្តចំពោះទីតាំងសាធារណៈតែប៉ុណ្ណោះ។ ប្រសិនបើបុគ្គលណាម្នាក់សាងសង់ផ្ទះខ្លួនឯងគោលការណ៍ណែនាំអំពីការបង្កលក្ខណៈងាយស្រួលគឺមិនត្រូវបានអនុវត្តឡើយ។

២. តើឯកសារអ្វីដែលត្រូវបានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា ដើម្បីលើកកម្ពស់ និងអនុវត្តការបង្កលក្ខណៈងាយស្រួល?

- អនុសញ្ញាស្តីពីសិទ្ធិជនពិការបានចុះហត្ថលេខានិងផ្តល់សច្ចាប័ននៅក្នុងខែធ្នូ ឆ្នាំ២០១២។
- ច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការនៅខែកក្កដា ឆ្នាំ២០០៩ (បច្ចុប្បន្នច្បាប់នេះកំពុងស្ថិតក្រោមដំណាក់កាលកែសម្រួល)។
- ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ( ផែនការនេះនឹងត្រូវកែសម្រួលរៀងរាល់៥ឆ្នាំម្តង)។
- ប្រកាសអន្តរក្រសួងអំពីស្តង់ដារបច្ចេកទេសស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពលេខ២៤៨ សមប.ប្រក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។
- គោលការណ៍ណែនាំអំពីការបង្កលក្ខណៈងាយស្រួល (បទដ្ឋានបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពឆ្នាំ២០១៨)។ល។

៣. ហេតុអ្វីបានជាការបង្កលក្ខណៈងាយស្រួលមានសារៈសំខាន់?

- ការមិនបង្កលក្ខណៈងាយស្រួល (ឧបសគ្គរូបវន្ត) គឺជាកត្តាបរិស្ថានដែលរឹតត្បិតទៅលើការចូលរួមរបស់ជនមានពិការភាព។ការធ្វើអោយប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្ហាញអំពីមូលដ្ឋានសម្រាប់បង្កើននូវការចូលរួមសម្រាប់ជនមានពិការភាពនិងធានាឱ្យមានសិទ្ធិស្មើគ្នាសម្រាប់ពួកគេជាមួយនឹងអ្នកដទៃ។
- ដោយសារតែវាគឺជាសិទ្ធិនិងគោលការណ៍មូលដ្ឋាន ការបង្កលក្ខណៈងាយស្រួលគឺជាបញ្ហាសិទ្ធិមនុស្សនិងក្តីបារម្ភក្នុងការអភិវឌ្ឍ។

- លទ្ធភាពចូលប្រើប្រាស់គឺជាស្ពានតភ្ជាប់រវាងតម្រូវការពិសេសរបស់ជនមានពិការភាពនិងការធ្វើឱ្យមានបរិយាបន្នសង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។

៤. ហេតុអ្វីបានជាចាំបាច់ត្រូវផ្ដល់ជូនក្រុមងាយរងគ្រោះនិងជាពិសេសជនមានពិការភាពនូវការបង្កលក្ខណៈងាយស្រួលប្រើប្រាស់បរិស្ថានដែលបានសាងសង់ឡើង?

- ដោយសារតែភាពអាចចូលប្រើប្រាស់បានដោយសេរីនិងការប្រើប្រាស់បរិស្ថានដោយមិនចាំបាច់ត្រូវការជំនួយពីខាងក្រៅគឺជាមធ្យោបាយបានតែមួយគត់ក្នុងការឈានទៅដល់កម្រិតពេញចិត្តនៃការធ្វើការងារដោយខ្លួនឯងពីអ្នកដទៃដែលគិតគូរជាសំខាន់ទៅលើការគោរពខ្លួនឯង ការសម្រេចចិត្តដោយខ្លួនឯង និងសម្រាប់ការអភិវឌ្ឍន៍ជំនាញរស់នៅដោយឯករាជ្យ។
- ដោយសារវាគឺជាសិទ្ធិរបស់ពួកគេដែលត្រូវទទួលបាន

៥. តើធ្វើដូចម្ដេចដើម្បីលើកកម្ពស់លទ្ធភាពចូលទៅប្រើប្រាស់នេះឱ្យកាន់តែមានប្រសិទ្ធភាព?

ពាក់ព័ន្ធនឹងលទ្ធភាពនៃការចូលទៅប្រើប្រាស់ ការអនុវត្តច្បាប់ គឺនៅមានកម្រិតនៅក្នុងប្រទេសកម្ពុជាហើយទីតាំងសាធារណៈភាគច្រើន គឺជនមានពិការភាពមិនអាចចូលទៅបានទេ។ សំណង់ថ្មីៗមិនមានរៀបចំនូវការបង្កលក្ខណៈងាយស្រួល។ ការបង្កលក្ខណៈងាយស្រួលអាចត្រូវបានលើកកម្ពស់ទៅតាមវិធីសាស្ត្រខុសៗគ្នា៖

- ការចូលរួមយ៉ាងសកម្មរបស់ជនមានពិការភាព (សកម្មភាពដែលអាចអនុវត្តបាន៖ ពិគ្រោះយោបល់ និងការសន្ទនាជាមួយជនមានពិការភាពដែលអាចឱ្យពួកគេប្រាប់អំពីតម្រូវការ មតិយោបល់ និងការណែនាំរបស់ពួកគេនៅក្នុងដំណើរការនៃការអនុវត្តគោលនយោបាយ និងតាមដានលើគ្រប់គោលនយោបាយនៃការបង្កលក្ខណៈងាយស្រួលស្រាប់ជនមានពិការភាពឱ្យជនមានពិការភាពចូលរួមនៅក្នុងការរៀបចំផែនការគម្រោង តាមដានការសាងសង់ និងព័ត៌មានអំពីគម្រោង។
- លើកកម្ពស់ព័ត៌មាននិងការយល់ដឹង (សកម្មភាពដែលអាចអនុវត្តបាន៖ ផ្សព្វផ្សាយស្តង់ដារបច្ចេកទេសជាតិស្តីពីហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពសម្រាប់ជនមានពិការភាព ជូនដំណឹងដល់អាជ្ញាធរនិងភាគីពាក់ព័ន្ធដែលទទួលខុសត្រូវក្នុងការកែលម្អទីតាំងសាធារណៈ (ផ្លូវដើរ ចំណតយានយន្ត កន្លែងលេងកម្សាន្ត សំណង់) ជូនដំណឹងដល់ជនមានពិការភាពអំពីលក្ខណៈងាយស្រួលសម្រាប់ជនពិការដើម្បីឱ្យពួកគាត់អាចស្នើសុំឱ្យមានអគារដែលមានលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព និងព័ត៌មានផ្សេងៗ សេចក្ដីជូនដំណឹងឬផ្ដល់ព័ត៌មានជូនដល់សាធារណជនទូទៅអំពីការលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពនិងតម្រូវការចៀសវាងការបង្កើតឧបសគ្គក៏ដូចជាគាំទ្រ ការវិនិយោគលើការបង្កភាពងាយស្រួលសម្រាប់ជនមានពិការភាពដែលអាចផ្ដល់ជាប្រយោជន៍ជូនអ្នកទាំងអស់គ្នា។
- រៀបចំផែនការ (សកម្មភាពដែលអាចអនុវត្តបាន៖ បញ្ចូលលក្ខណៈងាយស្រួលសម្រាប់ជនពិការសម្រាប់ការរៀបចំផែនការ និងការបង្កើតដំណាក់កាលនានា រៀបចំផែនការដើម្បីដោះស្រាយបញ្ហាការបង្កលក្ខណៈងាយស្រួល ក៏ដូចជាចាប់ផ្តើមរៀបចំកម្មវិធី ការសាងសង់ ការឱ្យជនមានពិការភាពចូលរួមក្នុងដំណើរការរបៀបចំផែនការគម្រោងដើម្បីតាមដានការសាងសង់និងព័ត៌មានអំពីគម្រោង)។
- ការបណ្ដុះបណ្ដាល (សកម្មភាពដែលអាចអនុវត្តបាន៖ បណ្ដុះបណ្ដាលស្ថាបត្យករ កម្មករសំណង់ និងបុគ្គលិកផ្នែកអភិវឌ្ឍន៍សហគមន៍អំពីបញ្ហាពិការភាពនិងការរចនាការបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាព ធ្វើឱ្យបុគ្គលិកនៅគ្រប់សេវាទាំងអស់ចងចាំអំពីរបៀបក្នុងការផ្ដល់ជំនួយ និងរួមបញ្ចូលទាំងជនមានពិការភាពផងដែរ លើកទឹកចិត្តគំនិតផ្ដួចផ្ដើមនានា ដើម្បីបង្កើត "បទដ្ឋានបច្ចេកទេស" កសាងសមត្ថភាពគ្រូឧទ្ទេសនៅថ្នាក់ជាតិ និងថ្នាក់

ក្រោមជាតិដែលទទួលបន្ទុកគ្រប់គ្រងសំណង់សាធារណៈឬទីតាំងសាធារណៈ បណ្តុះបណ្តាលជនមានពិការភាពនិងអង្គការតំណាងជនពិការ(DPOs)ដើម្បីជួយគាំទ្រគ្រូឧទ្ទេស អាជ្ញាធរ និងស្ថាប័ននានាដើម្បីធ្វើការវាយតម្លៃឧបសគ្គដោយប្រើប្រាស់ឧបក ឬណ៍វាយតម្លៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល។

- ការផ្សព្វផ្សាយ (សកម្មភាពដែលអាចអនុវត្តបាន៖ ផ្សព្វផ្សាយព័ត៌មានតាមរយៈមធ្យោបាយជាច្រើន និងដែលអាចទទួលបានគ្រប់គ្នាដោយព្រីនជាផ្ទាំងធំៗ ការឧបករណ៍បំពងសំឡេងការប្រើភាសាសាមញ្ញការប្រើប្រាស់រូបភាពជាដើម....)។
- ការតាមដាន (សកម្មភាពដែលអាចអនុវត្តបាន៖ ធ្វើការស្ទង់មតិទៅលើកម្រិតនៃភាពពេញចិត្តទៅលើការប្រើប្រាស់សេវាដោយជនមានពិការភាព ធ្វើរបាយការណ៍អំពីការអនុវត្តការបទប្បញ្ញត្តិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលដោះស្រាយបញ្ហានៃការបង្កលក្ខណៈងាយស្រួល...)។

សម្រាប់ព័ត៌មានបន្ថែម សូមមើលសៀវភៅណែនាំបណ្តុះបណ្តាលផ្នែក ២.១)

## ឯកសារចែកជូន ៤.១៖ ឧបសគ្គចំពោះការបង្កលក្ខណៈងាយស្រួល

**ឧបសគ្គចំនួនបីខុសៗគ្នានៃការបង្កលក្ខណៈងាយស្រួល៖**

- **បរិស្ថានរូបវន្ត៖** ភាពមិនបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពនៃទីតាំងមួយនៅក្នុងអគារ ភាពមិនបង្កលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពនៃប្រព័ន្ធដឹកជញ្ជូនសាធារណៈ ភាពមិនអាចប្រើប្រាស់ឧបកណ៍មូលដ្ឋាននិងគ្រឿងសង្ហារិមសាធារណៈដោយជនមានកម្សោយរូបរាកាយ ឧបសគ្គដែលរារាំងជនមានកម្រិតក្នុងការបន្លាស់ទីក្នុងការបម្លាស់ទីពីកន្លែងមួយនៅក្នុងទីក្រុងនិងបរិស្ថានដែលបានសាងសង់មានកម្រិតកម្ពស់ខ្ពស់ទាបខុសគ្នាជាដើម។
- **ឥរិយាបថសង្គម៖** ឧបសគ្គដែលបានបង្កើតឡើងដោយឥរិយាបថមិនមានការគោរព ដែលមិនមានគិតពិចារណាអំពីតម្រូវការរបស់ជនមានពិការភាព ជំនឿអំពីពិការភាព អ្នកយល់ខុសអំពីសមត្ថភាពរបស់ជនមានពិការភាព។
- **ការផ្សព្វផ្សាយ៖** ការមិនមានលក្ខណៈងាយស្រួលសម្រាប់ជនមានពិការភាពនៃព័ត៌មាន និងការផ្សព្វផ្សាយ មើលមិនច្បាស់ (ពុម្ពអក្សរតូច ព័ត៌មានច្រើនពេក គ្មានក្រាហ្វ ឬសញ្ញា) មានពណ៌ឆើតឆាយ និងការរចនាតុបតែច្រើនពេក គ្មានសំឡេង ដែលបង្កើតបានជាឧបសគ្គដែលរារាំងអ្នកដែលមានកម្សោយផ្នែកគំហើញ ស្មារតី ឬផ្នែកសតិបញ្ញាមិនឱ្យទទួលបានព័ត៌មាននិងស្វែងរកផ្លូវទៅកាន់ទីក្រុង និងបរិស្ថានដែលបានសាងសង់។

# ផ្នែកទី ៤៖ ជំនាញសិក្សាបែបមនុស្សធំ

ជាទូទៅយើងគិតថាមនុស្សធំដឹងអំពីរបៀបក្នុងការសិក្សា។ បន្ទាប់ពីនេះយើងទាំងអស់គ្នាបានសិក្សានៅក្នុងសាលារៀន ប៉ុន្តែវាអាចជាឥរិយាបថគ្រោះថ្នាក់ក្នុងការអនុវត្តនៅពេលដែលធ្វើការបណ្តុះបណ្តាលអំពីគំនិតផ្តួចផ្តើមថ្មី។ កម្មវិធីសិក្សាក្នុងសាលារៀន ត្រូវបានបង្កើតឡើងដោយផ្អែកលើទ្រឹស្តីអំពីរបៀបដែលកុមារ និងយុវជនសិក្សា។ តើអ្នកធ្លាប់បានពិចារណាទេថាតើមនុស្សពេញវ័យរៀនដូចគ្នាដែរទេ? មូលហេតុនេះហើយបានជាជំនាញសិក្សាបែបមនុស្សពេញវ័យបានដើរតួនាទីយ៉ាងសំខាន់ក្នុងបញ្ហាទាំងនេះ នៅពេលដែលយើងធ្វើការបណ្តុះបណ្តាលមនុស្សធំនៅក្នុងផ្លូវត្រឹមត្រូវ។ ការដឹងអំពីទំនោរសិក្សារបស់មនុស្សពេញវ័យ គឺជារឿងសំខាន់ខ្លាំងណាស់។ អ្នកអាចបង្កើតកម្មវិធីបណ្តុះបណ្តាលបែបសហការដើម្បីទាញយកប្រយោជន៍នៃគុណភាពដែលសិស្សពេញវ័យមានដូចជាកិច្ចខិតខំប្រឹងប្រែងក្នុងការសិក្សាឯកសារពាក់ព័ន្ធការបញ្ចេញគំនិត តម្រូវការពាក់ព័ន្ធនឹងបទពិសោធន៍ និងការជំរុញទឹកចិត្តក្នុងការពង្រឹងពួកគេ។ កត្តានេះអាចជួយគ្រូបណ្តុះបណ្តាលដែលជាបុគ្គលបង្គោលការបង្កលក្ខណៈងាយស្រួលថ្នាក់ជាតិ ដើម្បីត្រៀមលក្ខណៈរួចរាល់ក្នុងនាមជាគ្រូបណ្តុះបណ្តាលដែលមានជំនាញគ្រប់គ្រាន់ មុនពេលបំពេញតួនាទីក្នុងការអនុវត្តការបណ្តុះបណ្តាលការបង្កលក្ខណៈងាយស្រួលទៅកាន់សិក្ខាកាមមនុស្សពេញវ័យនាពេលអនាគត។

## ១.១ គោលការណ៍សិក្សាបែបមនុស្សធំ[៣]

សម្រាប់មនុស្សពេញវ័យឱ្យសិក្សាប្រកបដោយប្រសិទ្ធភាព ការបណ្តុះបណ្តាលត្រូវតែបង្កើតឡើងនៅក្នុងលក្ខណៈមួយដែលបំពេញតាមគោលការណ៍ស្នូលនៃការសិក្សាបែបមនុស្សធំដូចខាងក្រោម៖

### ១.១.១ ការដឹកនាំខ្លួនឯង

សំណើចំណេះដឹងខុសគ្នាដំបូង គឺថាមនុស្សពេញវ័យ គឺភាពម្ចាស់ការ និងការដឹកនាំខ្លួនឯង មានន័យថា ពួកគេរស់នៅក្រោមកម្រិតនៃការគ្រប់គ្រងខ្លួនឯង និងស្របតាមច្បាប់ ជំនឿ និងគុណតម្លៃរបស់ពួកគេ។ ពួកគេត្រូវដឹងអំពីអត្ថប្រយោជន៍ គុណតម្លៃ និងគោលបំណងនៃកម្មវិធីសិក្សា។ ពួកគេត្រូវដឹងអំពីមូលហេតុដែលពួកគេសិក្សា និងអ្វីដែលពួកគេសិក្សា។ ប្រសិនបើពួកគេមិនពេញចិត្តទៅនឹងគោលបំណងនិងគុណតម្លៃទេ ពួកគេនឹងមានភាពស្ទាក់ស្ទើរក្នុងការចូលរួមក្នុងកិច្ចអន្តរាគមន៍សិក្សានេះ។

### ១.១.២ ការរៀនតាមរយៈការអនុវត្ត

មនុស្សពេញវ័យ សិក្សាតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួន ដូច្នេះ ការអន្តរាគមន៍បណ្តុះបណ្តាល និងសិក្សាត្រូវតែរួមបញ្ចូលនូវការចូលរួមយ៉ាងសកម្ម និងអនុវត្ត និងផ្តល់នូវបច្ចេកទេសដែលអាចអនុវត្តបាន និងវិធីសាស្ត្រដែលនឹងកែលម្អជីវិតរបស់នៅប្រចាំថ្ងៃរបស់ពួកគេ។

### ១.១.៣ ភាពជាប់ពាក់ព័ន្ធ

ខ្លឹមសារនៃកម្មវិធីបណ្តុះបណ្តាលនេះត្រូវតែមានអត្ថន័យ និងមានភាពពាក់ព័ន្ធទៅនឹងការសិក្សារបស់មនុស្សពេញវ័យជីវិតរស់នៅ និងការងាររបស់ពួកគេ។ ពួកគេត្រូវដឹងច្បាស់អំពីមូលហេតុនិងសារៈសំខាន់ចំពោះពួកគេ និងរបៀបដែលខ្លឹមសារនេះអនុវត្តចំពោះជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។ សិស្សត្រូវយល់អំពីការប្រើប្រាស់ ភ្លាមៗនៃ

៣ https://sarahcordiner.com/the-8-fundamental-principles-of-adu/

តម្រូវការសិក្សា។ប្រសិនបើពួកគេមិនដឹងអំពីរបៀបដែលពួកគេអាចអនុវត្តការសិក្សាចំពោះជីវិតនិងតួនាទីផ្ទាល់ខ្លួនគេលើកឡើងថាការជំរុញទឹកចិត្តចំពោះការអន្តរាគមន៍បណ្តុះបណ្តាលនឹងត្រូវតែកាត់បន្ថយឱ្យបាន។

### ១.១.៤ បទពិសោធន៍

សិស្សជាមនុស្សពេញវ័យត្រូវតែអាចលើកឡើងអំពីបទពិសោធន៍ពីមុនរបស់ពួកគេ ដើម្បីជួយដល់ការសិក្សារបស់ពួកគេ។ការបណ្តុះបណ្តាល ត្រូវតែសម្របទៅតាមបរិបទ ដើម្បីប្រើប្រាស់ភាសាដែលពួកគេយល់។ យើងត្រូវតែជ្រើសរើសសេណារីយ៉ូជាករណីនិងឧទាហរណ៍ដែលពួកគេអាចពាក់ព័ន្ធ ក៏ដូចជាយោងទៅលើជីវិតអតីតកាលផ្ទាល់ខ្លួនការងារ និងបទពិសោធន៍សង្គមរបស់ពួកគេ ដើម្បីពាំនាំយកនូវអត្ថន័យនៃការសិក្សាចូលទៅក្នុងពិភពរបស់គេដូចដែលពួកគេបានយល់។

### ១.១.៥ វិញ្ញាណទាំងអស់

សិស្សជាមនុស្សពេញវ័យ ត្រូវការវិធីសាស្ត្ររៀន និងបង្រៀនពហុវិញ្ញាណ។ យើងត្រូវតែធានាថា ការអន្តរាគមន៍សិក្សារបស់ពួកយើង មានបច្ចេកទេសបង្រៀនសមាមាត្រសមស្រប ដែលបំពេញតាមតម្រូវការការស្តាប់ ការមើល ការអាន/ការសរសេរ ការរៀនសូត្រ ការពឹងផ្អែក និងការសិក្សាឯករាជ្យ។

### ១.១.៦ ការអនុវត្ត

សិស្សជាមនុស្សពេញវ័យ គឺជារឿយៗចូលរួមនៅក្នុងការសិក្សាដោយសារតែតម្រូវការបញ្ហាដើម្បីដោះស្រាយ។ ការអនុវត្តជំនាញនៅក្នុងបរិយាកាសគ្រប់គ្រង អនុញ្ញាតឱ្យពួកគេបង្កើនប្រសិទ្ធភាពខ្លួនឯងនៅក្នុងកិច្ចការថ្មីដែលរៀបចំឱ្យពួកគេអនុវត្តការងារដោយខ្លួនឯងនៅខាងក្រៅបរិយាកាសសិក្សា។ សិស្សជាមនុស្សពេញវ័យកាន់តែអនុវត្តជំនាញថ្មីអនុវត្ត សមត្ថភាព ឬការអនុវត្តចំណេះដឹង នោះឥទ្ធិពលអន្តរកាលចំពោះកិច្ចអន្តរាគមន៍សិក្សាគឺកាន់តែមាន។

### ១.១.៧ ការអភិវឌ្ឍផ្ទាល់ខ្លួន

ការចង់បាន និងមហិច្ឆតាពីខាងក្នុងផ្ទាល់ខ្លួនរបស់សិស្សជាមនុស្សពេញវ័យ ត្រូវតែយកមកគិតពិចារណានៅពេលរៀបចំផែនការនិងបង្រៀនកម្មវិធីសិក្សាបែបមនុស្សពេញវ័យ។ នៅពេលដែលសិស្សកាន់តែចម្រើនវ័យទៅមូលហេតុនៃការចូលរួមនៅក្នុងកម្មវិធីសិក្សារបស់ពួកគេ នឹងប្តូរពីកត្តាខាងក្រៅ (ដូចជាដើម្បីទទួលបានការដំឡើងឋានៈ) ទៅជាកត្តាខាងក្នុងដូចជាការសិក្សាចេញពីភាពសប្បាយរីករាយ ឬចំណាប់អារម្មណ៍ក្នុងការសិក្សាអ្វីដែលថ្មី។

### ១.១.៨ ការចូលរួម

កម្មវិធីសិក្សាបែបមនុស្សពេញវ័យមានប្រសិទ្ធភាព បានរៀបចំផែនការសម្រាប់មតិត្រលប់ និងការពិគ្រោះយោបល់របស់សិស្ស។ មនុស្សពេញវ័យ ត្រូវការអារម្មណ៍ ដូចថាពួកគេអារម្មណ៍ទំនួលខុសត្រូវ គ្រប់គ្រង និងការធ្វើសេចក្តីសម្រេចចិត្តលើការរៀនសូត្រអញ្ចឹងដែរ។ ពួកគេត្រូវបានចូលរួមនៅក្នុងការរៀបចំផែនការ ការវាយតម្លៃ និងការពិគ្រោះយោបល់អំពីដំណើរការសិក្សារបស់ពួកគេ ដើម្បីចូលរួមក្នុងការអនុវត្តប្រកបដោយភាពជោគជ័យពេញលេញ។

## ១.២ ជំនាញសម្របសម្រួល និងជំនាញធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធិ[៤]

មនុស្សជាច្រើនមិនបានដឹងថា ពេលខ្លះការសិក្សាមិនមែនធ្វើឡើងនៅក្នុងអំឡុងពេលបណ្តុះបណ្តាលនោះទេ។

៤ ការសម្របសម្រួលការសិក្សារបស់មនុស្សពេញវ័យ ©សហព័ន្ធនិយោជកជាតិសិង្ហបុរី ខែមិថុនា ឆ្នាំ២០១៤

សម្រាប់ការអនុវត្តការសិក្សា គ្រូបណ្តុះបណ្តាល ឬគ្រូឧទ្ទេសត្រូវតែមានជំនាញសម្របសម្រួលនិងជំនាញធ្វើបទបង្ហាញប្រកបដោយប្រសិទ្ធភាពដែលកត្តានេះគឺលើសពីការគ្រាន់តែឈរនៅពីមុខថ្នាក់ហើយចែករំលែកចំណេះដឹងនិងបទពិសោធន៍។

### ១.២.១ ការបង្កើតបរិយាកាសសិក្សាវិជ្ជមាន

ដើម្បីអាចសិក្សាប្រកបដោយប្រសិទ្ធភាព យើងត្រូវតែកសាងនិងរក្សាការទំនាក់ទំនងជាមួយសិស្ស។ ខាងក្រោមនេះគឺជាគន្លឹះមួយចំនួនសម្រាប់អ្នកក្នុងការបង្ហាញការយល់ចិត្តចំពោះសិស្សរបស់អ្នកនិងកំណត់បរិបទត្រឹមត្រូវសម្រាប់ការសិក្សា។

#### ស្វាគមន៍សិស្សពេលពួកគេមកដល់

- ស្វាគមន៍សិក្សសដែលមកដល់ នៅពេលដែលអាច។
- អញ្ជើញពួកគេចូលកន្លែងអង្គុយ។
- នៅក្នុងវគ្គសិក្សាដំបូង ត្រូវព្យាយាមស្គាល់ពួកគេម្នាក់ៗតាមរយៈការកត់បញ្ជីវត្តមាន។ ប្រើប្រាស់សកម្មភាពបើកចំហដើម្បីចាប់ផ្តើមការបណ្តុះបណ្តាល
- នៅពេលដែលអាច ត្រូវប្រើប្រាស់សកម្មភាពដែលពាក់ព័ន្ធនឹងប្រធានបទ។
- ប្រសិនបើចាំបាច់ ត្រូវឱ្យសិស្សធ្វើសកម្មភាពពាក់ព័ន្ធនឹងប្រធានបទ (ដូចជាការធ្វើតេស្តខ្លី) នៅពេលរងចាំអ្នកផ្សេងទៀត។
- ឱ្យសិស្សចូលរួមដើម្បីជួយកំណត់ការរំពឹងទុក និងវិធានជាមូលដ្ឋាន។ ណែនាំខ្លួនឯងដើម្បីបង្កើតជាការទុកចិត្តនិងការជឿជាក់
- ជាក់លាក់ – ចែករំលែកព័ត៌មានដែលសិស្សត្រូវដឹង។ ព័ត៌មានផ្សេងៗ ឬបន្ថែម អាចនឹងត្រូវលើកឡើងនៅក្នុងអំឡុងពេលបណ្តុះបណ្តាល។
- ចងចាំ – ការទុកចិត្ត កើតចេញពីសមត្ថភាពក្នុងការបណ្តុះបណ្តាល មិនមែនអ្វីដែលអ្នកនិយាយអំពីខ្លួនឯងនោះទេ។ កសាងទំនាក់ទំនងដោយប្រើប្រាស់យុទ្ធសាស្ត្រជាច្រើន
- អាចសួរនាំបាន
- មានភាពរសើបបែបវប្បធម៌
- បង្ហាញអំពីឥរិយាបថមិនតឹងតែង
- ផ្តល់នូវរឿងនិទានខ្លីៗអំពីខ្លួនឯងពាក់ព័ន្ធបទពិសោធន៍ក្នុងនាមជាសិស្ស
- ប្រើប្រាស់បច្ចេកទេសទំនាក់ទំនងជាពាក្យសម្តី និងមិនមែនពាក្យសម្តីសមស្រប

### ១.២.២ ពង្រឹងវត្តមានខ្លួនឯងនៅក្នុងថ្នាក់រៀន

ក្នុងនាមជាគ្រូឧទ្ទេសជាការសំខាន់ត្រូវមានការស្គាល់ខ្លួនឯងឱ្យបានច្បាស់អំពីរបៀបក្នុងការនិយាយនិងកាយវិការ។ នេះគឺជាដោយសារតែសិស្សនឹងធ្វើការសន្និដ្ឋានលើអ្នកដោយផ្អែកលើអ្វីដែលពួកគេស្តាប់ឮនិងមើលឃើញ ការលើកដាក់សំឡេង ការបញ្ចេញសំឡេង ការដំឡើងសំឡេង និងកាយវិការរបស់អ្នក។

### ១.២.៣ ដំណើរការ និងបច្ចេកទេសសម្របសម្រួល

ការក្លាយជាគ្រូឧទ្ទេសមានឥទ្ធិពលមានន័យថាជាការមានសមត្ថភាពក្នុងការធ្វើឱ្យការសិក្សាកើតមានឡើង។ការសិក្សាមិនមែនគ្រាន់តែកើតឡើងនៅពេលដែលអ្នកនិយាយគ្រប់ពេលនោះទេ។ ការសិក្សាបែបស្រាវជ្រាវជាច្រើនបាន

រកឃើញថាឱកាសជាច្រើនដែលអ្នកអនុញ្ញាតឱ្យសិស្សនិយាយនោះពួកគេនឹងអាចរៀនបានកាន់តែច្រើន។ ដើម្បីផ្តល់ឱកាសឱ្យសិស្សនិយាយ គ្រូបណ្តុះបណ្តាលឬគ្រូឧទ្ទេសត្រូវតែមានជំនាញដូចខាងក្រោម៖

- **ជំនាញសួរសំណួរ** ការដែលអាចសួរសំណួរ គឺជាបច្ចេកទេសដ៏សំខាន់បំផុតមួយ ដែលគ្រូឧទ្ទេសមានឥទ្ធិពលត្រូវមាន។ សួរសំណួរនៅពេលសមស្របក្នុងការសួរ អាចធ្វើឱ្យមានការចូលរួមដោយបង្កើតឱ្យមានការពិភាក្សានិងជួយតាមដានដំណើរការនៃការសិក្សាផងដែរ។
- **ជំនាញស្តាប់សកម្ម** ការស្តាប់សកម្មជាទូទៅគឺរួមមាន ការស្តាប់ ការចូលរួម (ភាសាកាយវិការ) ការនិយាយរៀបរាប់ឡើងវិញ និងការសង្ខេប។ តាមរយៈការស្តាប់សកម្ម គ្រូឧទ្ទេសអាចបង្វែរចំណាប់អារម្មណ៍របស់សិស្សឱ្យទៅជាការលើកទឹកចិត្តឱ្យមានករចូលរួមសកម្ម។ ការស្តាប់ប្រកបដោយការយកចិត្តទុកដាក់ អាចនាំទៅរកការសួរសំណួរដែលជំរុញឱ្យមានការពិភាក្សាកាន់តែច្រើន។
- **ការពន្យល់និងការផ្តល់ការណែនាំ** ជំនាញនេះ ក៏មានភាពសំខាន់ខ្លាំងណាស់ដែរសម្រាប់ការសិក្សាប្រកបដោយប្រសិទ្ធភាព។ សិស្សមិនអាចចូលរួមយ៉ាងមានប្រសិទ្ធភាពក្នុងការសិក្សាបានទេប្រសិនបើការណែនាំមិនមានភាពច្បាស់លាស់។ សេចក្តីណែនាំច្បាស់លាស់ដែលជាការរៀបរាប់មួយជំហានម្តងៗ គឺចាំបាច់ខ្លាំងណាស់ចំពោះសកម្មភាពសិក្សាក្នុងការឈានទៅសម្រេចបាននូវគោលបំណងរបស់ពួកគេ។ ការណែនាំអាចនឹងត្រូវផ្តល់ជូនជាពាក្យសម្តី ប៉ុន្តែការណែនាំខ្លះក៏អាចធ្វើឡើងតាមរយៈជារូបភាពគ្រប់ពេលផងដែរ នៅក្នុងអំឡុងពេលសកម្មភាពដើម្បីឱ្យសិស្សអាចមើលឃើញ និងពិនិត្យកិច្ចការនៅពេលកំពុងអនុវត្ត។
- **ជំនាញជំរុញទឹកចិត្ត** គ្រូឧទ្ទេសមានឥទ្ធិពលត្រូវតែអាចជំរុញការចាប់អារម្មណ៍របស់សិស្សនិងជំរុញឱ្យមានការចូលរួម។ចំណុចនេះ អាចត្រូវបានធ្វើឡើងតាមរយៈ៖
  - ✓ ការពន្យល់អំពីគោលបំណង/លទ្ធផលសិក្សាច្បាស់លាស់ក៏ដូចជាអត្ថប្រយោជន៍នៃសកម្មភាពសិក្សា
  - ✓ ការសារទររបស់គ្រូបណ្តុះបណ្តាល
  - ✓ ការចែករំលែកអារម្មណ៍ផ្ទាល់ខ្លួនជាមួយសិស្ស
  - ✓ ការបង្ហាញទំនុកចិត្តចំពោះសិស្ស។

### ១.២.៤ ឥទ្ធិពលនៃហ្គេមនិងការបង្រៀនដៃគូ

មិនមែនគ្រប់សិស្សទាំងអស់អាចរៀនបានទៅតាមមធ្យោបាយដូចគ្នានោះទេ។ ដូច្នេះជាការសំខាន់ត្រូវធានាថាការបណ្តុះបណ្តាលរបស់អ្នកគឺមានដាក់បញ្ចូលនូវអភិក្រមនិងបច្ចេកទេសខុសគ្នាដើម្បីអាចបំពេញតាមតម្រូវការរបស់សិស្សខុសៗគ្នា។

- **ការប្រើប្រាស់ហ្គេម៖** ក្រៅពីការធ្វើបទបង្ហាញ ការពិភាក្សា ការសម្តែងតួ សកម្មភាពក្រុមជាប្រចាំដូចជាករណីសិក្សាជាដើមនោះ ហ្គេមក៏អាចត្រូវបានប្រើប្រាស់ដើម្បីធ្វើឱ្យការសិក្សាកាន់តែមានភាពរីករាយផងដែរហើយការលេងហ្គេមនេះក៏មានប្រសិទ្ធភាពសម្រាប់សិស្សដែលមានការសិក្សាបែបកាយវិញ្ញាណផងដែរ។ នៅក្នុងឧទាហរណ៍ជាច្រើនទស្សនទានអាចនឹងត្រូវបង្រៀនបានយ៉ាងមានប្រសិទ្ធភាពតាមរយៈការលេងហ្គេមដូចជាហ្គេមកាតសម្រាប់ជំនាញចរចា ហ្គេមក្តារសម្រាប់ទស្សនទានហិរញ្ញវត្ថុ និងហ្គេមផ្សេងៗជាច្រើនទៀត។
- **ការបង្រៀនដៃគូ៖** សិស្សកាន់តែមានឱកាសនិយាយច្រើន នឹងអាចរៀនបានកាន់តែច្រើន។ ការបង្រៀនដៃគូគឺជាវេទិការដ៏ល្អបំផុតសម្រាប់សិស្សក្នុងការ“និយាយនិងសិក្សា”។ជាពិសេស នៅពេលសិស្សត្រូវបង្រៀន ការសិក្សានឹងកាន់តែមានភាពស៊ីជម្រៅខ្លាំង។

### ១.២.៥ ការអនុវត្តសកម្មភាព[៥]

មានដំណើរការសម្របសម្រួលចំនួនប្រាំជំហាន ដែលអាចប្រើប្រាស់ដើម្បីសម្របសម្រួលសកម្មភាពសិក្សាយ៉ាងមានប្រសិទ្ធភាព។

- **ជំហានទី ១៖** គ្រូឧទ្ទេស ពន្យល់អំពីគោលបំណងនៃសកម្មភាព និងផ្ដល់ទិសដៅ និងការណែនាំអំពីរបៀបក្នុងការបំពេញកិច្ចការ។

- **ជំហានទី ២៖** គ្រូឧទ្ទេស ប្រាកដថាសិស្សបានចូលរួមបានច្រើននៅក្នុងការធ្វើសកម្មភាព។

- **ជំហានទី ៣៖** គ្រូឧទ្ទេសជួយសិស្សឱ្យចែករំលែកបទពិសោធន៍តាមរយៈការសួរសំណួរដែលមានដំណាក់កាលសមស្របដូចជា៖

✓ តើហេតុការណ៍អ្វីដែលសំខាន់ខ្លាំងបំផុត/មិនសំខាន់សម្រាប់អ្នក?
✓ តើអ្នកមានប្រតិកម្មយ៉ាងណាចំពោះហេតុការណ៍នោះ?
✓ តើចំណុចសិក្សាគន្លឹះអ្វីដែលអ្នកទទួលបានពីហេតុការណ៍នោះ?

- **ជំហានទី ៤៖** គ្រូឧទ្ទេសសួរអំពីទស្សនាទានពីសិស្ស ដោយមិនប្រាប់ពួកគេអំពីទស្សនទាន

- **ជំហានទី ៥៖** គ្រូឧទ្ទេស លើកទឹកចិត្តសិស្សឱ្យឆ្លុះបញ្ចាំងអំពីរបៀបដែលពួកគេអាចអនុវត្តការសិក្សានៅកន្លែងការងារ។ កត្តានេះអាចអនុវត្តបានដោយការសួរសំណួរដូចជា៖

✓ តើអ្នកដោះស្រាយស្ថានភាពនោះយ៉ាងដូចម្ដេចនៅពេលក្រោយ?
✓ តើអ្វីជាផលវិបាក ប្រសិនបើអ្នកអនុវត្តនិងមិនអនុវត្តយុទ្ធសាស្ត្រទាំងនេះ?
✓ តើអ្នកនឹងធ្វើឱ្យខុសគ្នាយ៉ាងដូចម្ដេចនៅពេលក្រោយ?



រូបភាព ១៨៖ ការបណ្ដុះបណ្ដាលដៃគូ

៥ ការសម្របសម្រួលការសិក្សារបស់មនុស្សពេញវ័យ ©សហព័ន្ធនិយោជកជាតិសិង្ហបុរី ខែមិថុនា ឆ្នាំ២០១៤

## ១.៣ ការសម្របសម្រួលកិច្ចពិភាក្សា ករណីសិក្សា និងការសម្តែងតួ

### ១.៣.១ ការពិភាក្សា

ដើម្បីសម្របសម្រួលកិច្ចពិភាក្សាប្រកបដោយភាពជោគជ័យ គ្រូឧទ្ទេសត្រូវធ្វើការលើកទឹកចិត្តអ្នកគ្រប់គ្នាឱ្យរួមចំណែកនិងចែករំលែកគំនិត។ បច្ចេកទេសក្នុងការសម្របសម្រួលកិច្ចពិភាក្សាប្រកបដោយប្រសិទ្ធភាព គឺរួមមានសកម្មភាពដូចខាងក្រោម៖

- **ការរៀបចំផែនការជាមុន៖** រៀបចំសំណួរដើម្បីផ្តួចផ្តើមការពិភាក្សាធ្វើការសួរព័ត៌មាននិងគំនិតយោបល់ពីសិស្ស។
- **រងចាំឱ្យសិស្សឆ្លើយតប៖** បន្ទាប់ពីសួរសំណួររួច ត្រូវទុកពេលឱ្យសិស្សស្វែងយល់អំពីសំណួរ និងគិតអំពីចម្លើយ។
- **លើកទឹកចិត្តឱ្យមានការរួមចំណែក៖** ហៅឈ្មោះសិស្សឬសួរសំណួរទៅកាន់ក្រុមតូចមួយ។អញ្ជើញសិស្សឱ្យចែករំលែកឧទាហរណ៍ពាក់ព័ន្ធនិងជាក់លាក់។ ត្រូវចាំថាត្រូវផ្តល់ឱកាសឱ្យសិស្សដែលស្ងាត់ស្ងៀមចែករំលែកផងដែរ។
- **ការស្តាប់ដោយយកចិត្តទុកដាក់៖** យកចិត្តទុកដាក់ស្តាប់ការឆ្លើយតបទាំងអស់។សួរបញ្ជាក់ភ្លាមៗប្រសិនបើចម្លើយទាំងនោះមិនមានភាពច្បាស់លាស់។ រៀបពាក្យឡើងវិញ ឬសួរសំណួរបែបអង្កេត ដើម្បីបញ្ជាក់អំពីការយល់ដឹង។ ភ្ជាប់មតិយោបល់ប្រសិនបើអាច ប៉ុន្តែការធ្វើបែបនេះតម្រូវឱ្យអ្នកចងចាំថា "នរណាជាអ្នកនិយាយអ្វី"។
- **កត់ត្រាគំនិត៖** សរសេរចម្លើយពាក់ព័ន្ធទាំងអស់នៅលើតារាងឬក្តារយៀន។ការកត់ត្រាគំនិតនេះដោយជួយសម្រួលដល់ការពន្យល់សង្ខេបនៅពេលបញ្ចប់សកម្មភាព។
- **ពិនិត្យឡើងវិញ ជំរុញការអនុវត្ត និងធ្វើឡើងវិញ៖** ឱ្យសិស្សសង្ខេបអំពីការពិភាក្សា។ ជំនួយមកវិញត្រូវសួរសំណួរផ្ទាល់សម្រាប់ឱ្យសិស្សកំណត់អំពីទស្សនទានដែលបានពិភាក្សា។ សូមចងចាំថាត្រូវផ្ទេរការសិក្សានេះទៅកន្លែងធ្វើការ។

### ១.៣.២ ករណីសិក្សា

ករណីសិក្សាជាទូទៅត្រូវបានផ្តល់ជូនជាសេណារីយ៉ូ (ជាក់ស្តែង ឬប្រឌិត)ដែលសិស្សត្រូវធ្វើការវិភាគនិងឆ្លុះបញ្ចាំងបន្ទាប់មកត្រូវអនុវត្តទស្សនាទាននិងគោលការណ៍ដែលបានសិក្សាដើម្បីដោះស្រាយបញ្ហាមួយចំនួន។ ការសម្របសម្រួលករណីសិក្សាគឺមានភាពស្រដៀងគ្នាទៅនឹងការសម្របសម្រួលកិច្ចពិភាក្សាដែរ។ ចំណុចខុសគ្នាតែមួយនោះគឺថាត្រូវផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់ជូនទៅសិស្សដើម្បីអាននិងពិនិត្យមើលករណីសិក្សានោះ។ ដើម្បីឱ្យសិក្សាកាន់តែមានប្រសិទ្ធភាព គ្រូឧទ្ទេសគប្បីពន្យល់ករណីនោះបន្ទាប់ពីសិស្សបានអានចប់មុនពេលអនុញ្ញាតឱ្យពួកគេធ្វើការឆ្លើយសំណួរទាំងនោះ។ បន្ទាប់មកករណីសិក្សានឹងត្រូវសម្របសម្រួលដូចជាការសម្របសម្រួលកិច្ចពិភាក្សាអញ្ចឹងដែរ។

**កំណត់សម្គាល់៖** ករណីសិក្សា គឺមានប្រយោជន៍ជាខ្លាំងសម្រាប់សិស្ស ក្នុងការស្វែងរកទស្សនាទានថ្មី ដែលពួកគេអាចកសាងបន្ថែមពីលើបទពិសោធន៍របស់ពួកគេ។ ប៉ុន្តែករណីសិក្សាមួយចំនួន គឺត្រូវចំណាយពេលច្រើនដើម្បីសម្របសម្រួល ហើយករណីសិក្សាទាំងនោះមានប្រសិទ្ធភាពដែលនៅពេលដែលដំណើរការរៀបរាប់សង្ខេបគឺមានភាពច្បាស់លាស់និងសម្របសម្រួលបានល្អ។




រូបភាព ១៩៖ ការពិភាក្សាក្រុម

### ១.៣.៣ ការសម្តែងតួ

ការសម្តែងតួ ជាទូទៅត្រូវបានអនុវត្តឡើងក្នុងគោលបំណងចំនួនពីរ ដើម្បីឱ្យសិស្សអនុវត្តជំនាញដែលបានរៀនរួច ឬដើម្បីស្វែងយល់និងយល់អារម្មណ៍របស់អ្នកដទៃ។ ប៉ុន្តែការសម្តែងតួត្រូវបានធ្វើឡើងដោយមានការយកចិត្តទុកដាក់ខ្លាំងបំផុតដោយសារតែសិស្សពេញវ័យជាច្រើននឹងមិនមានភាពស្រួលចិត្តក្នុងការសម្តែងតួនោះទេ។

ការសម្របសម្រួលការសម្តែងតួនឹងតម្រូវឱ្យគ្រូឧទ្ទេស៖

- រៀបចំផែនការសេណារីយ៉ូ និងត្រៀមសម្ភារសម្រាប់សម្តែងដែលចាំបាច់សម្រាប់ការសម្តែងជាមុន។
- ធានាថាបរិយាកាសបណ្តុះបណ្តាល គឺមានសុវត្ថិភាពក្នុងការចាប់ផ្តើមសម្តែងតួ
- កាត់បន្ថយភាពភ័យខ្លាច ឬការនឿយហត់ ដោយការចាត់ទុកសកម្មភាពនេះ គឺជាការអនុវត្តជំនាញ
- ធានាថា សិស្សមិនមានការអៀនខ្មាស់ក្នុងការសម្តែងនៅចំពោះមុខមិត្តរួមថ្នាក់នោះទេ។
- ផ្តល់ឱកាសឱ្យសិស្ស ហាត់សម ការសម្តែងរបស់ខ្លួនប្រសិនបើចាំបាច់។
- ផ្តល់ការណែនាំច្បាស់លាស់ទៅកាន់តួសម្តែងនីមួយៗ (តួប្រុសនិងតួស្រី)។
- ធានាថាមានអ្នកអង្កេតមើល ដើម្បីផ្តល់មតិត្រលប់ទៅលើការអនុវត្តជំនាញនោះ។
- ផ្តល់នូវការពន្យល់សង្ខេបច្បាស់លាស់នៅពេលបញ្ចប់សកម្មភាពដែលបូករួមបញ្ចូលនូវការសួរសំណួរដើម្បីបង្កើតការយល់ដឹងនិងការសិក្សា

*ខ្ញុំស្តាប់ ខ្ញុំភ្លេច*

*ខ្ញុំមើលឃើញ ខ្ញុំចងចាំ*

*ខ្ញុំធ្វើ ខ្ញុំយល់។*

### ១.៣.៤ ការសង្ខេបមេរៀន

ដើម្បីឱ្យសកម្មភាពនៃការសិក្សាអាចសម្រេចបានលទ្ធផលនៃការសិក្សា យើងត្រូវតែមានវគ្គសង្ខេបមេរៀន បន្ទាប់ពីសកម្មភាពត្រូវបានអនុវត្តរួច។ ក្នុងអំឡុងពេលសង្ខេបមេរៀន គ្រូឧទ្ទេសនឹងត្រូវជួយសិស្សឱ្យ៖

- ✓ យល់ដឹងកាន់តែល្អប្រសើរអំពីគោលបំណងនៃសកម្មភាព
- ✓ សិក្សាពីបទពិសោធន៍
- ✓ ផ្ទេរចំណុចដែលបានសិក្សាទៅកន្លែងធ្វើការ

វិធីសាស្ត្រដ៏សាមញ្ញក្នុងការសង្ខេបមេរៀនគឺការសួរបីសំណួរ៖

**១) តើមានអ្វីកើតឡើង?**

- ✓ តើអ្នកបានឃើញនិងស្តាប់ឮអ្វីខ្លះ?
- ✓ តើអ្នកបានធ្វើអ្វីខ្លះដើម្បីឆ្លើយតបទៅនឹងស្ថានភាពនោះ?
- ✓ តើអ្វីដែលធ្វើបានល្អនិងអ្វីដែលធ្វើមិនបានល្អ?

**២) អញ្ចឹងតើយ៉ាងណាដែរ?**

- ✓ តើអ្នកបានសិក្សាអ្វីខ្លះពីហេតុការណ៍នេះ?
- ✓ តើអ្នកធ្វើការសន្និដ្ឋានអ្វីអំពីគ្រោះថ្នាក់នេះ?

**៣) ចុះឥឡូវយ៉ាងណាដែរ?**

- ✓ តើខ្ញុំអាចអនុវត្តអ្វីដែលខ្ញុំបានសិក្សាទៅកន្លែងធ្វើការបានយ៉ាងដូចម្តេច?
- ✓ តើមានផលវិបាកអ្វីចំពោះការអនុវត្ត ឬមិនអនុវត្តអ្វីដែលបានសិក្សានៅសាលារៀន?

### ១.៣.៥ ការផ្តល់មតិត្រលប់

ការផ្តល់មតិត្រលប់ទាន់ពេលវេលាគឺជាជំនាញដ៏សំខាន់មួយទៀត ដែលគ្រូឧទ្ទេសត្រូវតែមាន ដើម្បីសម្របសម្រួលការសិក្សាឱ្យកាន់តែមានប្រសិទ្ធភាព។ គោលបំណងនៃការផ្តល់មតិត្រលប់ក្នុងអំឡុងពេលបណ្តុះបណ្តាលគឺជាការលើកទឹកចិត្តឱ្យសិស្សសិក្សានិងកាន់តែមានការអភិវឌ្ឍជាបន្តបន្ទាប់ដើម្បីអាចធ្វើការងារជាច្រើនខុសៗគ្នាបាន។ មតិត្រលប់ជួយឱ្យសិស្សសិក្សាអំពីអ្វីដែលគួរធ្វើដើម្បីទទួលបានភាពជោគជ័យនិងអ្វីដែលមិនគួរធ្វើពីកំហុសនិងភាពបរាជ័យ។

**ចប់ការបណ្តុះបណ្តាល!**

## ឧបសម្ព័ន្ធ

១. ឧបសម្ព័ន្ធមួយ៖ គំរូតេស្តមុនវគ្គនិងក្រោយវគ្គ

២. ឧបសម្ព័ន្ធពីរ៖ បញ្ជីបទបង្ហាញស្លាយដ៍ PowerPoints